ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Feb-2017, 09:13
CMS/CFO: Sann Rada

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>**

**<u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>**

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី៤៨៥**

ចៅក្រមសាលាដំបូង៖

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

ក្រឡាបញ្ជីសាលាដំបូង៖

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

លោក ឯម ហ៊ុយ

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆរ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

ជនជាប់ចោទ៖

លោក នួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ នួន ជា៖

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វាំងសង់ វ៉ាយឌ៍ ដេស្នាឯល | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោកស្រី ទី ស្រ៊ីនណា | ខ្មែរ |
| លោកស្រី ខៀវ នាប (2-TCCP-258) | ខ្មែរ |
| ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី ខៀវ នាប** (2-TCCP-258)

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី....................................................... ទំព័រ ៣
សួរដោយកញ្ញា អង់តា ហ្គិសសេ ផ្ដើមពី........................................................................ ទំព័រ ៣៣
សួរដោយលោក គង់ សំអុន ផ្ដើមពី ............................................................................ ទំព័រ ៤៦

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖** 2-TCCP-1063

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖.................................................................................. ទំព័រ ៥៧
សួរដោយលោកស្រី ទី ស្រ៊ីនណា ផ្ដើមពី៖........................................................................ ទំព័រ ៥៩
សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី៖.................................................................... ទំព័រ ៧៧

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:៤០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប បញ្ចប់ ហើយនិងផ្តើមស្តាប់សក្តីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063។ ហើយមុននឹងបន្តដំណើរការសវនាការ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីក្នុងសំណុំរឿង០០២/០២ ទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ ដោយលោកចៅក្រម យូរ ឧត្តរា មានធុរៈផ្ទាល់ខ្លួនចាំបាច់ មិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការបាន បន្ទាប់ពីយើងខ្ញុំពិគ្រោះយោបល់ជាមួយនឹងចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងភាគីជាតិជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលអវត្តមានរហូតដល់ពេលណាដែលចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ហើយការសម្រេចនេះ ផ្អែកលើខ្លឹមសារនៃបទប្បញ្ញត្តិវិធាន៧៩(៤)នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គល អង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៥:៥៥]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ខៀវ នាប លោកស្រីមានវត្តមាន រួចហើយនៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានដើមបណ្ដឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-1063។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ បានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

[០៩:០៧:០៩]

បានឃើញកំណត់ហេតុពិនិត្យសុខភាព ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះ ជាប្រចាំ អង្គុយយូរកាន់តែឈឺខ្លាំង និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់ លើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1063 ជាឯកសារភស្តុតាង។ អង្គជំនុំជម្រះកត់សម្គាល់ថា

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 ដែលបច្ចុប្បន្ននេះ មានលេខឯកសារD22/144 នៅពេលថ្មីៗនេះ អង្គជំនុំជម្រះបានទទួលយកទម្រង់បែបបទព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធ្វើជាឯកសារភស្តុតាងដែលមានលេខឯកសារ E3/10670 (សូមមើលឯកសារ E436/1)។ ទម្រង់បែបបទព័ត៌មានបន្ថែមទៀត របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានទទួលយកជាឯកសារភស្តុតាងកាលពីពេលមុន ហើយមានលេខឯកសារ E3/5932a។ ផ្អែកលើការអនុវត្តរបស់អង្គជំនុំជម្រះ ទាក់ទងនឹងការទទួលយកសម្ភារៈ ទាក់ទងនឹងបុគ្គលនានាដែលនឹងត្រូវមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ហេតុដូច្នេះអង្គជំនុំជម្រះទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 ធ្វើជាឯកសារភស្តុតាង និងដាក់លេខឯកសារ E3/10670a សម្រាប់ឯកសារនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

[០៩:១០:១៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន និងលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ វ៉ាំងសង់ដេរីល។ ខ្ញុំនឹងចោទសំណួរទៅកាន់លោកស្រី តាងនាមឱ្យការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំដឹងថា វាជាការលំបាកសម្រាប់លោកស្រីក្នុងការនឹកនូវហេតុការណ៍ដែលបានកើតឡើងកាលពីយូរណាស់មកហើយ ក៏ប៉ុន្តែទោះជាយ៉ាងក៏ដោយ សូមលោកស្រីឆ្លើយខ្លីៗ ច្បាស់ៗទៅនឹងសំណួររបស់ខ្ញុំ។ ប្រសិនបើលោកស្រី<>មិនដឹងចម្លើយទេ លោកស្រីប្រាប់ថា លោកស្រីមិនដឹងទេ។ ហើយបើលោកស្រីស្តាប់មិន<យល់>នូវសំណួរ សូមលោកស្រីប្រាប់ឱ្យខ្ញុំសួរឡើងវិញ។

សំណួរដំបូង គឺពាក់ព័ន្ធនឹងសមាជិកគ្រួសារលោកស្រី។ តើសមាជិកគ្រួសារលោកស្រីហ្នឹង មានអ្នកណាជានាយទាហាន ឬក៏ជាទាហានរបស់សាធារណរដ្ឋខ្មែរ ឬក៏របប លន់ លន់ ឬក៏ជាមន្ត្រីរដ្ឋការ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លន់ នល់ ពីចន្លោះឆ្នាំ៧០ ដល់ឆ្នាំ៧៥ ដែរឬទេ?

[០៩:១១:២៧]

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ក្រុមគ្រួសារនាងខ្ញុំ គឺពីសម័យសង្គ្រាម លន់ នល់ គឺមានតែឪពុកមាមួយ។ តែគាត់បានចូលមកនៅទឹកដីកំពង់ឆ្នាំង តែនោះក៏បាត់ខ្លួនទាល់ឥឡូវដែរ។ តែក្រុមគ្រួសារផ្ទាល់ ដូចជាគ្រួសារជាប្ដីខ្ញុំនេះ ក៏អត់បានធ្វើសង្គ្រាម លន់ នល់ ទេ -- អត់បានធ្វើទាហានលន់ នល់ គឺនៅខាងក្រៅ គឺធ្វើការផ្នែកខាងយោធា ខាងខ្មែរក្រហម។

**ស៖** លោកស្រីអាចប្រាប់ឈ្មោះឪពុកមាដែលបានបាត់ខ្លួនហ្នឹងទេ?

**ឆ៖** ចាស ឪពុកមាខ្ញុំឈ្មោះ ឈុន ឈឿង។

**ស៖** តើឪពុកមារបស់លោកស្រីបាត់ខ្លួននៅពេលណា <តើគាត់បាត់ខ្លួននៅក្នុង>ឆ្នាំ៧៥ ឬក៏នៅពេលណា? មុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ ឬក៏ក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ ក្រោយពេលដែល<ពួក>បដិវត្តហ្នឹង វ៉ៃយកភ្នំពេញបាន?

**ឆ៖** ចាស ឪពុកមាខ្ញុំបាត់ខ្លួនក្រោយ៧៥។

**ស៖** តើលោកស្រីដឹងថាគាត់បាត់ខ្លួនហ្នឹងក្នុងកាលៈទេសៈបែបណាទេ? មានអ្នកណានិយាយប្រាប់លោកស្រីទេ?

[០៩:១៣:២២]

**ឆ៖** ចាស ឪពុកមាខ្ញុំនេះ គឺបានដំណឹង។ ដំណឹងនោះ គឺនៅក្នុងឃុំជាមួយគ្នានោះឯង តែចេញពីមកខាងក្នុងទឹកដីខេត្តកំពង់ឆ្នាំងមក មានគ្នាពីរនាក់ ទៅភូមិជាមួយគ្នា។ តែដល់ពេលដែលចេញមកហើយ គេបានអំពាវនាវថា បើសិនជាបុគ្គលណាធ្វើការអ្វី គេឲ្យទៅធ្វើការនោះវិញ។ តែឪពុកមាខ្ញុំ គឺថាចាញ់បោកគេទៅ។ គាត់បង្ហាញខ្លួន បង្ហាញសិទ្ធិ តួនាទីរបស់ខ្លួន។ ទៅ ក៏គេយកទៅបាត់ទៅ។ តែឈ្មោះរ៉ូ ក៏គេមិនបានបង្ហាញខ្លួនថា គេបានធ្វើអី ក៏គេរួចខ្លួន មកដល់ភូមិកំណើតវិញ។ តែរយៈក្រោយមក ក្នុងក្រោយ៧៥មក គឺគេស្រាវជ្រាវទៅតាមខ្សែរយៈ គេដឹងប្រវត្តិយើងធ្វើទាហាន លន់ នល់ អ៊ីចេះទៅ ក៏គេយកទៅបាត់ដែរទៅ ទាល់ឥឡូវនេះ។

**ស៖** សូមអរគុណលោកស្រី។ កាលពីម្សិលមិញលោកស្រីបាននិយាយថា លោកស្រីបាន<> ជួបប្ដី<លោកស្រីម្ដងទៀត>នៅពេលចូលឆ្នាំខ្មែរ នៅឆ្នាំ៧៨ <នៅជិតផ្សារថ្មី> នៅភ្នំពេញ <>ហើយ

ពេលនោះលោកស្រីថា លោកស្រីធ្វើជាចុងភៅ។ ពេលដែលលោកស្រីទៅហ្នឹង គឺលោកស្រីនៅក្នុងអង្គភាពតែមួយជាមួយប្ដីរបស់លោកស្រីហ្នឹង គឺអង្គភាពផ្គត់ផ្គង់ផ្សារដ្ឋហ្នឹង មែនទេ?

**ឆ៖** ចាស ខ្ញុំក្នុងឆ្នាំ៧៨ គឺប្ដីខ្ញុំទៅយកខ្ញុំពីផ្ទះមក ថាមកចូលឆ្នាំក្នុង៧៨នេះ មកដល់ពេលវេលាមុនចូលឆ្នាំ ក្នុងពេលរយៈពីរបីថ្ងៃនេះ ក៏ខ្ញុំគេចាត់តាំងនៅចុងភៅ តែនៅចង្កោមក្រុមគ្រួសារជាមួយស្នាក់នៅជាមួយគ្នា។

[០៩:១៥:៣៨]

**ស៖** ចុះក្រោយមកលោកស្រីនៅតែបន្តធ្វើចុងភៅដដែល រហូតដល់ប្ដីលោកស្រីបាត់ខ្លួនមែនទេ?

**ឆ៖** ចាស ដល់ពេលខ្ញុំធ្វើម្ហូបចុងភៅនេះ ទាល់ពេលប្ដីខ្ញុំបាត់ខ្លួន ខ្ញុំក៏ចេញដំណើរថ្ងៃនោះឯងជាមួយគ្នាដែរ។ គេបញ្ចេញខ្ញុំពីថ្ងៃជាមួយនោះឯង ខុសតែម៉ោងគ្នាទេ។

**ស៖** អង្គភាពចុងភៅចំណុះឲ្យ<ក្រសួង>៨៧០ មែនទេ?

**ឆ៖** ចាស កន្លែងនោះឯង គេហៅថា ផ្សារដ្ឋ ផ្គត់ផ្គង់សេដ្ឋកិច្ច អង្ករ បន្លែ ម្ហូបអាហារអី គេហៅថា "ក្រសួង៨៧០"។

**ស៖** កាលពីម្សិលមិញ ពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់លោកស្រីមេធាវី ម៉ារី ហ្គីរ៉ូដ៍ លោកស្រីបញ្ជាក់ថា ប្ដីរបស់លោកស្រីមិនមែនជាកម្មាភិបាលទេ គ្រាន់តែជាកម្មករលីសែងធម្មតាតែប៉ុណ្ណោះ។ ដូច្នេះខ្ញុំចង់សួរបញ្ជាក់ត្រង់ចំណុចនេះ ឲ្យបានច្បាស់ ពីព្រោះថា នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់លោកស្រី គឺឯកសារ E3/6425 ជាភាសាបារាំងគឺ 01152692, ជាភាសាអង់គ្លេស 01114153 និងជាភាសាខ្មែរគឺ 00544168។ នេះជាអ្វីដែលបានសរសេរនៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់លោកស្រី។ "ដល់ឆ្នាំ១៩៧៨ បន្ទាប់ពីកម្មាភិបាលជាច្រើនដែលជាប្រធានកង ការិយាល័យ ឬមន្ទីរត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ប្ដីរបស់ខ្ញុំត្រូវបានដំឡើងឲ្យធ្វើជាកម្មាភិបាលនៅមន្ទីរ៨៧០។" ដូច្នេះខ្ញុំសួរសំណួរឡើងវិញលោកស្រី។ នៅឆ្នាំ៧៨ តើមានហេតុការណ៍ដែលបណ្ដាលឲ្យប្ដីលោកស្រីបានឡើងឋានៈទេ គឺគ្រាន់គាត់ឡើងពីកម្មករធម្មតា ទៅជាកម្មាភិបាល?

[០៩:១៨:២៩]

**ឆ៖** ចាស ដែលហៅថា ប្ដីខ្ញុំជាប្រធានកងវរសេនាតូចនោះ ខ្ញុំបាននិយាយថា អង្កាល់ពីនៅកាន់អាវុធ គឺប្ដីខ្ញុំមានតួនាទីពិតមែន អ៊ីចេះឯង។ ដល់ពេលដាច់៧៥ ប្ដីខ្ញុំចូលមកនៅនឹងផ្សារដ្ឋនេះ គឺជាកម្មករធម្មតា សមាជិករបស់គេ គ្រាន់តែថា ប្រមូលលទ្ធផលបញ្ចូលក្នុងឃ្លាំងនោះទេ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោកមេធាវី វ៉ិចទ័រ កូប៉េ?

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថា ជាការជំទាស់ ឬជាការកត់សម្គាល់ទេ ដោយសារ ងើបឃើតបន្តិច។ តើពាក្យថា "កម្មាភិបាល" សហព្រះរាជអាជ្ញាចង់និយាយថាដូចម្ដេច? តើតំណាងសហព្រះរាជអាជ្ញាចង់និយាយអំពីសមាជិកបក្សកុម្មុយនីស្តកម្ពុជា ឬក៏ចង់និយាយថា យ៉ាងដូចម្ដេច? ខ្ញុំមិនដឹងថាពាក្យ "កម្មាភិបាល" នេះមានន័យដូចម្ដេច។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំគិតថា ខ្ញុំសួរទៅគាត់ ហើយគាត់បានឆ្លើយហើយ។ អ៊ីចឹងមិនចាំបាច់ជជែកតវ៉ាអីគ្នាទេ។ ខ្ញុំដឹងថា កម្មាភិបាលហ្នឹង គាត់មានទំនួលខុសត្រូវមួយចំនួន ដោយមិនចាំបាច់តែជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានោះទេ។

[០៩:២០:០០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំដឹងថា មានកំហុសនៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់លោកស្រី គឺឯកសារ E3/6425 គឺប្ដីរបស់លោកស្រីមិនដែលធ្វើជាកម្មាភិបាលទេ។ ទោះជាយ៉ាងណាក៏ដោយ លោកស្រីដឹងទេថា អ្នកណាជាប្រធានមន្ទីរផ្គត់ផ្គង់សម្ភារៈរដ្ឋ គឺប្រធានមន្ទីរផ្គត់ផ្គង់ផ្សាររដ្ឋ គឺមានន័យថា ជាមន្ទីរដែលនៅក្រោមចំណុះមន្ទីរ៨៧០នុ៎ង? លោកស្រីដឹងទេថា អ្នកណាជាមេផ្ទាល់របស់ប្ដីលោកស្រី?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស នាងខ្ញុំចូលមកដល់ឆ្នាំ៧៨នេះ គ្រាន់តែដឹងថា ឈ្មោះ ពូវ៉ុយ និង ពូភីន ជាមេនៅក្នុងក្ដោបក្ដាប់នៅក្នុងកន្លែងនោះឯង។ ខ្ញុំស្គាល់តែប៉ុណ្ណោះឯងទេ។

**ស៖** នៅពីលើ <វ៉ុយ> និង <ភីន> ហ្នឹង លោកស្រីមិនដឹងថា អ្នកណាជាអ្នកក្ដាប់រួមនៅក្នុងមន្ទីរហ្នឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពី <វុយ> នៅពេលក្រោយបន្តិចទៀត។ កាលពីម្សិលមិញ លោកស្រីបាននិយាយថា លោកស្រីបានឃើញលោក ខៀវ សំផន <>ចែក<សម្ភារៈ> និងស្បៀងទៅដល់អ្នកមកពីព្រៃវែង គឺភូមិភាគបូព៌ា។ តើលោកស្រីធ្លាប់ឮគេនិយាយពី ខៀវ សំផន ទេ មុនពេលលោកស្រីឃើញគាត់ហ្នឹង ហើយមុនពេលដែលប្ដីលោកស្រីប្រាប់ថា នុ៎ងហើយ ជា ខៀវ សំផន នោះ?

[០៩:២១:៥៧]

**ឆ៖** ចាស ថ្ងៃមួយនោះឯង ដែលគេជម្លៀសប្រជាជនមកពីព្រៃវែង ក៏ពួកខ្ញុំនេះ គេឱ្យដាំបាយធ្វើម្ហូបជូនពួកគាត់។ ដល់ពេលគេមានសម្ភារៈ សម្លៀកបំពាក់ដូចជាក្រមាខោអាវនេះ គេចែកចាយទៅឱ្យគាត់ផង។ ហើយដល់ពេលកំពុងតែចែកបាយហើយ ឃើញ អ៊ំខៀវ សំផន នេះទៅនេះ តែខ្ញុំមិនស្គាល់ទេដំបូងនោះ ក៏ខ្ញុំសួរប្ដីខ្ញុំថា “ពីណានេះអី រាងចម្លែក? ប្ដីខ្ញុំប្រាប់ថា៖ នេះឯងហៅថា អង្គការនោះ ហៅថា តាខៀវ សំផន។” ខ្ញុំស្គាល់ត្រឹមប៉ុណ្ណោះឯងទេ។

**ស៖** ក្រៅពីលោក ខៀវ សំផន តើលោកស្រីធ្លាប់ឮគេនិយាយអំពីអ្នកទទួលខុសត្រូវជាន់ខ្ពស់ផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជាទេ?

**ឆ៖** ចាស ពីមុនមក ក៏ឮគេថា អង្គការៗ តែមិនដឹងឈ្មោះអីដែរ។ មេដឹកនាំកាលពីមុនមក ក៏ខ្ញុំមិនដឹងដែរ។

**ស៖** នៅជិតផ្សារថ្មី លោកស្រីដឹងថា មានមន្ទីរមួយដែលគេហៅថា “មន្ទីរពាណិជ្ជកម្មក្រៅប្រទេស” ទេ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ ត្រង់ណោះឯង។

**ស៖** ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីហេតុការណ៍ដែលលោកស្រីឃើញលោក ខៀវ សំផន ចែកក្រមា និងចំណីអាហារទៅឱ្យប្រជាជនមកពីព្រៃវែង។ តើក្រមាដែលលោក ខៀវ សំផន ចែកហ្នឹង មានពណ៌អ្វីដែរ លោកស្រី?

[០៩:២៤:០៣]

**ឆ៖** ចាស ក្រមាដែលគាត់បានលូកក្រមាមួយ ហុចទៅប្រជាជននៅក្នុងផ្សារថ្មីនោះ ក្រមាសខៀវ។ ពណ៌វា ស-ខៀវ។

**ស៖** ក្រមាពណ៌ស-ខៀវហ្នឹង គឺគេចែកឱ្យតែអ្នកមកពីបូព៌ាដែលនៅជិតផ្សារថ្មីហ្នឹងទេ មែនទេ?

**ឆ៖** ចាស ដែលកំពុងឃើញចែកនោះ គេចែកឱ្យតែពួកនោះឯងទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ដដែល ដូចដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញ នៅពេលដែលមេធាវី ម៉ារី ហ្គីរ៉ូដ៍ គាត់និយាយបញ្ហាស៊ីជម្រៅទៅលើអ្នកជម្លៀសមកពីបូព៌ានោះ។ វគ្គសវនាការយើងនេះ គឺមិននិយាយអំពីហេតុការណ៍ពាក់ព័ន្ធនឹងការជម្លៀសទេ។ អ៊ីចឹងខ្ញុំសូមជំទាស់ ពីព្រោះថា ការជម្លៀសវគ្គដំហានទី៣នេះ គឺមិននៅក្នុងវិសាលភាពទេ។ អ៊ីចឹងខ្ញុំជំទាស់ដដែល ដូចដែលខ្ញុំបានលើកឡើងកាលពីម្សិលមិញអ៊ីចឹង ពាក់ព័ន្ធនឹងបញ្ហានេះ។

[០៩:២៥:៤៩]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

លោកប្រធាន ខ្ញុំដឹងថា មានការជំទាស់ជាច្រើនលើបញ្ហាហ្នឹង ក៏ប៉ុន្តែវាពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន។ នៅថ្ងៃហ្នឹង ហេតុអីបានជាលោក ខៀវ សំផន គាត់នៅទីហ្នឹង។ អ៊ីចឹងដើមបណ្តឹងរដ្ឋប្បវេណីនេះ គាត់អាចនិយាយបានថា ខៀវ សំផន គាត់នៅទីនោះធ្វើអី នៅផ្សារថ្មីហ្នឹង។ អ៊ីចឹងគាត់ថា ខៀវ សំផន ចែកក្រមាពណ៌ ស-ខៀវ។ អ៊ីចឹងវាពាក់ព័ន្ធនឹងតួនាទីរបស់គាត់ហើយ។ ហើយទី២នោះ ខ្ញុំចង់ដឹងថា តើការកំណត់និយមន័យខ្មាំងហ្នឹងវាយ៉ាងម៉េច អ្នកណាខ្លះចូលជាប្រភេទ "ខ្មាំង" <របស់កម្ពុជាប្រជាធិបតេយ្យ>នោះ។ ហើយខ្ញុំក៏មានសំណួរផ្សេងទៀត ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ដែលចែកក្រមា ស-ខៀវ ទៅឲ្យអ្នកជម្លៀសមកពីបូព៌ានោះ ដែលគេនឹងបញ្ជូនទៅពាយ័ព្យនោះ។ អ៊ីចឹងការចែកក្រមានេះ មិនមែនជារឿងធម្មតា ដូចដែលយើងគិតទេ វាអាចជាបញ្ហា។ វាអាចជាការបែងចែក ដែលមានគោលបំណងមនុស្សធម៌ ឬក៏វាមានគោលបំណងផ្សេងទៀត ដើម្បីកំណត់មុខសញ្ញាអ្នកមកពីបូព៌ា។ ហើយគឺអាចជាការប្រព្រឹត្តឧក្រិដ្ឋកម្មទៅលើអ្នកបូព៌ាទាំងអស់នេះ។ បើអង្គជំនុំជម្រះមិនចង់ស្តាប់ភស្តុតាងហ្នឹងទេ អ៊ីចឹងខ្ញុំសួរវិញ ថាតើអង្គជំនុំជម្រះកោះហៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមកធ្វើអីនៅថ្ងៃនេះ?

ចំណុចចុងក្រោយ គឺតួនាទីរបស់ជនជាប់ចោទ ការចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួមរបស់គាត់នោះ វាមានភាពពាក់ព័ន្ធខ្លាំងណាស់។ ទោះបីជាអង្គហេតុឧក្រិដ្ឋដែលចោទប្រកាន់ហ្នឹង វានៅក្រៅវិសាលភាពនៅក្នុងសំណុំរឿង០០២/០២ក៏ដោយ ក៏ប៉ុន្តែនេះគឺជាការកំណត់អំពីតួនាទី និងការចូលរួម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចំណែកយ៉ាងសំខាន់របស់ជនជាប់ចោទ ក្នុងសហឧក្រិដ្ឋកម្មរួម។ ម្យ៉ាងវិញទៀត យើងបានស្ដាប់ចម្លើយសាក្សីជាច្រើននៅក្នុងសំណុំរឿង០០២/០២ អំពីតួនាទីរបស់ជនជាប់ចោទ។ ដូច្នេះវាមិនមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងទួលពោធិ៍ជ្រៃ ហើយនិងការជម្លៀសប្រជាជនដំណាក់កាលទី១, ទី២នោះទេ។ ឥឡូវនេះ ដើមបណ្ដឹងរដ្ឋប្បវេណីមកនិយាយអំពីតួនាទីរបស់ជនជាប់ចោទ ដូច្នេះខ្ញុំគិតថា វាមានភាពពាក់ព័ន្ធដែរ ទោះបីជាវាពាក់ព័ន្ធនឹងការជម្លៀសក៏ដោយ ក៏ប៉ុន្តែវាបង្ហាញអំពីតួនាទីរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងអ្នកជម្លៀសមកពីបូព៌ានោះ នៅពេលដែលគាត់ចែកក្រមា ស-ខៀវ ទៅឲ្យអ្នកទាំងអស់នោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:២៨:២៦]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណ។ លោកប្រធាន ខ្ញុំសូមឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ អ្វីដែលគាត់បានលើកឡើង<> ពិតណាស់ យើងអាចនិយាយពាក់ព័ន្ធនឹងការជម្លៀសប្រជាជន មិននៅក្នុងវិសាលភាពក៏ដោយ <ក៏ព្រះរាជអាជ្ញាអាចផ្ដល់នូវភស្តុតាង និងសួរសំណួរជាច្រើន។ ផ្ទុយទៅវិញ ជាក់ស្ដែងមេធាវីការពារក្ដី មិនមានឱកាសក្នុងការកោះហៅសាក្សីណាម្នាក់មកធ្វើសក្ខីកម្ម ឬដេញដោលលើភស្តុតារពាក់ព័ន្ធនឹងការចោទប្រកាន់នេះឡើយ>។ ហើយសហព្រះរាជអាជ្ញានិយាយថា <>អាច<ប្រើប្រាស់ធាតុផ្សំ> ទោះបីជានៅក្រៅវិសាលភាពក៏ដោយនោះ។ អ៊ីចឹងមេធាវីការពារក្ដីអត់មានបានត្រៀមខ្លួនទេ <ដោយហេតុថា មេធាវីការពារក្ដីមិនទាន់បានកោះហៅសាក្សី ព្រោះថារឿងនេះស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ>។ ក៏ប៉ុន្តែ<សម្រាប់លោក គឺថាអាចប្រើប្រាស់ធាតុផ្សំទាំងនេះបាន ដោយសារតែវាងាយស្រួលសម្រាប់លោកក្នុងការរកភស្តុតាដាក់បន្ទុកនោះ។ ដូច្នេះការព្យាយាមរកភស្តុតាងបន្ថែមប្រឆាំងនឹងលោក ខៀវ សំផន មានវិធានសាមញ្ញណាស់នៅក្នុងនីតិវិធី គឺថាមិនអនុញ្ញាតឲ្យគ្រប់ភាគីនិយាយអំពីអ្វី ដែលមិនមាននៅក្នុងដីកាដំណោះស្រាយ និងរឿងអ្វីដែលគ្មានវិសាលភាពក្នុងការជំនុំជម្រះនេះឡើយ។ ដោយ>ហេតុអី? ព្រោះថាមេធាវីការពារក្ដីអត់អាចមានលទ្ធភាពក្នុងការផ្ដល់ភស្តុតាងទៅលើចំណុចក្រៅអង្គហេតុទាំងអស់ហ្នឹងទេ។ <ឆ្លើយតបទៅនឹងសំណួរថា> ហេតុអីបានអង្គជំនុំជម្រះកោះយកគាត់មកហ្នឹង គឺគាត់បាននិយាយថា គាត់បានឃើញ ខៀវ សំផន <តែគាត់និយាយថា>គាត់<បាន>ឃើញ<លោក ខៀវ សំផន>ប្រហែលជា៥នាទីទេ<>។ អ៊ីចឹងវាអត់មានមូលដ្ឋានអីដែលសហព្រះរាជអាជ្ញារងនិយាយថា <>គាត់អាច<ផ្ដល់ព័ត៌>មាន <ឬ>ភស្តុតាង<នូវ>ហេតុការណ៍<ដែល

គាត់បានឃើញត្រឹមតែ៥នាទីឡើយ។ ប្រាកដណាស់គាត់មិនអាចដឹងពីអ្វីដែលបានកើតមានចំពោះអ្នកមកពីភូមិភាគបូព៌ា ដែលត្រូវគេជម្លៀសទៅកន្លែងផ្សេងឡើយ។>

<ជាថ្មីម្តងទៀត អង្គហេតុទាំងនេះ មិនមែននៅក្នុងវិសាលភាពនៃការជំនុំជម្រះឡើយ។> យើងតែងនិយាយថា មេធាវីការពារក្តីចង់ពន្យារពេលអ៊ីចឹង <ប៉ុន្តែការពិតទៅយើងកំពុងតែបាត់បង់ពេលវេលា លើអ្វីដែលមិនមានវិសាលភាពក្នុងការជំនុំជម្រះ> វាជាការរំលោភ<យ៉ាងធ្ងន់ធ្ងរមួយ>ទៅលើសិទ្ធិរបស់មេធាវី របស់ជនជាប់ចោទ។ យើង<កំពុងតែនិយាយគ្នាលើអ្វីដែលយើងសម្រេចថា នឹងមិននិយាយនៅក្នុងការជំនុំជម្រះនេះទៀតឡើយ> ។

[០៩:៣០:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំសុំការអនុញ្ញាតបន្ថែមការជំទាស់ទៅលើក្រុមរបស់ ខៀវ សំផន។ ខ្ញុំជឿជាក់ថា ស្ថានភាពរបស់សាក្សីរូបនេះ គឺមានលក្ខណៈប្រហែលគ្នាទៅនឹងសាក្សីម្នាក់កាលពីពីរសប្តាហ៍មុននេះ និយាយថា គាត់<ជាអ្នកមកពីភូមិភាគបូព៌ា ហើយក្រោយមកគេធ្វើបាបគាត់ ដែរឬទេនៅកំពង់ស្ពឺ>។ ហើយសហព្រះរាជអាជ្ញា គូមដែន ក៏បានសួរពីបញ្ហានេះ។ ហើយគាត់បានសួរសំណួរទូទៅតែមួយ ឬក៏ពីរសំណួរតែប៉ុណ្ណឹង។ អ៊ីចឹងឥឡូវនេះយើងកំពុងតែមានស្ថានភាពដូចគ្នាហើយ។ ទោះបីជាការសួរនេះ ទើបតែសួរបានមួយសំណួរពីរសំណួរក្តី ក៏គួរបញ្ឈប់ ព្រោះក្រៅវិសាលភាព។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើខ្ញុំយល់មិនច្រឡំទេ សហព្រះរាជអាជ្ញាគិតថា នេះគឺអ្វីដែលអាចកើតឡើងក្នុងពេលផ្លាស់ទីលំនៅប្រជាជន ដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ដែល<មិនដូចគ្នានឹងករណីខាងលើឡើយ>។ អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ វាវែងឆ្ងាយមកបន្តិចហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់អំពីមូលហេតុ។ ខ្ញុំដឹង<>គាត់សួរលម្អិតពាក់ព័ន្ធទៅនឹងអ្នកដែលបង់ក្រមាពណ៌ស-ខៀវនោះ។ អ៊ីចឹង<ហើយទើបខ្ញុំក្រោកឈរ>គាំទ្រទៅដល់ការជំទាស់ ប្រសិនណាជាការសួរនោះ សួរកម្រិតត្រឹមតែនៅផ្សារថ្មីនុ៎ង អ៊ីចឹងគឺមិនជាបញ្ហាអ្វីទេ អាចនឹងយល់គ្នាបាន។ ក៏ប៉ុន្តែបើសហព្រះរាជអាជ្ញារងចូលសួរសាក្សីនេះលម្អិត<ថាមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងនោះ> គឺថាវាហួសពីវិសាលភាពហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៣២:៥០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្តីជំទាស់ផ្នែកពាក់ព័ន្ធ ជាមួយនឹងរឿងអង្គហេតុដែលកើតមានឡើងនៅផ្សារថ្មី។ សហព្រះរាជអាជ្ញាអាចបន្តសំណួរចំណុចនេះបាន ដោយមិនមានភាពលម្អិតពាក់ព័ន្ធទៅនឹងអង្គហេតុនៃជម្លៀសដំណាក់កាលទី៣ទេ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន សំណួរដែលខ្ញុំសួរហ្នឹង គឺវាពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ ហើយចង់ដឹងថា នៅពេលដែលចែកក្រមា ស-ខៀវហ្នឹង គឺវាជាការចែកដើម្បីកំណត់មុខសញ្ញាសម្រាប់អ្នកជម្លៀសមក <ពី>បូព៌ា ឬក៏អត់។ ដូច្នេះវាពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿងយើងនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោក ខៀវ សំផន ចែកសម្លៀកបំពាក់ ហើយដែលក្នុងនោះមានក្រមា ស-ខៀវ និងស្បៀងទៅឱ្យអ្នកជម្លៀសមកពីបូព៌ាជិតផ្សារថ្មីនោះ លោកស្រីអាចជម្រាបបានទេថា គាត់ចែកឱ្យហ្នឹងទៅឱ្យមនុស្សប្រហែលប៉ុន្មាននាក់ដែរ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ដែលចែកសម្ភារៈនោះគឺគេឡើង ជម្លៀសឡើងមកច្រើនរាប់រយនាក់នោះ មិនមែនតិចទេ។ មកមួយវគ្គៗ។

[០៩:៣៤:២៦]

**ប្រធានអង្គជំនុំ៖**

សំណួរមិនអ៊ីចឹងទេ។ សំណួរសួរថា តើលោក ខៀវ សំផន ដែលលោកស្រីឃើញថា ខៀវ សំផន បែងចែកក្រមា ស-ខៀវ ឱ្យទៅពួកដែលទើបជម្លៀសពីមកពីបូព៌ានុំង ឱ្យចំនួនប្រហែលប៉ុន្មាននាក់ដែរ ដែលលោកស្រីឃើញលោក ខៀវ សំផន ហុចក្រមាឱ្យទៅអ្នកដែលទើបតែជម្លៀសពីបូព៌ាមកស្នាក់នៅបណ្តោះអាសន្ននៅផ្សារថ្មីនោះ? ចំនួន ៗសំខាន់គឺហុចឃើញ លោកស្រីឃើញថា ខៀវ សំផន ហុចឱ្យអ្នកទាំងនោះប៉ុន្មាននាក់ដែរ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ដែលខ្ញុំបានឃើញ ឃើញតែម្នាក់ តែគាត់ហុចតែម្នាក់ទេ គាត់ហុចតែមួយទេ ព្រោះគាត់លូកដៃមកសុំ ក៏គាត់នេះ លើកក្រមា ស-ខៀវ ហុចទៅតែយាយម្នាក់ទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំមិនសួរយល់លោកស្រី។ ពីមុននោះលោកស្រីថា មនុស្សរាប់រយនាក់ត្រូវបានជម្លៀសមកភ្នំពេញបណ្តោះអាសន្នហ្នឹង<បានទទួល>ស្បៀង <និង>សម្លៀកបំពាក់ ជាដើមហ្នឹង។ អ៊ីចឹងពេលដែលចែកហ្នឹង លោកស្រីឃើញគាត់ចែកឲ្យមនុស្សតែម្នាក់ទេ <ឬមនុស្សជាង១០០នាក់ហ្នឹងទទួលបានក្រមា និងម្ហូបអាហារនោះ>?

[០៩:៣៥:៥៣]

**ឆ៖** ចាស មនុស្សវាច្រើនពិតមែន ប៉ុន្តែគាត់បានទាញក្រមានោះ ហុចតែយាយម្នាក់នោះទេ តែគេអ្នកចែក គេចែកច្រើនគ្នា ក្រៅពីនោះ។ តាំងពីម្ហូបអាហារ តាំងពីសម្លៀកបំពាក់។ តែចំពោះ អ៊ំខៀវ សំផន គាត់ទាញក្រមាហុចទៅមួយនេះ ព្រោះអីគាត់លូកដៃមកសុំក្រមាមួយទៀត ក៏គាត់នេះ ទាញក្រមាហុចទៅគាត់ យាយនេះទៅ។ ខ្ញុំឃើញតែមួយនេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន យ៉ាងម៉េចទៅ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមខ្ញុំចាំបានពីម្សិលមិញ ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានឆ្លើយច្រើនជាងមួយដងទាក់ទងទៅនឹងចំនួនក្រមា ដែលលោក ខៀវ សំផន ហុចឲ្យ ដែលគាត់បញ្ជាក់ដដែលៗថា ឃើញលោក ខៀវ សំផន ហុចក្រមាមួយឲ្យទៅមនុស្សដែលនៅផ្សារថ្មីនោះ អ្នកដែលនៅផ្សារថ្មីនោះ។ គឺគាត់និយាយតែក្រមាមួយ ក្រមាមួយនេះដដែលៗច្រើនដង មិនមែនច្រើនទេ។ ដូច្នេះការសួរបន្ថែមទៅលើចំណុចនេះ វាជាការសួរច្រំដែល។ បាទ សូមអរគុណ។

[០៩:៣៧:១៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំចង់បំភ្លឺចំណុចមួយ នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ ឯកសារ E3/6425 ជាភាសាបារាំង 01152693, ជាភាសាអង់គ្លេស 01114154, ជាភាសាខ្មែរ 00544170។ លោកស្រីបានឆ្លើយ

ដូចតទៅ៖ "មុនពេលខ្មែរក្រហមចាប់ខ្លួនប្ដីរបស់ខ្ញុំ ខ្ញុំធ្លាប់ឃើញ ខៀវ សំផន ចូលមកម្ដុំផ្សារថ្មី ដើម្បីចែកអំណោយជូន ដូចជាក្រមា ស-ខៀវ សំពត់ ខោអាវ និងបាយកញ្ចប់ឲ្យប្រជាជនដែលបានជម្លៀសចេញមកពីទិសបូព៌ា មកកាន់ទីក្រុងភ្នំពេញបណ្ដោះអាសន្ន និងដែលបន្តជម្លៀសទៅកាន់ភូមិភាគពាយ័ព្យបន្តទៅទៀត នៅពេលខាងមុខ។" ដូច្នេះលោកស្រីដឹងដោយរបៀបណាថា ប្រជាជនដែលលោក ខៀវ សំផន ចែកក្រមា សម្លៀកបំពាក់ និងស្បៀងហ្នឹង គឺជាអ្នកដែលមកពីបូព៌ា ហើយដែលនឹងត្រូវជម្លៀសបន្តទៅកាន់ពាយ័ព្យនោះ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ដឹង ខ្ញុំដឹងដោយរបៀបណា ព្រោះអីខ្ញុំនៅបានចែកសម្ភារៈជាមួយនឹង ទីកដី ទីកន្លែងតំបន់នោះដែរ។ បានជាខ្ញុំដឹង ឃើញពិតនឹងភ្នែកខ្ញុំ។

[០៩:៣៨:៥៨]

**ស៖** បាទ លោកស្រីឃើញ ក៏ប៉ុន្តែអ្នកណាប្រាប់លោកស្រីថា ពួកគាត់ហ្នឹងមកពីបូព៌ា ហើយនិងត្រូវបញ្ជូនទៅពាយ័ព្យ? អ្នកជម្លៀសទាំងអស់ហ្នឹង ជាអ្នកប្រាប់លោកស្រីផ្ទាល់ថា ពួកគេមកពីបូព៌ា ឬក៏យ៉ាងម៉េច ឬក៏ប្ដីលោកស្រី <ឬអ្នកដទៃណា>ជាអ្នកប្រាប់?

**ឆ៖** ចាស បានជាដឹង ពួកប្រជាជន ពួកនោះឡើងមក ពួកខ្ញុំនេះសួរថា មកពីខាងណាដែរ? ថាពួកខ្ញុំឡើងមកពីខាងបូព៌ា គឺខាងព្រៃវែង។ បានជាខ្ញុំដឹងព័ត៌មានអីនោះ។

**ស៖** លោកស្រីឃើញមនុស្ស១០០នាក់ជាងហ្នឹង មកហ្នឹងគឺឃើញតែមួយក្រុមហ្នឹងទេ ឬក៏មានច្រើនក្រុមដែលមកពីព្រៃវែង ឬក៏មកពីស្វាយរៀង មកនៅក្បែរផ្សារថ្មីហ្នឹង?

**ឆ៖** ចាស ដែលខ្ញុំឃើញគឺ--

**ប្រធានអង្គជំនុំ៖**

បាទ កុំអាលទាន់! កុំអាលទាន់ចម្លើយ!

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ជាក់ស្ដែងណាស់ សំណួររបស់សហព្រះរាជអាជ្ញារង គឺពាក់ព័ន្ធនឹងការជម្លៀសប្រជាជន គឺគាត់សួរថា ពួកគាត់មកពីណា ទៅណា? គឺនៅក្រៅវិសាលភាពហើយ លោកប្រធាន ខ្ញុំសូមជំទាស់។

[០៩:៤០:២២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំគ្រាន់តែសង្កត់ធ្ងន់ទៅលើហេតុការណ៍ដែលលោក ខៀវ សំផន ចែក<សម្លៀកបំពាក់>ទៅឱ្យអ្នកជម្លៀសទាំងអស់នុ៎ង។

**កញ្ញា អង់តា ហ្គីសសេ៖**

គឺបញ្ហាហើយ លោកប្រធាន។ <>យើងមិនអាចនិយាយហេតុការណ៍ហ្នឹង ដោយមិនបង្ហាញពីបរិបទ <ឬអត្ថន័យ ដោយមិនមានភាពជាក់លាក់ស្ដីពី> ការជម្លៀសប្រជាជនដំណាក់កាលទី៣ហ្នឹង <បានទេ ម៉្យាងទៀតវាក៏មិនមែនជាអ្វីដែលយើងត្រូវសួរបញ្ជាក់ឡើយ>។ អ៊ីចឹងការសួរបែបហ្នឹង ធ្វើឱ្យមេធាវីការពារក្ដីពិបាកការពារក្ដីហើយ<>។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំគ្រាន់តែសួរបញ្ជាក់តែប៉ុណ្ណោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ហើយនិងដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ស្ថិតនៅក្នុងបញ្ជីសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីរបស់មេធាវីការពារក្ដី<ជាងពីរឆ្នាំកន្លះ>មកហើយ។ អ៊ីចឹងយើងដឹងហើយថា សំណើរបស់យើងខ្ញុំដើម្បីស្ដាប់បុគ្គលរូបនេះ គឺដើម្បីឱ្យគាត់មកផ្ដល់ព័ត៌មានលម្អិត អំពីតួនាទីរបស់ជនជាប់ចោទ។ ជាពិសេស ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនមកពីបូព៌ា ហើយនិងការចែកក្រមា។ អ៊ីចឹងដូចអត់មានអី<ចម្លែក>ទេសម្រាប់មេធាវីការពារក្ដី<ភ្ញាក់ផ្អើល>ពីការចូលរួមចំណែកនៅក្នុងសហឧក្រិដ្ឋកម្មរួម<នោះ>។ អ៊ីចឹងខ្ញុំគិតថាវានៅក្នុងវិសាលភាពនៃសំណុំរឿងយើងហើយ។ អ៊ីចឹងមេធាវីការពារក្ដី<គួរតែ>ជំទាស់<> មិនឱ្យ<កោះហៅ>គាត់មកផ្ដល់សក្ខីកម្មដែរ។

[០៩:៤១:៤៥]

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើយើងកាត់បន្ថយឱ្យខ្លីបន្តិចបានទេ ពីព្រោះថា ការជំទាស់នេះវែងឆ្ងាយណាស់។ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយតើ។ តើវាមានអ្វីខុសប្លែក ឬងាកចេញពីការសម្រេចរបស់អង្គជំនុំជម្រះអម្បាញ់មិញនេះ ឬក៏យ៉ាងម៉េច?

**កញ្ញា អង់តា ហ្គីសសេះ**

ក្នុងការសម្រេចរបស់លោកប្រធាននោះ<>មិនឲ្យសួរលម្អិតពីការជម្លៀសប្រជាជនដំណាក់កាលទី៣ទេ។ សហព្រះរាជអាជ្ញាសួរហ្នឹង គឺសួរលម្អិតពាក់ព័ន្ធនឹងការជម្លៀសដំណាក់កាលទី៣ហើយលោកប្រធាន។

**លោក វាំងសង់ វ៉ាយឌ័ ដេស្សាឯលៈ**

ខ្ញុំមិនដឹងថា<លោកប្រធានមានការសម្រេចចិត្ត យ៉ាងដូចម្ដេចទេ។ តើខ្ញុំអាចបន្តទៀតបានទេលោកប្រធាន?>

[០៩:៤២:៤០]

**ប្រធានអង្គជំនុំ៖**

ឥឡូវអ៊ីចេះ និយាយឲ្យច្បាស់លាស់។ យើងទាំងអស់គ្នា យើងនិយាយឡើងវិញ ហើយរួមទាំងភាគីដែលមិនបានចូលរួមផង ជាពិសេសតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ហើយ យើងបានបញ្ជាក់ម្ដងហើយ។ យើងបានកំណត់អំពីសាក្សីមកសួរអង្គហេតុតួនាទីរបស់ជនជាប់ចោទ។ អ៊ីចឹងការកំណត់របៀបនេះ មានន័យថា អង្គហេតុ សាក្សីនេះគឺជាសំណួរចម្បង។ អង្គហេតុពាក់ព័ន្ធជាមួយនឹងតួនាទីរបស់ជនជាប់ចោទ។ ចំណែកឯអង្គហេតុផ្សេងទៀត វាជាសំណួរបន្ទាប់បន្សំ ដែលយើងមិនអាចកាត់ផ្ដាច់បាន។ បើយើងផ្ដាច់ជាកង់ៗ ស្ដាប់វាមិនយល់ តែប៉ុណ្ណឹងទេ។ មិនមែនឲ្យយកតួនាទីរបស់ជនជាប់ចោទ ហើយសួរទៅលាតសន្ធឹង ដូចករណីទូទៅទេ។ បើដូច្នោះយើងមិនបាច់កំណត់ជាក់លាក់អំពីថាសាក្សីណាដែលយកមកស្ដាប់អង្គហេតុណា ជាមូលដ្ឋានចម្បង ជាសារវន្តនោះទេ។ អ៊ីចឹងហើយយើងបានខំបែងចែកនេះ គឺឲ្យដឹងថា សាក្សីណា ដើមបណ្ដឹងរដ្ឋប្បវេណីណា សំខាន់ពាក់ព័ន្ធនឹងអង្គហេតុណា។ ចំណែកឯសាក្សីទូទៅ យល់ដឹងទូទៅ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកជំនាញយល់ដឹងទូទៅយើងបើកទូលាយឲ្យភាគីសួរដេញដោលគ្រប់បញ្ហាទាំងអស់។

ដូច្នេះគួរតែកំហិតនូវព្រំដែននៃសំណួររបស់ខ្លួន ឲ្យសមស្របទៅតាមអង្គហេតុដែលយើងបានកំណត់ធ្វើសវនាការនីមួយៗ។ ហើយគួរតែជៀសវាងកុំចំណាយពេល ដោយសារមូលហេតុពេលវេលាដែលអង្គជំនុំជម្រះចែកទៅ គ្រាន់តែជាការប្រមើលមើលទេ បើសិនជាខ្វះគឺថែមទៀត បើចាំបាច់។ ប៉ុន្តែបើសិនជាមិនចាំបាច់ទេ គឺនៅសល់ពេល ក៏បន្តទៅសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតដែរ។

អញ្ជើញតទៀត!

[០៩:៤៤:៤០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ដូច្នេះខ្ញុំសូមចូលទៅប្រធានបទថ្មី ក៏ប៉ុន្តែមុនចូលទៅប្រធានបទថ្មី ខ្ញុំសូមបញ្ជាក់ដើម្បីជាកំណត់ត្រាប្រតិចារឹក គឺមានឯកសារបី <ដែលខ្ញុំមិនអាចអានបានទេ គឺ> E3/5542, E3/7708 និង E3/3970 ដែលនិយាយអំពីជោគវាសនារបស់អ្នកដែលទទួលបានក្រមាខៀវទាំងអស់នេះ<>។ អ៊ីចឹងឥឡូវលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំចូលទៅប្រធានបទថ្មី គឺនិយាយអំពីការចាប់ខ្លួនប្តីលោកស្រី គឺឈ្មោះ <គង់ ជឺ ហៅ>ជឿន។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ ថាតើប្តីរបស់លោកស្រីត្រូវបានចាប់ខ្លួននៅពេលណា? ប្រហែលជាប៉ុន្មានខែ ឬប៉ុន្មានឆ្នាំមុនពេលវៀតណាមវាយយកទីក្រុងភ្នំពេញ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ប្តីខ្ញុំដែលនៅនឹងទីកន្លែងផ្សាររដ្ឋនោះ ក៏នៅជាមួយនឹងខ្ញុំដែរ ដែលពេលគេចាប់ខ្លួនយកទៅ គឺបើខ្ញុំអង្កាល់នោះ វាមិនចាំ តែនេះគឺមានភស្តុតាងឯកសារនេះ នៅក្នុងខែ១២ ថ្ងៃទី១១។ ថាថ្ងៃ -- ខែទី១០ អ៎ ទី១២ គឺខ្ញុំមិនបានចាំច្បាស់ទេដែរ ប៉ុន្តែថ្ងៃមួយនោះ គឺគេចាប់ទៅ មានគ្នាបីនាក់។ ឈ្មោះប្តីខ្ញុំហ្នឹងឈ្មោះ គង់ ជឺ ហៅ ជឿន តែឈ្មោះមួយទៀត ហៅ យ៉េ, រុន ទៅទាំងបីនាក់នេះឯង។ នេះបានឃើញឯកសារនៅលើកន្លែងនេះ ខ្ញុំទើបនឹងឃើញច្បាស់នេះឯង។

[០៩:៤៦:៥៩]

**ស៖** បញ្ជីហ្នឹងគឺមេធាវី ហ្គីរ៉ូដ៍ បានផ្តល់ឲ្យលោកស្រីកាលពីម្សិលមិញគឺ E3/10454 ដែលបញ្ជាក់ថា ប្តីរបស់លោកស្រីចូល ស-២១ នៅថ្ងៃទី១១ ធ្នូ ៧៨ ហើយត្រូវបានសម្លាប់ចោលនៅថ្ងៃទី១៤ ធ្នូ។ នៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោកស្រី ទោះបីជាលោកស្រីមិនចាំអំពីកាលបរិច្ឆេទក៏ដោយ ក៏ប៉ុន្តែក្នុងនេះ គឺបញ្ជាក់អំពីខែតុលា ឆ្នាំ៧៨ គឺជាពេលដែលលោកស្រី ប្តីលោកស្រីបាត់ខ្លួន។ គឺឯកសារ E3/6425a ជាភាសាអង់គ្លេស 01069300, ជាភាសាខ្មែរ 00581519 និងជាភាសាបារាំង 01151395។ នេះជាអ្វីដែលបានសរសេរនៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោកស្រី។ ខ្ញុំសូមដកស្រង់៖ “តែក្រោយមកអង្គការចាប់ប្តីនាងខ្ញុំនៅខែតុលា ឆ្នាំ១៩៧៨។ អង្គការចាប់គាត់ដាក់ឡានបាត់ មិនដឹងយកទៅទីណានោះទេ។ នាងខ្ញុំមិនបានដឹងពីមូលហេតុអ្វីទេ។ តាមនាងខ្ញុំដឹងថា ពេលនោះអង្គការស្រាវជ្រាវចាប់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្នកធំជាបន្តបន្ទាប់ ជាប្រព័ន្ធតែម្តង។” ដូច្នេះខ្ញុំចង់ដឹងថា តាមរយៈការដឹងឮរបស់លោកស្រី ទោះបីជាឆ្នាំ៧៩ ក៏ដោយនោះ ថាតើប្តីរបស់លោកស្រីត្រូវបានឃុំខ្លួន និង អប់រំនៅកន្លែងណាផ្សេងសិនទេ មុននឹងបញ្ជូនទៅស-២១នោះ?

**ឆ៖** ចាស ខ្ញុំអត់មានបានដឹងដំណឹងអីសោះ ទាល់តែបាត់សូន្យ ទាល់តែឃើញឯកសារនេះតែម្តង។

**ស៖** តើឈ្មោះ រ៉េត នេះមានបាននិយាយអំពីជោគវាសនាប្តីរបស់លោកស្រី ប្រាប់លោកស្រីនៅក្រោយឆ្នាំ៧៩ទេ?

[០៩:៤៩:១៧]

**ឆ៖** ចាស ក្រោយឆ្នាំ៧៩ ក្នុងវេលាឆ្នាំនោះ គឺចូលឆ្នាំ៨០គត់ ខ្ញុំស្រុកស្រែនេះ វាអត់កើតស្រូវកើតអង្ករ ខ្ញុំបររទេះគោនោះ ទៅរកស្រូវនៅទឹកដីខេត្តសៀមរាប។ តែជួប ដែលធ្លាប់ស្គាល់គ្នាពីមុនមកនេះ ក៏គាត់សាកសួរសុខទុក្ខហើយ ខ្ញុំបានសួរពីដំណឹងប្តីខ្ញុំ។ តែសួរទៅក៏គាត់ថា ស្មានដែរ បើប្តីមិត្តឯងមានតែគេដាក់ស្អី! ព្រៃស និងមន្ទីរស-២១ នេះឯង។ តែគាត់ គាត់ថា ព្រោះវាបាត់ហើយ គ្មានទៅណាទេនៅជិតៗហ្នឹងដែរ ក៏ខ្ញុំបានដឹងដំណឹងពីឈ្មោះ រ៉េត នៅខេត្តសៀមរាបនោះហើយទេ មកទល់ឥឡូវនេះ។

**ស៖** កាលពីម្សិលមិញ លោកស្រីបាននិយាយថា មនុស្សបីនាក់ គឺខ្មែរក្រហមបីនាក់ មកនាំប្តីលោកស្រីទៅ។ លោកស្រីដឹងថា អ្នកទាំងបីហ្នឹងមកពីអង្គភាពណាទេ?

**ឆ៖** ខ្ញុំនិយាយថា មានគ្នាបីនាក់ និងប្តីខ្ញុំ, ឈ្មោះ យ៉េ ឈ្មោះ រុន ហ្នឹងទេ តែបានឃើញ ពីព្រោះអ្នកដែលយកប្តីខ្ញុំទៅ ខ្ញុំមិនបានឃើញទេ ព្រោះខ្ញុំនៅនឹងចង្ក្រានធ្វើម្ហូប។ តែប្តីខ្ញុំក៏នៅជ្រុងម្ខាងនឹងទីកន្លែងគេ ខាងការងារគេទៅ។ តែដឹង ដឹងនឹងកូនខ្ញុំ។ កូនខ្ញុំវាអាយុ៣ឆ្នាំទៅហើយ វានៅលេងជាមួយឪពុកវា។ ដល់ពេលបាត់ឪពុកទៅ ខ្ញុំសួរ ថាមានតាៗបីនាក់ ហៅពុកដាក់ឡានជាមួយ ពូរុន, ពូយ៉េ និងឪពុកនេះឯង។ ខ្ញុំបានដឹងដំណឹងនឹងកូនខ្ញុំនេះទេ។

**ស៖** ខ្ញុំដឹងថា ទម្រង់ព័ត៌មានជនរងគ្រោះហ្នឹង មិនអាចទុកចិត្តបាន១០០ភាគរយទេ។ <ខ្ញុំសំដៅលើ>កម្មាភិបាលមកពីមន្ទីរ ក-៧។ លោកស្រីដឹងទេ មន្ទីរ ក-៧ហ្នឹង ជាមន្ទីរអីដែរ?

**ឆ៖** ចាស ខ្ញុំមិនបានដឹងទេ មន្ទីរ ក-៧នេះ។ គ្រាន់តែឮ ដូចថា នៅក្នុងក្រសួងនេះនិយាយថាមន្ទីរ ក-៧ៗនេះ ប៉ុន្តែមិនដឹងនៅត្រង់ណា ទីកន្លែងណាទេ គ្រាន់តែថា នៅក្នុងនោះហើយ ក៏មានការនិយាយគ្នា ក៏ឮតែថាអ៊ីចឹងដែរទេ ខ្ញុំអត់បានដឹងនៅត្រង់ណាទេ។

[០៩:៥២:២១]

**សៈ** លោកស្រីបាននិយាយពីមិត្តភក្តិពីរនាក់របស់ប្ដីលោកស្រី ដែលគេយកចេញទៅជាមួយគ្នានឹងប្ដីលោកស្រីគឺ វុន និង កង យ៉េ។ បើអ្នកទាំងពីរហ្នឹងមានប្រពន្ធនោះ លោកស្រីស្គាល់ប្រពន្ធរបស់ យ៉េ ហើយនិង វុន ហ្នឹងទេ?

**ឆៈ** ចំណែក វុន អត់ទាន់មានគ្រួសារទេ។ បើ បងយ៉េ នោះមានហើយ ឈ្មោះ ណាត តែឈ្មោះដើមគេ ដឹងឈ្មោះអីទេ ប៉ុន្តែនៅក្នុងក្រុមជាមួយគ្នានេះ ឈ្មោះ ណាត។

**សៈ** ប្រពន្ធរបស់ យ៉េ ហ្នឹងឈ្មោះ ណាត ហ្នឹង គេយកចេញទៅក្នុងពេលតែមួយជាមួយគ្នាជាមួយនឹងលោកស្រី ឬក៏អត់ទេ គាត់នៅកន្លែងហ្នឹងដដែល ពេលលោកស្រីចេញទៅហ្នឹង?

**ឆៈ** ចាស ដល់ពេលគេឱ្យខ្ញុំ ពួកខ្ញុំចេញទៅ ប្រពន្ធ យ៉េ នោះឯង ដែលឈ្មោះ ណាត នេះចេញទៅថ្ងៃជាមួយខ្ញុំនេះឯង។

**សៈ** តើមានស្ត្រីច្រើនទេ ពេលដែលគេនាំទៅជាមួយលោកស្រីទៅវត្តនោះ?

**ឆៈ** ចាស ស្ត្រីប្រហែលជាប្អូនប្រាំ ប្រាំមួយមួយនាក់ទេ ព្រោះវាកាលនោះខ្ញុំភ្លេចដែរ វាយូរយារហើយ ប៉ុន្តែមានស្ត្រី។ តែបុរស គឺមានតែម្នាក់ទេ ឈ្មោះ ហំ មិនដឹងនៅខេត្តណាទីណាដែរទេ មិនសូវដឹង ជំនាន់នោះមិនបានដឹងថា នេះគ្រាន់ថានៅក្រុមជាមួយគ្នា ក៏ចេះតែស្គាល់គ្នា ដូចតាមឈ្មោះរៀងខ្លួនៗប៉ុណ្ណោះឯងទេ។

**សៈ** ស្ត្រីទាំងអស់ដែលគេនាំតាមឡានយកទៅហ្នឹង សុទ្ធតែជាប្រពន្ធដែលរបស់ប្ដី ដែលគេត្រូវបាននាំចេញមុនហើយមែនទេ?

**ឆៈ** ចាស ស្ត្រីដែលទៅជាមួយខ្ញុំនោះ គឺមានប្ដីជា នាំទៅមុនខ្លះ និងគេអ្នកមានប្ដីនៅជាមួយខ្លះ។

[០៩:៥៥:១៧]

**សៈ** ខ្ញុំមានសំណួរមួយទៀត ពាក់ព័ន្ធនឹងទិសដៅរបស់លោកស្រី។ លោកស្រីនិយាយអំពីវត្តជ័យឧត្តម។ លោកស្រីដឹងទេថា វត្តហ្នឹងចំណុះឲ្យមន្ទីរ <>៨៧០មែនទេ?

**ឆៈ** ចាស វត្តជ័យ--

**ប្រធានអង្គជំនុំៈ**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់ឆ្លើយ!

សុំអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់ទៅនឹងរបៀបនៃការសួរសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិ លោកប្រធាន។ ដើមបណ្ដឹងរដ្ឋប្បវេណី គាត់និយាយអំពី "ក្រសួង៨៧០" គាត់មិនដែលប្រើពាក្យថា "មន្ទីរ <៨៧០>" ទេ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសុំរៀបចំសំណួរឡើងវិញ។ លោកស្រីដឹងទេថា វត្តជ័យឧត្ដមដែលលោកស្រីធ្វើការ <ទៅច្រូតស្រូវ>ហ្នឹងស្ថិតនៅក្រោមបង្គាប់របស់ក្រសួង៨៧០មែនទេ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ដែលពួកខ្ញុំចេញដំណើរទៅនេះ នៅវត្តជ័យឧត្ដមនេះ គ្រាន់តែដឹងថា ទីកន្លែងវត្តជ័យឧត្ដមទេ តែត្រង់ក្រសួង ឬកន្លែងអី គេហៅអី ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំចេញដំណើរទៅ គេឲ្យនៅ ទៅច្រូតស្រូវកន្លែងនោះឯង។

[០៩:៥៦:៥០]

**ស៖** កាលពីម្សិលមិញលោកស្រីបានឃើញឯកសារមួយគឺ <E3/10454>។ ខ្ញុំមានឯកសារមួយទៀត គឺមកពីមន្ទីរស-២១ គឺឯកសារ E3/1974 ជាបញ្ជីសួរចម្លើយនៅស-២១។ ទំព័រពាក់ព័ន្ធជាភាសាបារាំងគឺ ERN 00884077, ជាភាសាអង់គ្លេសគឺ 00184007 ទៅដល់08, ជាភាសាខ្មែរ 00052897។ លោកប្រធាន ខ្ញុំសុំការអនុញ្ញាតប្រគល់ឯកសារនេះជូនទៅដើមបណ្ដឹងរដ្ឋប្បវេណី គឺប្រហែលជាមានឈ្មោះប្ដីរបស់គាត់ និងអ្នកពីរនាក់ទៀតដែលគេនាំទៅជាមួយគ្នានោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ក្នុងនេះមានឈ្មោះបួនដែលនៅក្នុងផ្នែកសេដ្ឋកិច្ចរដ្ឋ។ ទី១ ឈ្មោះ ឃី ប៉េងលី ហៅ អាន អាយុ២៣ ភេទប្រុស នីរសារសេដ្ឋកិច្ចរដ្ឋ ០២ ខែវិច្ឆិកា ឆ្នាំ៧៨ ប្រហែលជាថ្ងៃចូលស-២១ហើយមើលទៅ។ ខ្ញុំសុំផ្អាកអានបញ្ជីហ្នឹងសិន ហើយសុំសួរលោកស្រីថា នៅសម័យនោះ លោកស្រីស្គាល់ឈ្មោះនៅលេខរៀងទី១ហ្នឹងទេ ដែលឈ្មោះ ឃី ប៉េងលី ហៅ អាន ជានីរសារផ្នែកសេដ្ឋកិច្ចរដ្ឋ? លោកស្រីស្គាល់ឈ្មោះហ្នឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ខៀវ នាបៈ**

**ឆៈ** ចាស នាងខ្ញុំអត់ស្គាល់ទេ ឈ្មោះនេះឯង។

[០៩:៥៩:២១]

**សៈ** ខ្ញុំនឹងអានឈ្មោះបីទៀត ដែលមាននៅក្នុងបញ្ជីផ្សេងទៀត ដែលគេបានផ្ដល់ជូនលោកស្រី កាលពីម្សិលមិញគឺ កង យ៉េ អាយុ២៦ ភេទប្រុស យុទ្ធជនផ្គត់ផ្គង់ផ្សាររដ្ឋ ១១ ធូ ៧៨។ បន្ទាប់មកទៀត មានឈ្មោះ គង់ ជី ហៅ ជឿន, កង ជី ឬ កង ជី។ ហើយអាយុហ្នឹង គឺដូចជាមើលមិនដាច់ទេ ហើយជាភាសាបារាំង គេបកទៅ ប្រហែលជា៣៥ឆ្នាំ។ អង់គ្លេសក៏អ៊ីចឹងដែរ។ ភេទប្រុស យុទ្ធជនផ្គត់ផ្គង់ផ្សាររដ្ឋ ១១ ធូ ៧៨។ ឈ្មោះមួយទៀតគឺ ធូ លាក់ ហៅ រុន អាយុ២៤ឆ្នាំ ភេទប្រុស យុទ្ធជន ផ្គត់ផ្គង់ផ្សាររដ្ឋ ១១ ធូ ៧៨។ លោកស្រីអាចបញ្ជាក់បានទេ ថាអ្នកទាំងបីហ្នឹង គឺប្ដីលោកស្រី ហើយនិងមិត្តភក្ដិរបស់គាត់ទាំងពីរនាក់ដែលគេនាំទៅថ្ងៃតែមួយ ជាមួយគ្នាហ្នឹង មែនទេ?

**ឆៈ** ចាស ខ្ញុំសូមឆ្លើយ តែ គង់ យ៉េ គឺមិត្តភក្ដិប្ដីខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! កុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមការបញ្ជាក់ជាក់ស្ដែង គឺឯកសារនេះ នៅពេលដែលព្រះរាជអាជ្ញារងបានបង្ហាញហ្នឹង មិនទាន់ -- ដើមបណ្ដឹងរដ្ឋប្បវេណីមិនទាន់កត់សម្គាល់ថា ឈ្មោះមួយណាជាប្ដីរបស់គាត់ទេ ហើយក៏មិនទាន់និយាយថា មានប្ដីរបស់គាត់នៅក្នុងនេះដែរ ព្រោះមានចំណុចខុសគ្នាផង។ ហើយប៉ុន្តែព្រះរាជអាជ្ញារង គាត់បានបញ្ជាក់ថា ប្ដីរបស់គាត់រួចទៅហើយ។ ដូច្នេះជាការសន្និដ្ឋានមុនរបស់ព្រះរាជអាជ្ញារង ដែលជាការផ្ដល់តម្រុយទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអរគុណ ដូច្នេះខ្ញុំសូមជំទាស់ចំពោះការសួរបែបនេះ។

[១០:០១:៥២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន ខ្ញុំដូចជាមិនគិតដូចគាត់ទេ។ ខ្ញុំសួរដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីចង់ដឹង ព្រោះថាឈ្មោះហ្នឹង គឺដូចឈ្មោះដែលយើងបានឃើញកាលពីម្សិលមិញ ឈ្មោះទាំងបីហ្នឹង។ អ៊ីចឹងខ្ញុំសួរអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹង អ្នកទាំងបីហ្នឹងគឺមនុស្សដដែលហ្នឹង មែនទេ។ គឺក្នុងនុ៎ងប្រហែលជាអាចមានប្ដីគាត់ដែរ បើសិនជាគាត់ឃើញប្ដីគាត់ គាត់ប្រាប់ទៅ។

**លោក គង់ សំអុន៖**

លោកប្រធាន ដោយសារឯកសារនេះ វាមានលក្ខណៈខុសគ្នា ហើយមានការឆ្វេតលុបនៅលើនេះទៀត។ ហើយម្យ៉ាង ទាក់ទងទៅនឹងអាយុ ក៏មានលក្ខណៈខុសគ្នា ពីការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីកាលពីម្សិលមិញ ដែលគាត់បញ្ជាក់ថា ប្ដីគាត់មានអាយុ២៥ឆ្នាំ នៅពេលបាត់ខ្លួននោះ។ ហើយនៅក្នុងនេះ បញ្ជាក់ពីអាយុ៣៥ឆ្នាំ។ ដូច្នេះវាមានកំហុស ចំណុចខុសគ្នា។

**ប្រធានអង្គជំនុំ៖**

សួរបញ្ជាក់សិនទៅ ហើយគាត់ស្គាល់ឈ្មោះហ្នឹងទេ អត្តសញ្ញាណដែលបញ្ជាក់ហ្នឹង ហើយស្គាល់ដែរទេ។ បើថាគាត់ឆ្លើយថាស្គាល់ ហើយសុំសួរថា អ្នកណាគេ អ្នកហ្នឹង អ្នកណាគេ។ អាហ្នឹងបើសួរតាមហូរហែអ៊ីចឹងទៅ វានឹងអាចមានភាពច្បាស់លាស់ហើយ។ ហើយបើសួរទៅ គាត់អត់ស្គាល់ផងមានសួរអីទៀត។ បើគាត់អត់ស្គាល់ផង។

សំណួរឡើងវិញ រៀបឲ្យបានខ្លីៗចុះ ដើម្បីឲ្យគាត់យល់បាន។ ហើយបើមានខុសគ្នាអំពីអាយុ ត្រូវសួរបញ្ជាក់អំពីអាយុ ម៉េចក៏ខុសគ្នា។ កាលៈទេសៈ ប្រហាក់ប្រហែលគ្នា អាយុខុសគ្នាដល់១០ឆ្នាំ។

[១០:០៣:៣៦]

**លោក វ៉ាំងសង់ វ៉ាយដ៏ ដេស្បាឯល៖**

បើយើងពិនិត្យមើលឯកសារជាភាសាខ្មែរហ្នឹង យើងមិនប្រាកដថា “២” ឬក៏ “៣” ទេ អាយុហ្នឹង លេខ២៥ ឬក៏៣៥នោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៏ ដេស្បាឯល៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងឯកសារនេះ មានឈ្មោះ គង់ ជី ហៅ ជឿន យុទ្ធជន ផ្គត់ផ្គង់ផ្សាររដ្ឋ ១១ ធ្នូ ៧៨។ ឈ្មោះហ្នឹង លេខរៀងទី៣ហ្នឹង លោកស្រី ជាប្ដីលោកស្រី មែនទេ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ខ្ញុំសូមឆ្លើយថា ខ្ញុំឡើងមកបកសក្ខីកម្មនេះ ខ្ញុំសូមស្បថជាមួយលោកតាដំបងដែក ពិតជាប្ដីរបស់ខ្ញុំ។ ហើយឈ្មោះ រុន នេះក៏ជាមិត្តភក្តិនៅជាមួយនឹងប្ដីខ្ញុំដែរ។ ខ្ញុំស្គាល់ពិតប្រាកដ ទាំងពីរនាក់ជាមួយប្ដីខ្ញុំ បីនាក់នេះ។

**ស៖** បាទ មុននេះលោកស្រីនិយាយអំពីឈ្មោះ វុយ ដែលជាប្រធានប្ដីលោកស្រី។ ខ្ញុំចង់បង្ហាញឯកសារមួយជូនលោកស្រី។ ជាបញ្ជីមនុស្សដែលសួរចម្លើយនៅស-២១ គឺ E3/2178។ ជាភាសាខ្មែរ 00021091, ជាភាសាអង់គ្លេស 00631981, ជាភាសាបារាំងគឺ 00631977។ ឯកសារនេះពិបាកមើលបន្តិច អ៊ីចឹងដើម្បីចំណេញពេល ខ្ញុំសូមអានការបកប្រែជាបញ្ជីអ្នកសួរចម្លើយនៅស-២១។ ក្នុងនោះមានឈ្មោះ៦៦ឈ្មោះ ហើយអ្នកខ្លះគេមានដាក់ថ្ងៃខែឆ្នាំកម្ទេចចោល ហើយអ្នកខ្លះទៀត គឺនៅសួរចម្លើយនៅឡើយ។ នៅលើបញ្ជីនេះ មានឈ្មោះ សូ ស៊ូ ហៅ វុយ អាយុ២៩ឆ្នាំ ភេទប្រុស ប្រធានមន្ទីរផ្គត់ផ្គង់រដ្ឋ៨៧០ ថ្ងៃចូលស-២១ ២៤ ឧសភា ៧៨។ ខ្ញុំសូមបញ្ជាក់ថា នៅក្នុងជាភាសាអង់គ្លេស គឺ<និងសំណៅដើមជាភាសាខ្មែរ>លេខរៀងទី៥១ ក៏ប៉ុន្តែ<>ជាភាសាបារាំងនោះ អត់មានលេខរៀងទេ។ ដូច្នេះពាក់ព័ន្ធនឹងឈ្មោះ វុយ អាយុ២៩ឆ្នាំ ភេទប្រុស មុខនាទី ប្រធានមន្ទីរផ្គត់ផ្គង់រដ្ឋ៨៧០នេះ ដែលគេចាប់ខ្លួនដែរហ្នឹង គឺជាឈ្មោះ វុយ ដែលជាប្រធានប្ដីលោកស្រីហ្នឹងមែនទេ?

[១០:០៧:០៨]

**ផ៖** ចាស ពិតមែនហើយ។

**ស៖** នៅសម័យនោះ លោកស្រីដឹងទេថា ក្នុងកាលៈទេសៈបែបណាដែល វុយ នេះបាត់ខ្លួន?

**ផ៖** ចាស គឺអត់ដឹងដែរ ព្រោះដូចថា នៅនឹងទីកន្លែងនោះ ហូបបាយរួមគ្នាពិត តែដល់ពេលគាត់បាត់ខ្លួន ខ្ញុំអត់ដឹងទេ។ ស្រាប់តែបាត់គាត់នោះ បាត់ទៅបណ្ដោយ។

**ស៖** លោកស្រីដឹងថា អ្នកណាមកជំនួស វុយ ហ្នឹងជាប្រធានមន្ទីរផ្គត់ផ្គង់រដ្ឋហ្នឹង?

**ផ៖** ចាស ផុតពីនោះទៅ ក៏ដូចថាគ្មានអ្នកណាផ្គត់ផ្គង់ទៀតទេ ខ្លាចតែពីឯណាផ្សេងខាងទៀតដឹង បើទៅទីកន្លែង គឺចេះតែរប៉ាត់រប៉ុយ រប៉ាត់រប៉ុយ ក៏អស់ ត្រឹមពួកខ្ញុំចេញដែរទៅ ក៏មិនដឹងជាពីណាក្ដោបក្ដាប់លើពីណាដែរ អត់ដឹងដែរ។

**ស៖** នៅសម័យនោះ លោកស្រីមានធ្លាប់ស្គាល់ឈ្មោះកម្មាភិបាលមួយទៀត ឈ្មោះ សៅ គឺឈ្មោះពេញរបស់គាត់ សំរិត សួស ហៅ សៅ សម័យនោះគាត់មានអាយុ២៨ឆ្នាំ លោកស្រីធ្លាប់ស្គាល់ឈ្មោះហ្នឹងទេ?

**ផ៖** ចាស ខ្ញុំមិនស្គាល់ទេ ព្រោះអីវាច្រើន ខ្ញុំអត់ស្គាល់គេទេ។

**ស៖** នៅចន្លោះពេលលោកស្រីមកដល់ទីក្រុងភ្នំពេញ ដែលលោកស្រីធ្វើការជាចុងភៅនៅចូលឆ្នាំខ្មែរ នៅឆ្នាំ១៩៧៨ ហើយនិងពេលដែលលោកស្រី ហើយនិងប្ដីលោកស្រីត្រូវបាននាំចេញទៅនុំង តើ

មានកម្មាភិបាល ឬយុទ្ធជនណាផ្សេងទៀត នៅក្នុងអង្គភាពចុងភៅ ឬអង្គភាពផ្គត់ផ្គង់រដ្ឋរបស់ប្តីលោកស្រី ដែលត្រូវបានបាត់ខ្លួនទេ ក្រៅពី វុយ?

[១០:០៩:៥១]

**ឆ៖** ចាស ខ្ញុំអត់មានដឹងទេ ព្រោះខ្ញុំចេញផុតហើយ មិនដឹងជាអ្នកណាក្តោបក្តាប់អ្នកណាទេ។ ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំនឹងសួរសំណួរឡើងវិញ ប្រហែលជាស្មុគស្មាញបន្តិច។ ខ្ញុំចង់ដឹងថា ចន្លោះពីខែមេសា ឆ្នាំ៧៨ ហើយនិងពេលគេដាក់លោកស្រីលើឡាននាំទៅវត្ត ទៅដាំស្រូវនោះ ទៅធ្វើស្រែហ្នឹង ចន្លោះពេលហ្នឹង ខ្ញុំចង់ដឹងថា មានអ្នកណាបាត់ខ្លួនទេ នៅក្នុងអង្គភាពលោកស្រី ឬក៏នៅក្នុងអង្គភាពប្តីលោកស្រីក៏ដោយ លោកស្រីដឹងព័ត៌មានហ្នឹងទេ?

**ឆ៖** ចាស ដែលគេដាក់ឡានខ្ញុំយកទៅកន្លែងធ្វើស្រែ ច្រូតស្រូវនោះ ក៏ខ្ញុំអត់មានដឹងដែរ ព្រោះថាមនុស្សវាច្រើននាក់ខ្លាំងណាស់។ ដូចថា ម្នាក់ៗខិតខំគិតរិះរកតែខ្លួនឯង អ្នកណាបាត់ខ្លួន ក៏មិនដឹង អ្នកណាទៅណា ក៏ខ្ញុំអត់ដឹងដែរ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន យើងខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនៅថ្ងៃនេះ យើងមានបញ្ហាបន្តិច ដើម្បីចង់ពិគ្រោះជាមួយនឹងភាគី សួរដំបូងសួរខាងភាគីខាងអយ្យការ ខាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខមុន។ ហើយតាមល្បឿននៃកិច្ចដំណើរការសវនាការនៅសប្តាហ៍នេះ យើងឃើញថា សវនាការនៅថ្ងៃស្អែកហ្នឹង អាចនឹងចប់យ៉ាងយូរ គឺនៅពេលមួយព្រឹក ហើយយើងនៅសល់ពេលរសៀលថ្ងៃស្អែក។ ហើយតែដោយសាក្សីដែលយើងកំណត់កាលវិភាគសវនាការសម្រាប់សក្ខីកម្មនៅថ្ងៃចន្ទ និងថ្ងៃអង្គារ សប្តាហ៍ក្រោយគឺ 2-TCW-1060 និង 2-TCW-920 នោះ គឺគាត់មានធុរៈ មិនអាចចូលមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកបាន។ ហើយសាក្សីដែលមានលទ្ធភាពមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកបានគឺ 2-TCW-1069។ ហើយសាក្សីនេះជាសាក្សីដែលស្នើឡើងដោយមេធាវីការពារក្តី នួន ជា ហើយដែលអង្គជំនុំជម្រះកំណត់កាលបរិច្ឆេទធ្វើសវនាការនៅថ្ងៃពុធ ទី០៧ ខែធ្នូ ឆ្នាំ២០១៦។ បញ្ហាសួរ គឺទៅភាគីថា បើអង្គជំនុំជម្រះកោះហៅសាក្សី 2-TCW-1069 មកផ្តល់សក្ខីកម្មចាប់ពីថ្ងៃស្អែកនេះតទៅ តើយ៉ាងម៉េចដែរ? គិតបន្ទាប់ពីស្តាប់សក្ខីកម្មសាក្សី

2-TCW-1063 បានបញ្ចប់។ បញ្ហា គឺថាវាមានបញ្ហាក្នុងការកំណត់កាលវិភាគសវនាការ។

[១០:១២:៤៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមបញ្ជាក់ឱ្យបានច្បាស់ជាភាសាអង់គ្លេស។ <សាក្សីមួយចំនួនមានបញ្ហាសុខភាព ដូច្នេះ យើងមិនអាចស្ដាប់សក្ខីកម្មរបស់គេឡើយ។ យើងគិតថាមានមនុស្សតែម្នាក់គត់ដែលអាចមកបាននៅថ្ងៃស្អែក គឺសាក្សី1069> នេះជាសាក្សីដែលស្នើសុំដោយក្រុមមេធាវីការពារក្ដី នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំដូចជាភ្ញាក់ផ្អើលបន្តិចហើយ។> តើ<>កំណត់<ហេតុរបស់គាត់>ពីមជ្ឈមណ្ឌលឯកសារកម្ពុជានោះ បានបកប្រែរួចរាល់ហើយឬនៅ? បើសិនណាឯកសារនេះ មិនទាន់មានការបកប្រែនៅឡើយទេ អ៊ីចឹងគឺវាចោទជាបញ្ហាហើយ។ វាមានអត្ថបទមួយ <របស់ទស្សនាវដ្ដី>ស្វែងរកការពិត។ យើងបានអានជាភាសាខ្មែរ មានសំណើសុំជាបន្ទាន់មួយ សុំឱ្យធ្វើការបកប្រែ។ ខ្ញុំកំពុងតែសួរសហការីរបស់ខ្ញុំ ថាតើការបកប្រែនោះ វារួចរាល់ហើយឬនៅ។ ហើយបើសិនណាមានតែមួយភាសា នោះគឺមានបញ្ហាហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងបើយើងមិនច្រឡំទេ អ៊ីចឹងបើសិនណាជាការបកប្រែនោះ បកប្រែរួចរាល់ ស្អែកហ្នឹងគឺថាដំណើរការរលូន មិនអ៊ីចឹង? បើមិនទាន់ទេ លោក គឺថាវាអាចមានជាបញ្ហាអ៊ីចឹងមែនទេ?

[១០:១៤:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អ៊ីចឹងមែន។ សហការីខ្ញុំ ប្រាប់ខ្ញុំថា ការបកប្រែទៅជាភាសាអង់គ្លេស ទស្សនាវដ្ដីស្វែងរកការពិតនេះ បករួចរាល់ហើយ។ អ៊ីចឹងតើខ្ញុំសុំៗចាប់ផ្ដើម ខ្ញុំសុំចាប់ផ្ដើមសួរនៅពេលរសៀល នៅថ្ងៃស្អែកនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<អ៊ីចឹង យើងគិតថាទៅរួចហើយ>

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងល្អហើយ។ ចុះភាគីដទៃទៀត យ៉ាងម៉េចដែរ? ព្រោះភាគីម្ចាស់សំណើដូចលែងមានបញ្ហាហើយ ដូចជាអាចដោះស្រាយបានហើយ។ បើមានបញ្ហា សូមលើក បើអត់មានបញ្ហាទេ មិនបាច់ក៏បានដែរណា។

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាងលេះ៖**

លោកប្រធាន យើងទទួលបណ្តឹងនេះ វាយឺតពេកហើយ។ <>បើសិនជាមេធាវី នួន ជា គាត់អាចត្រៀមលក្ខណៈបានសម្រាប់ស្អែកនេះ គឺយើងមិនមានបញ្ហាអ្វីទេ។ ក៏ប៉ុន្តែបើសិនជាយើងត្រូវចាប់ផ្តើមស្អែកហ្នឹង ប្រហែលជាមានបញ្ហាចោទហើយ ពីព្រោះថាយើងត្រៀមលក្ខណៈមិនទាន់រួចស្រេចបាច់នោះទេ។ យើងអាចធ្វើដូចពីមុនមកអ៊ីចឹង ដូចជាកាលនិយាយពីផ្នែករៀតណាមហ្នឹងគឺថា ត្រូវសហព្រះរាជអាជ្ញាអង្គាល់នោះ សហព្រះរាជអាជ្ញាចាប់ផ្តើម ហើយក្រោយមកខាងមេធាវីការពារក្តីគឺថាពេលចូលផុតពីសម្រាកវិញហ្នឹង អាចចាប់ផ្តើម។ អ៊ីចឹងបើសិនជាស្អែកហ្នឹង ខាងមេធាវី នួន ជា គាត់ចាប់ផ្តើមមុននោះ មិនថ្វីទេ យើងអាចសួរនៅសប្តាហ៍ក្រោយ។ ហើយបើមិនអ៊ីចឹងទេ គឺថាយើងអាចធ្វើការតែប៉ផាប់ពភីងហើយលោកប្រធាន។

[១០:១៦:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ ខ្លាចតែខ្ញុំយល់មិនបានច្បាស់នូវអ្វីដែលសហព្រះរាជអាជ្ញារងកំពុងតែនិយាយ។ យើង តាមការពិតទៅគឺខ្ញុំក៏ត្រូវអានចម្លើយពីជម្រមណ្ឌលឯកសារកម្ពុជាពាក់ព័ន្ធទៅនឹងសាច់ញាតិរបស់ សោ ភឹម នេះផងដែរ គឺថា ខ្ញុំនឹងបរិច្ចាគពេលវេលា គឺថានឹងប្រឹងប្រែងទៅតាមនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ដើម្បីឲ្យច្បាស់លាស់ហ្នឹង ថាស្អែកហ្នឹង តើលោកមេធាវីត្រៀមលក្ខណៈរួចហើយទេ? ព្រោះថាខ្ញុំស្តាប់ឮតាមរយៈការបកប្រែដូចជាមានភាពផ្ទុយគ្នា។ អ៊ីចឹងខ្ញុំសួរលោកម្តងទៀតថា តើស្អែកហ្នឹងសម្រាប់សាក្សី 1069 នោះ ស្អែកលោកត្រៀមលក្ខណៈរួចដើម្បីសួរគាត់ទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនទាន់ត្រៀមខ្លួនរួចរាល់ហើយនៅឡើងទេ ក៏ប៉ុន្តែខ្ញុំអាចចូលរួមដំណើរការបាន។

[១០:១៧:០៤]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ចំណែកយើងខ្ញុំវិញនេះគឺថា យើងខ្ញុំត្រៀមលក្ខណៈអត់ទាន់ទេ ព្រោះថាយើងលោតផ្លោះ យើងមានសាក្សីសំខាន់ៗជាច្រើន។ អ៊ីចឹងបើក្នុងករណីយើងនេះគឺថា មេធាវី នួន ជា គាត់ចាប់ផ្ដើមមុន អ៊ីចឹងតាមធម្មតាហ្នឹង យើងនឹងសួរនៅសប្ដាហ៍ក្រោយទេ។ ក៏ប៉ុន្តែបើសិនជាអង្គជំនុំជម្រះចង់បានយោបល់ខ្ញុំ ៗដឹងថាអង្គជំនុំជម្រះចង់ទៅឲ្យលឿនហើយ ទៅមុខឲ្យលឿនហើយ ក៏ប៉ុន្តែបើយោបល់ខ្ញុំវិញ ខ្ញុំគិតថា កាលណាយើងធ្វើការទាំងប៉ផាប់ពភឹងយ៉ាងដូច្នេះ នេះគឺវាដូចជាមិនសូវល្អដែរទេ។ ខ្ញុំយោបល់ផ្ទាល់ហ្នឹង ខ្ញុំថាពេលវេលាសម្រាប់យើងខ្ញុំនេះគឺថា វាសឹងតែថាមិនអាចត្រៀមលក្ខណៈទាន់តែម្ដងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បញ្ហាករណីនេះ យើងបានជូនដំណឹងយូរហើយ។ បញ្ហាសំខាន់មានការផ្លាស់ប្ដូរពីសប្ដាហ៍បន្ទាប់ហើយមកសប្ដាហ៍នេះ ហើយបន្ទាន់ ហើយពេលវេលាសម្រាប់ដំណើរការនេះទំនងជាអាចតែម្ចាស់សំណើទេ ហើយម្ចាស់សំណើអត់មានបញ្ហាផង។ ចំណែកភាគីពាក់ព័ន្ធដទៃទៀត គឺមានពេលវេលាសមស្របសម្រាប់នឹងអាចបន្តកិច្ចដំណើរការនីតិវិធីនៅសប្ដាហ៍ក្រោយ។ ខ្ញុំគិតថា បញ្ហាដូចដោះស្រាយច្បាស់លាស់ហើយ។ ហើយលោកមេធាវីការពារក្ដី នួន ជា លោកបង្ហាញជំហរខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហានេះ វាជាជាងយើងទុកពេលវេលាទំនេរ អត់បំពេញការងារ ព្រោះកិច្ចការវាច្រើនហើយវាយូរណាស់មកហើយក្នុងកិច្ចដំណើរការនីតិវិធីសវនាការនេះ។ បាទ អរគុណណាស់នូវការមតិយោបល់ល្អនេះ។ យើងនឹងដោះស្រាយបញ្ហានេះបានហើយ។

ហើយឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ សាមសិបប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់ និងសាមសិបប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៩ នាទី ដល់ម៉ោង ១០:៣៨ នាទី)*

[១០:៣៧:៥៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយដំបូងនេះអង្គជំនុំជម្រះជម្រាបភាគីថា អង្គជំនុំជម្រះសម្រេចកោះហៅសាក្សី 2-TCW-1069 មកផ្ដើមផ្ដល់សក្ខីកម្មនៅថ្ងៃស្អែក។

បាទ តទៅនេះ ផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី។ ដំបូងនេះ ផ្ដល់មេធាវីទៅ -- វេទិកាជូនសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានសំណួរដើម្បីសួរសាក្សីរូបនេះទេ។ ក៏ប៉ុន្តែខ្ញុំគិតថា ខ្ញុំត្រូវតែពិនិត្យមើលទៅលើប្រធានបទដែលត្រូវសួរទៅសាក្សី <2-TCW1069>។ បាទ 1069 ហើយឥឡូវនេះ គឺថាមានការបកប្រែជាភាសាអង់គ្លេសហើយ។ ក៏ប៉ុន្តែសាក្សីមួយទៀតគឺ 2-TCW-1070 ដែលអង្គជំនុំជម្រះជ្រាបហើយ គឺថាមានភាពជិតដិតជាមួយនឹងសាក្សី 1096 ពីព្រោះថាគាត់ធ្វើការជាមួយនឹង សោ ភឹម។ ឯកសារ <E3/10717> គឺថាមានតែជាភាសាបារាំងទេ។ អ៊ីចឹងចម្លើយពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាភាសាបារាំង៨៨ទំព័រនេះ ប្រសិនបើណាជាខ្ញុំត្រូវសួរសាក្សីរូបនេះ គឺថាវាមានបញ្ហា <>។ ហើយបន្ថែមលើនេះទៀត គឺថាខ្ញុំសូមរំឭកផងដែរថា សាក្សីទាំងពីរ សេចក្ដីសម្រេចកោះហៅសាក្សីទាំងពីរនេះ ទើបតែធ្វើឡើងនៅថ្ងៃទី២២ ខែវិច្ឆិកា គឺទើបតែ៨ថ្ងៃមុននេះទេ។ អ៊ីចឹងក្រុមរបស់យើងខ្ញុំត្រូវតែរៀបចំត្រៀមលក្ខណៈ ដើម្បីប្រឈមមុខទៅនឹងលំបាកទាំងអស់នេះ។ អ្វីដែលសំខាន់បំផុតនោះគឺថា <>នេះគឺថាឯកសារ<10717>មានតែជាភាសាបារាំងទេ។

[១០:៤០:៥៥]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវីដឹងថា ការបកប្រែនឹងរួចរាល់នៅពេលណាទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

យើងអត់ដឹងទេ លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយយើង សាក្សីមួយ -- អំមិញគឺសាក្សី 1069 មិនមែន 1096 ទេណ៎ា អ្នកបកប្រែភាសា 1069 មិនមែន96ទេ។ ហើយចំពោះសាក្សី 1070 យើងនឹងមានកាលវិភាគស្ដាប់នៅពេលក្រោយទៀត ដោយសារមានបញ្ហា។ ទំនងជាអាចយើងមានពេលវេលាដោះស្រាយបញ្ហាទាំងអស់នេះបាន។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីបំភ្លឺ ខ្ញុំមើលទៅ ដូចជាមានបញ្ហាបកប្រែក៏មិនដឹងដែរ។ លោកមេធាវី កូប៉េ លោកនិយាយថា លោក<នៅមិនទាន់រួចរាល់ដើម្បីសួរនៅ>ផ្នែករសៀលនេះ<>ឬក៏យ៉ាងម៉េច? <តើលោកអាច>សួរសាក្សីហ្នឹង<នៅ>សប្ដាហ៍ក្រោយ<បានទេ?>

[១០:៤២:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវ។ គឺថាផ្នែកនេះ ក៏ខ្ញុំអាចត្រៀមខ្លួនរួចរាល់ដែរ ក៏ប៉ុន្តែវាអាស្រ័យទៅលើបកប្រែឯកសារ E3/10717 សិន ដែលជាចម្លើយមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទាក់ទងទៅនឹងសាក្សី 2-TCW-1070។ អ៊ីចឹងបើសិនណាជាមិនទាន់មានបកប្រែជាភាសាអង់គ្លេស ចម្លើយនេះទេ គឺខ្ញុំមិនអាចសួរសាក្សីទាំងពីរនេះបានទេ។ ហើយខ្ញុំរំពឹងថា ការបកប្រែឯកសារនេះគឺថានឹងអាចរួចរាល់ឆាប់ៗនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ចុះបើករណីដែលបកប្រែជាភាសាអង់គ្លេសហ្នឹងមិនហើយ ផ្នែកនេះ តើលោកអាចចោទសំណួរសាក្សីហ្នឹង សប្ដាហ៍ក្រោយបានដែរឬទេ? ព្រោះថាឥឡូវ យើងដឹងថា មានការបកប្រែជាភាសាបារាំងហើយ<>នៅក្នុងក្រុមរបស់លោកនោះ<ក៏>មានអ្នកដែលចេះភាសាបារាំង<ដែរតើ។>

**លោក វ៉ិចទ័រ កូប៉េ៖**

(ការនិយាយជាភាសាបារាំង៖) តាមពិតហើយ យើងយល់ ក៏ប៉ុន្តែ -- លោកចៅក្រម ឡាវែន៍ ខ្ញុំ

អាចអានជាភាសាបារាំងបាន ប៉ុន្តែខ្ញុំត្រូវការភាសាអង់គ្លេស ពីព្រោះខ្ញុំត្រូវសួរតតាំងជាមួយនឹងសាក្សីរូបនេះ។ អ៊ីចឹងឯង ខ្ញុំត្រូវមានការយល់ដឹងឲ្យបានច្រើន អំពីរឿងរ៉ាវពាក់ព័ន្ធទៅនឹងសាក្សីទាំងពីររូបនេះ។

[១០:៤៤:១៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹង បើសិនជាឯកសារទាំងពីរហ្នឹង<>មិនទាន់បកប្រែជាភាសាអង់គ្លេសបានទេ គឺលោកមិនអាចចោទសំណួរទៅសាក្សីរូបនេះបានទេ អ៊ីចឹង ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយ លោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងសួរបញ្ជាក់ឡើងវិញ អំមិញលោកថា បកប្រែហើយហើយ ឥឡូវមានការ យើងសម្រេចរួចហើយ ថាសម្រេចយកសាក្សីនេះ មកស្តាប់សក្ខីកម្មនៅរសៀលថ្ងៃស្អែក។ ដោយយើងបានស្តាប់ភាគីពាក់ព័ន្ធ ជាពិសេសលោកមេធាវី វ៉ិចទ័រ កូប៉េ ដែលជាម្ចាស់សំណើ គឺបានច្បាស់លាស់ហើយ ភាសាខ្មែរ គឺទំនងជាអាចប្រឹងប្រែង ខិតខំធ្វើទៅបាន។ ឥឡូវស្រាប់តែយើងសម្រេចរួចថា យើងនឹងយកមកស្តាប់ បន្តស្តាប់សក្ខីកម្ម ផ្តើមស្តាប់សក្ខីកម្មនៅរសៀលថ្ងៃស្អែក ឥឡូវថាអត់ ៗកើតវិញ។ ឥឡូវយើងចង់សួរបញ្ជាក់ថា យ៉ាងម៉េចទៅ អំមិញឆ្លើយថា ស្តាប់សក្ខីកម្មសាក្សី -- ឯកសារហ្នឹងត្រូវបានបកប្រែរួចរាល់ហើយ។ ឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបន្ទាប់ពីយើងសម្រេចថា កោះហៅសាក្សីហ្នឹងមកថ្ងៃស្អែក ឥឡូវមានការផ្លាស់ប្តូរ។ យ៉ាងម៉េចទៅ ឥឡូវនិយាយឲ្យច្បាស់លាស់ និយាយឲ្យខ្លីៗ ហើយឲ្យងាយយល់បានហើយ យើងដូចជាបញ្ហាកាត់តែស្មុគស្មាញទៅ រឿងដូចតូចសោះ។ យើងដូចធ្លាប់ដោះស្រាយរឿងធំៗ ស្មុគស្មាញច្រើនហើយ ប៉ុន្តែដូចជាងាយស្រួល ប៉ុន្តែដល់ពេលមកដល់រឿងនេះ ទំនងជាងាយ បែរជាបង្កើតបញ្ហាស្មុគស្មាញ នាំឲ្យដួរត្រឡប់ត្រឡិននូវសេចក្តីសម្រេចរបស់ខ្លួន ដូចជាមិនទំនងសោះ។

[១០:៤៥:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមទោសលោកប្រធាន។ ប្រហែលជាបញ្ហាការបកប្រែនេះ គឺថាមិនទាន់ច្បាស់លាស់ទេ។ មុនពេលឈប់សម្រាក ខ្ញុំបានឆ្លើយថា បាទ គឺថាយើងមានបំណងចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី។

ក៏ប៉ុន្តែវាអាស្រ័យទៅលើព័ត៌មានណាមួយដែលយើងខ្ញុំយល់មិនគ្រប់គ្រាន់នោះ ពីព្រោះថា សាក្សីទី២ ដែលមានការជាប់ពាក់ព័ន្ធជិតដិតជាមួយនឹង 2-TCW-1069 គឺថា គាត់បានផ្តល់ចម្លើយទៅដល់មជ្ឈ-មណ្ឌលឯកសារកម្ពុជារួចហើយដែរ ក៏ប៉ុន្តែវាមានតែជាភាសាខ្មែរ និងភាសាបារាំងទេ។ ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា សាក្សីទាំងពីរនេះ គឺមានភាពជិតដិតជាមួយនឹង សោ ភឹម ហើយអង្គជំនុំជម្រះសម្រេចកោះហៅសាក្សីទាំងពីរនេះ គឺភ្លាមៗ ទើបតែប៉ុន្មានថ្ងៃមុននេះ។ អ៊ីចឹងយើង<មានការពិបាកក្នុង>ការសួរសំណួរសាក្សីម្នាក់ <>ដោយ<ពុំបាន>ដឹង<>សាក្សីម្នាក់ទៀត<>ផ្តល់ចម្លើយជូនមជ្ឈមណ្ឌលឯក-សារកម្ពុជា<ថាយ៉ាងដូចម្តេច>នោះទេ។ អ៊ីចឹងលោកប្រធាន ខ្ញុំសូមដកចេញនូវការបញ្ជាក់របស់ខ្ញុំមុនពេលឈប់សម្រាក។ អ៊ីចឹងគឺខ្ញុំនៅតែផ្តោតថា ឥឡូវនេះ វាជួបនឹងការលំបាកហើយ ប្រសិនណាជាឯកសារនេះ មិនបានបកប្រែទៅជាភាសាអង់គ្លេស ឲ្យបានទាន់ពេលវេលាទេ។

[១០:៤៧:៣១]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងទំនងជាសប្តាហ៍ក្រោយក៏ធ្វើមិនបានដែរ ហើយទំនងជាឆ្នាំនេះធ្វើមិនបានទេ តាមយើងស្តាប់លោកនិយាយហ្នឹង ទំនងឆ្នាំនេះធ្វើមិនបានទេ ២០១៦ ធ្វើមិនបានទេ ព្រោះធ្វើសវនាការត្រឹមថ្ងៃ១៥ ខែធ្នូទេ។ បើតាមទំហំឯកសារ ហើយនិងតាមបទពិសោធន៍ការងាររបស់លោកហ្នឹង ការងារហ្នឹងតើធ្វើហើយពេលណាទំនងនោះ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<តើខ្ញុំអាចផ្តល់យោបល់មុនពេលយើង-->

**ប្រធានអង្គជំនុំ៖**

ឥឡូវឆ្លើយសិន! យើងអ្នកសួរ បញ្ហាឯកសារនោះយ៉ាងម៉េចទៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមបញ្ជាក់ចម្លើយឡើងវិញ លោកប្រធាន។ ចម្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជារបស់សាក្សីម្នាក់ទៀតនេះ គឺខ្ញុំយល់ឃើញថា មិនអាចបកប្រែរួចរាល់រហូតទៅដល់សប្តាហ៍ក្រោយឯនោះ។ ខ្ញុំមានបំណងចូលរួមនៅសប្តាហ៍ក្រោយនេះ គឺប៉ុន្តែការបកប្រែនេះ គឺជាអាទិភាពហើយ។ ខ្ញុំត្រៀមខ្លួនរួចហើយ ឲ្យតែការបកប្រែនោះរួចរាល់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរសំណួរទៅលោក ថាតើមានបានស្នើសុំឲ្យបកប្រែឯកសារនេះ ហើយឬនៅ? តើមានភាគីណាមួយស្នើសុំឲ្យបកប្រែឯកសារនេះរួចរាល់ហើយ ឬនៅ?

[១០:៤៨:៥៨]

**<លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាបានដាក់ស្នើទៅហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដាក់ស្នើទៅនៅពេលណាដែរ?>

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹងថា យើងបានស្នើសុំហើយ។ យើងសុំរួចហើយ ដោយសារថា មានការបកប្រែជាភាសាអង់គ្លេសសម្រាប់សាក្សីម្នាក់<រួចរាល់ហើយ>។ អ៊ីចឹងខ្ញុំ<គិតថាយើងដាក់ស្នើទៅតាមរយៈសំណើសុំតែមួយហ្នឹង។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងកំពុងតែពិនិត្យមើល ផ្ទៀងផ្ទាត់ឲ្យបានច្បាស់លាស់។ អ៊ីចឹងប្រហែលជាយើងរង់ចាំរហូតដល់ពេលយើងដឹងថាការបកប្រែ តើវាអាចនឹងរួចរាល់ហើយនៅពេលណា? ហើយនិងយើងចេញសេចក្ដីសម្រេចទៅតាមនោះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមធ្វើការកត់សម្គាល់ទាក់ទងនឹងចំណុចនេះ គឺថាបញ្ហា ប្រសិនបើបញ្ហាភាសានៅតែបន្តមានទៀតហ្នឹង គឺថាយើងនឹងមានការលំបាកបន្តទៀតហើយ។ ទាក់ទងទៅនឹងសាក្សី 920 នេះគឺថាមាន គាត់ផ្ដល់ការសម្ភាសទៅមជ្ឈមណ្ឌលកម្ពុជាហ្នឹង ឯកសារកម្ពុជា មានតែជាភាសា<បារាំង> ហើយនិងភាសាខ្មែរទេ។ អ៊ីចឹងនៅថ្ងៃអង្គារនេះ ត្រូវស្ដាប់គាត់ហ្នឹង <គឺមិនបានពន្យារពេលទេ>។ ហើយ <>ខាងព្រះរាជអាជ្ញានេះ យើងមានទាំងអ្នកនិយាយបារាំង និងចេះនិយាយអង់គ្លេសដែរ។ សម្រាប់ស្នែកនេះ ខ្ញុំគិតថា យើងមានតែជាភាសាបារាំងទេ ហើយវាមានតែពាក់ព័ន្ធទៅនឹងសាក្សី 2-TCW-1069 វាពាក់ព័ន្ធខ្លាំង។ អ៊ីចឹងខ្ញុំគិតថា បើយើងប្រើពេលមួយសប្ដាហ៍ គួរតែដោះស្រាយបញ្ហាហ្នឹងបានហើយ។ ក្រុម នួន ជា គាត់មានមេធាវីជាតិពីរនាក់ អ៊ីចឹងគាត់អាចសួរបាននៅក្នុងសវនាការនេះ។ ហើយគាត់មានអ្នកចេះនិយាយភាសាបារាំងច្រើនដែរ។

ដូច្នេះបើសិនជា គ្រាន់តែអានសម្រង់នៃចម្លើយដែលគាត់ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជានេះ មេធាវីជាតិអាចអានជាភាសាខ្មែរទៅ ហើយអ៊ីចឹង ខ្ញុំគិតថា គាត់អាចចំណាយពេលវេលាត្រៀមច្រើនបន្តិច ក៏ប៉ុន្តែអាចដោះស្រាយបញ្ហានេះបានទេ មិនបាច់ពន្យារពេលនៃការមកផ្តល់សក្ខីកម្ម ការស្តាប់សក្ខីកម្មរបស់សាក្សីជាច្រើន <ដោយមិនមានកាលកំណត់នោះទេ>។ អ៊ីចឹងខ្ញុំគិតថា ភាគីមួយៗគួរតែវិនិយោគបន្តិចទៅ ដើម្បីដោះស្រាយបញ្ហានេះឲ្យចេញ។

[១០:៥១:៣៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ឆ្លើយទៅនឹងសំណួររបស់លោកប្រធាន ខ្ញុំបានទទួលព័ត៌មានថា សំណើសុំហ្នឹងគឺត្រូវបានធ្វើឡើងនៅថ្ងៃទី២៨ តុលា គឺស្នើសុំឲ្យបកប្រែឯកសារពាក់ព័ន្ធសាក្សីទាំងពីរនេះឯង។ ហើយមានការបញ្ជាក់ថា ការបកប្រែ គឺត្រូវបកហើយនៅថ្ងៃទី២៦ វិច្ឆិកា។ អ៊ីចឹងការបកប្រែនេះ មើលទៅគឺអាចនឹងរួចរាល់ឆាប់ៗនេះហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំធ្វើការកត់សម្គាល់ខ្លីទេ ព្រោះខាងក្រុមខ្ញុំនេះ គាត់ថា មានការបកប្រែជាអង់គ្លេសហើយស្រេចទៅហើយ តាមពិតគ្រាន់តែថា *អាប់ឡូត*ចូល *ហ្សាយឡេក*ទៅបានហើយ។ អ៊ីចឹងការបកប្រែចម្លើយគាត់ចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា មានជាភាសាអង់គ្លេសរួចស្រេចទៅហើយទេ គ្រាន់តែ*អាប់ឡូត*ទៅបានហើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថា លោកស្រីមេធាវីនិយាយអំពីចម្លើយទី២របស់សាក្សីម្នាក់ទៀតនេះ ឬម៉េច ឬក៏និយាយអំពីសាក្សី TCW-1069? និយាយពីមួយណាដែរនេះ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

បើគេទើបនឹងប្រាប់ខ្ញុំអំមិញនេះឯងថា នុ៎ងហើយ គេបកប្រែជាភាសាអង់គ្លេសហើយៗ សាក្សីម្នាក់ទៀតនុ៎ង ចម្លើយរបស់សាក្សីម្នាក់ទៀតនុ៎ង។ អ៊ីចឹងពេលសម្រាកនេះ ពេលសម្រាកអាហារថ្ងៃត្រង់នេះ ខ្ញុំនឹងសុំព័ត៌មានលម្អិតពីបញ្ហាបកប្រែហ្នឹងថា យ៉ាងម៉េចទៅហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៣:២៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ត្រូវហើយ សាក្សីទី២ហ្នឹង គឺថា 2-TCW-1070 គឺចម្លើយរបស់សាក្សីរូបនេះ ត្រូវបានបកប្រែជាភាសាអង់គ្លេសហើយៗ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ហើយយើងបញ្ចាក់បញ្ហានេះនៅវេលារសៀល មុននៅរសៀលនេះ ព្រោះក្រោយពេលអាហារថ្ងៃត្រង់ ដើម្បីឱ្យភាគីពាក់ព័ន្ធរួមទាំងខាងមន្ត្រីច្បាប់របស់អង្គជំនុំជម្រះខ្លួនឯងបានពិនិត្យ និងបានព័ត៌មាននេះមកយើងឱ្យបានល្អជាងនេះផង។

បាទ តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរមួយចំនួន សួរទៅកាន់លោកស្រី ហើយសហភាតារបស់ខ្ញុំលោក គង់ សំអុន ក៏គាត់មានសំណួរដែរ។ ជាដំបូងខ្ញុំសូមឱ្យលោកស្រីជួយបំភ្លឺចំណុចមួយ ពេលដែលលោកស្រីឆ្លើយទៅនឹងសហព្រះរាជអាជ្ញា ដែលសួរសំណួរទៅលោកស្រី ទាក់ទងនឹងបញ្ជីអ្នកទោសមន្ទីរស-២១ លោកស្រីបានពន្យល់ថា លោកស្រីមកទីនេះ ដើម្បីនិយាយការពិត ហើយលោកស្រីបានស្បថនៅមុខអ្នកតាដំបងដែកផងដែរ។ ជាធម្មតា ដើមបណ្តឹងរដ្ឋប្បវេណីគេមិនមកស្បថ មិនចាំបាច់ស្បថទេ។ អ៊ីចឹងខ្ញុំសួរលោកស្រី ថាតើលោកស្រីស្បថនៅចំពោះមុខអ្នកតាដំបងហ្នឹងនៅពេលណាដែរ?

[១០:៥៥:៤២]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញគាត់ថា គាត់មិនបាន -- គាត់មិនបាននិយាយថាគាត់បានស្បថទេ តែគាត់និយាយថាគាត់អាចទៅស្បថបាន។ ដូច្នេះអ្វីដែលបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើកឡើងអម្បាញ់មិញ គឺមិនត្រឹមត្រូវទេ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងប្រហែលជាមានបញ្ហាបកប្រែហើយ ព្រោះថាជាបារាំងអម្បាញ់មិញយើងអត់បានឮ អ៊ីចឹងទេ។ អ៊ីចឹងសូមអរគុណដែលបានឆ្លើយបំភ្លឺ។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនទាក់ទងនឹងរយៈកាលមុនឆ្នាំ១៩៧៥ ហើយនិងជាពិសេស ការជួបប្តីរបស់លោកស្រី។ តើលោកស្រីបានជួបប្តីរបស់លោកស្រីហ្នឹងនៅក្នុងភូមិ ហើយពេលដែលជួបហ្នឹងគឺថាលោកស្រីស្គាល់គាត់មុនពេលរៀបការទេ ស្គាល់ពីមុនមកទេ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ប្តីខ្ញុំនិងខ្ញុំនេះគឺនៅភូមិជាមួយគ្នា ឃុំជាមួយគ្នា ដែលស្គាល់តាំងពីកំណើតមក ដឹងក្តីរៀនសាលាជាមួយគ្នា។

**ស៖** ហើយតើឈ្មោះគាត់តាំងពីកំណើតមកដែលលោកស្រីស្គាល់ហ្នឹងឈ្មោះអីដែរ?

**ឆ៖** ឈ្មោះពីកំណើតមក ខេង ជឿន ជីតាគាត់ឈ្មោះ គង់ អ៊ូ! សូមទោស ខេង ជី – ខេង ជី ចូលបដិវត្តគេហៅ ខេង ជឹន តែជីតាគាត់ឈ្មោះ គង់ – គង់ ជី។

**ស៖** លោកស្រីបានឆ្លើយថា ប្តីរបស់លោកស្រីបានចូលបដិវត្តន៍នោះក្នុងឋានៈជាយុទ្ធជន ខ្ញុំយល់ហើយ ខ្ញុំយល់ថាគាត់ហ្នឹងមិនមានឋានន្តរស័ក្តិអីទេនៅក្នុងកងទ័ពបដិវត្តនោះ តើអ៊ីចឹងមែនទេ?

[១០:៥៨:១០]

**ឆ៖** ចាស ខ្ញុំបាននិយាយថា អង្កាល់ដែលនៅសមរភូមិ ដែលវ៉ៃគ្នាប្តីខ្ញុំជាវរកងតូច។ ៧៥ ដាច់ភ្នំពេញនេះ គឺប្តីខ្ញុំអត់មានតួនាទីអីទេ តែមានតែការងារជញ្ជូនស្បៀង លីសែងដាក់ក្នុងឃ្លាំងរដ្ឋអីទេ។

**ស៖** ឥឡូវខ្ញុំនិយាយអំពីរយៈកាលមុនឆ្នាំ១៩៧៥ដដែល លោកស្រីដូចជាបាននិយាយ<ថា> ប្តីរបស់លោកស្រីហ្នឹងចេញពីឃុំហ្នឹងនៅឆ្នាំ១៩៧៤។ តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេថាលោកស្រីជួបគាត់ជាលើកទី១វិញ ជួបឡើងវិញនៅពេលណាដែរ ក្រោយពីពេលគាត់បានចេញពីឃុំរស់នៅហ្នឹងទៅ លោកស្រីបានជួបគាត់ម្តងទៀតឡើងវិញហ្នឹងនៅឆ្នាំណាដែរ?

**ឆ៖** ចាស ប្តីខ្ញុំចេញពីឆ្នាំ១៩៧៤នេះ ទៅសមរភូមិ ទៅបាត់។ ដល់ពេលដាច់៧៥នេះ ខ្ញុំមកជួបលេងបានម្តងក្នុងរយៈពេល១ខែហ្នឹង កន្លះខែហ្នឹង ភ្លេចដែរយូរ មួយដងនោះឯង រហូតដល់ឆ្នាំ៧៨ បានជួបគ្នារហូតដល់បែកគ្នាទៀត។

**ស៖** ពេលដែលលោកស្រីជួបគាត់នៅឆ្នាំ១៩៧៥ហ្នឹង គឺមុនពេលដែលវ៉ៃបែកភ្នំពេញហើយ ដណ្ដើមបានទីក្រុងភ្នំពេញហើយ ឬក៏ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ទេ?

**ឆ៖** ចាស ដែលខ្ញុំមកជួបនោះគឺនៅក្នុងឆ្នាំ៧៥នេះ ក្រោយរំដោះភ្នំពេញរួចហើយ។ ប្ដីខ្ញុំចូលធ្វើការរដ្ឋនៅនឹងផ្សារថ្មីនេះហើយ លីសែងដាក់ឃ្លាំង។ ខ្ញុំសុំច្បាប់ពីភូមិឃុំ ខ្ញុំសុំមកលេងជាមួយនឹងគាត់ម្ដងប៉ុណ្ណោះឯង រហូតដល់៧៨ បានជួបគ្នា។ អស់រយៈពេលប៉ុន្មានខែនេះ ក៏បែកគ្នាទាល់ឥឡូវនេះទៀតទៅ។

[១១:០១:០៧]

**ស៖** នៅពេលដែលលោកស្រីទៅជួបប្ដីរបស់លោកស្រីក្នុងរយៈពេល១៥ថ្ងៃហ្នឹង តើនៅផ្សារថ្មីដដែលហ្នឹង នៅភ្នំពេញដដែលហ្នឹង ផ្សារថ្មីហ្នឹងជាកន្លែងដែលលោកស្រីបានជួប ទៅជួបគាត់ម្ដងទៀតនៅឆ្នាំ១៩៧៨ហ្នឹង ឬក៏នៅកន្លែងផ្សេងទេ?

**ឆ៖** ចាស ជួបនឹងកន្លែងដដែល កន្លែងដែលនៅនឹងផ្សារថ្មីដដែល។ អត់មានខុសកន្លែងទេ។

**ស៖** លោកស្រីបាននិយាយថា ដើម្បីឲ្យបានការអនុញ្ញាតហ្នឹង គឺលោកស្រីបានសុំការអនុញ្ញាតពីអាជ្ញាធរ។ តើនៅពេលដែលលោកស្រីមកជួបប្ដីលោកស្រីនៅឆ្នាំ១៩៧៨ហ្នឹង គឺលោកស្រីជាអ្នកទៅសុំច្បាប់ពីអាជ្ញាធរខ្លួនឯង ឬក៏ប្ដីលោកស្រីទេ ជាអ្នកសុំច្បាប់ចេញពីលើទៅ ដើម្បីឲ្យលោកស្រីអាចមកជួបគាត់នៅភ្នំពេញបាន?

**ឆ៖** ចាស កាលឆ្នាំ៧៨នោះហើយដែលថា ទៅយកខ្ញុំមកចូលឆ្នាំនេះ គឺគេទៅយកខ្លួនគេផ្ទាល់បណ្ដោយ។ ខ្ញុំអត់បានដឹងដែរ ស្រាប់តែឃើញទៅ យកខ្ញុំ ថាមកលេងចូលឆ្នាំនៅភ្នំពេញនេះឯង។ ដល់មកលេងទៅ ក៏អត់បានទៅវិញទេ។

**ស៖** អ៊ីចឹងលោកស្រីកំពុងតែនិយាយថា លោកស្រីមិនបានសុំច្បាប់អនុញ្ញាតមកភ្នំពេញអីជាមុនទេ អ៊ីចឹងឬក៏យ៉ាងម៉េច?

**ឆ៖** ចាស តែខ្ញុំមិនបានសុំច្បាប់ទេ ត្រឹមប្ដីខ្ញុំទៅគឺគេសុំមេភូមិ មេឃុំនេះឯង សុំខ្ញុំមក ក៏គេអនុញ្ញាតឲ្យមក ក៏ខ្ញុំមកជាមួយទៅ។

**ស៖** ខ្ញុំយល់។ អ៊ីចឹងពេលដែលលោកស្រីនិយាយថា គេជិះឡានមក ៗយកលោកស្រីហ្នឹងទៅភ្នំពេញ អ៊ីចឹងកន្លែងហ្នឹងគឺតាមពិតទៅ ប្ដីលោកស្រីគាត់ជិះឡានមកដឹកលោកស្រីឡើងទៅភ្នំពេញ ឬក៏យ៉ាងម៉េច?

[១១:០៣:៤៩]

**ឆ៖** ចាស នាងខ្ញុំជម្រាបថា ឈ្មោះ ពូវីន និង ពូកុយ នេះឯងជាប្រធានប្ដីខ្ញុំ។ ដល់ពេលចូលឆ្នាំ៧៨នេះឯង គាត់ហ្នឹងបរឡានឡើងទៅ ៗយកខ្ញុំនេះមក ជាមួយនឹងប្ដីខ្ញុំនេះឯង ថាមកលេងចូលឆ្នាំ៧៨ ឆ្នាំ៧៨នេះឯង។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំចូលមកនិយាយអំពីការមកដល់របស់លោកស្រីនៅផ្សារថ្មី។ តើលោកស្រីអាចពិពណ៌នាអំពីកន្លែងដែលលោកស្រីចូលធ្វើការដែរឬទេ? លោកស្រីបានឆ្លើយចំពោះមុខអង្គជំនុំជម្រះថា ការងាររបស់លោកស្រីហ្នឹងគឺអ្នកធ្វើខាងដាំបាយសម្រាប់អ្នកដែល<ដែលនៅជាមួយគ្នា>។ អ៊ីចឹងលោកស្រីអាចបញ្ជាក់បានទេថា កន្លែងដែលលោកស្រីរស់នៅ ធ្វើការហ្នឹងគឺលោកស្រីដាំបាយដាំទឹកអីឲ្យគេហ្នឹងហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ការពិត។ ចំណែកខ្ញុំ គេឲ្យនៅធ្វើម្ហូប នៅនឹងចង្ក្រាននោះឯង។ តែសម្រាប់អ្នកដែលលីសែង ផ្គត់ផ្គង់ស្បៀងដាក់ឃ្លាំង គ្រាន់ចែកគ្នាហូប នៅក្នុងមួយក្រុមហ្នឹងទេ។

**ស៖** កន្លែងដែលលោកស្រីរស់នៅនោះ គឺនៅក្នុងឃ្លាំងហ្នឹងតែម្ដង ឬក៏ជាអគារមួយដែលនៅដាច់ដោយឡែកពីឃ្លាំង?

**ឆ៖** ចាស កន្លែងដែលខ្ញុំសម្រាកស្នាក់នៅប្រចាំថ្ងៃ គឺអគារនៅដាច់ពីឃ្លាំង។

**ស៖** ហើយកន្លែងដែលលោកស្រីដាំបាយដាំទឹកនោះ ជាកន្លែងដែលលោកស្រីសម្រាន្តពេលយប់ហ្នឹង ឬក៏កន្លែងដែលដាំបាយដាំទឹកហ្នឹង នៅកន្លែងឃ្លាំងទេ?

[១១:០៦:១៧]

**ឆ៖** ចាស កន្លែងដាំបាយនេះក៏នៅកន្លែងខ្ញុំស្នាក់នៅនេះទេ ចង្ក្រានដាំបាយ។

**ស៖** កន្លែងដែលលោកស្រីដាំបាយដាំទឹកហ្នឹង ឬក៏កន្លែងដែលលោកស្រីគេងសម្រាន្តពេលយប់ហ្នឹង នៅឆ្ងាយពីឃ្លាំងហ្នឹងប៉ុន្មានដែរ ប្រហែលចម្ងាយប៉ុន្មានដែរពីឃ្លាំង?

**ឆ៖** ពេលទៅ វាប្រហែលជា៥០ម៉ែត្រហ្នឹងពីឃ្លាំងផ្សារថ្មីមកនឹងកន្លែងខ្ញុំស្នាក់នៅ សម្រាកប្រចាំថ្ងៃ។

**ស៖** ហើយប្ដីលោកស្រីនោះ ពេលថ្ងៃៗហ្នឹង គាត់ធ្វើការនៅឃ្លាំងហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ថ្ងៃឡើង នាំគ្នាលើកអង្ករពីឡាន ដាក់នៅក្នុងផ្សារធំនោះឯង។

**ស៖** លោកស្រីបាននិយាយពីមនុស្សពីរនាក់ ដែលជាទំនងជាត្រូវបានចាប់ខ្លួន ក្នុងពេលដំណាល

គ្នាជាមួយប្ដីលោកស្រី។ អ៊ីចឹងខ្ញុំសួរលោកស្រី ថាតើលោកស្រីបានជួបគាត់ពីរនាក់ហ្នឹង នៅពេលណាដែរ ជាលើកទី១ហ្នឹង ឈ្មោះ រុន ហើយនឹង យ៉េ នេះ?

**ឆ៖** ចាស អ្នកពីរនាក់នេះ ដែលគេចាប់ប្ដី -- អ៎! ចាប់ទៅជាមួយប្ដីខ្ញុំនេះ បើនិយាយពីស្គាល់តាំងពីខ្ញុំចូលមកនៅ មកចូលឆ្នាំ៧៨នេះឯង ខ្ញុំស្គាល់រហូត ទាល់ពីបែកពីខ្ញុំទៅ ជាមួយនឹងប្ដីខ្ញុំ។

**ស៖** គាត់ទាំងពីរនាក់ហ្នឹង ធ្វើការនៅក្នុងឃ្លាំងជាមួយគ្នានឹងប្ដីលោកស្រី?

**ឆ៖** ចាស ធ្វើការជាមួយគ្នា ហូបចុកជាមួយគ្នា តែខ្ញុំអ្នកដាំស្លនេះឯង។

**ស៖** តើលោកស្រីដាំបាយដាំទឹកហ្នឹង សម្រាប់មនុស្សប៉ុន្មាននាក់ដែរ?

[១១:០៨:៥៨]

**ឆ៖** ចាស ព្រោះអីដាំបាយដាំអី វាមិនទៀងដែរ ថ្ងៃណាក៏បានត្រឹម៥០នាក់ ថ្ងៃណាក៏៤០នាក់ គេចល័តកម្លាំងទៅណាទៅណីទៅ ខ្ញុំមិនដឹងដែរ។ ថ្ងៃណាតិច ថ្ងៃណាច្រើន មានពេលវាដែរ។

**ស៖** ហើយនៅពេលដែលលោកស្រីធ្វើម្ហូបអាហារហ្នឹង តើអ្នកណាជាអ្នកមើលថែទាំកូនចៅលោកស្រី?

**ឆ៖** ចាស កូន វានៅជាមួយនឹងខ្ញុំដែរ ដើរលេងដើរអី នៅកន្លែងអគារនេះទៅ។ ក៏មានបញ្ហាអីដូចថា ខ្ញុំដាំស្លក៏មានគ្នាក្រែល បីបួននាក់ទៅ នារីៗនោះ។ កូនក៏វាដើរលេងនឹងកន្លែងនេះដែរទៅ។

**ស៖** ឥឡូវខ្ញុំសូមចូលទៅនិយាយពីថ្ងៃដែលលោកស្រីទទួលដំណឹងថា គេចាប់ប្ដីលោកស្រីហើយ។ លោកស្រីនិយាយថា កូនលោកស្រីអាយុបីឆ្នាំនោះ បានប្រាប់ថា ប្ដីរបស់លោកស្រីហ្នឹងចេញទៅជាមួយមនុស្សពីរនាក់ ដែល រុន ហើយនិង យ៉េ នេះបាត់ហើយ។ តើលោកស្រីដឹងដែរឬទេថា ពេលដែលកូនលោកស្រីឃើញមនុស្សទាំងបីនាក់នេះចេញទៅហ្នឹង កូនលោកស្រីហ្នឹងនៅកន្លែងណាដែរ ពេលដែលឃើញហ្នឹង?

**ឆ៖** ចាស កូនខ្ញុំវានៅជាមួយឪពុកហ្នឹងឯង ដល់ពេលគេហៅឪពុកដាក់ឡានទៅ វានៅនោះឯងនៅជាមួយឪពុក។ តែកូនខ្ញុំវានៅលេងជាប់នោះឯង ដល់វាដឹង វាឃើញ ខ្ញុំសួរវាថា អាទូច ឯណាពុកអ្អែង? ថា ពុក ម៉ែអើយ ពុកដាក់ឡានទៅបាត់ហើយជាមួយ ពូរុន និង យ៉េ នោះឯង។ បានខ្ញុំដឹងពីកូនខ្ញុំនេះឯង។ ក៏បាត់ ទៅបាត់ហើយអត់ឃើញ។

[១១:១១:១៩]

**ស៖** យើងឃើញថា មានកំហុសជាច្រើននៅក្នុងឯកសារចម្លើយរបស់លោកស្រី គឺទម្រង់បែប

បទសុំពាក្យតាំងជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោកស្រីនោះ មានកំហុសច្រើន។ ហើយខ្ញុំសូមគូសបញ្ជាក់ថា ឯកសារ E3/6425 ERN ជាភាសាបារាំងគឺ 01152692, ជាភាសាខ្មែរគឺ 00544168, ជាភាសាអង់គ្លេសគឺ 01114153។ លោកស្រីបានឆ្លើយទៅសហព្រះរាជអាជ្ញាថា មានកំហុសមួយនៅក្នុងឯកសារហ្នឹង ពីព្រោះថា ប្ដីរបស់លោកស្រីមិនដែលធ្លាប់ជាកម្មាភិបាលទេ គឺគាត់ជាអ្នកលីសែង កម្មករលីសែងទេ។ អ៊ីចឹងនៅក្នុងឯកសារនេះ មានសរសេរដូចតទៅនេះ នៅពេលដែលនិយាយអំពីការដំឡើងឋានន្តរសក្តិឱ្យគាត់នេះ។ ខ្ញុំសូមដកស្រង់៖ "គាត់ចូលធ្វើការហ្នឹងបានប្រហែល១ខែហ្នឹង គឺគេចាប់គាត់នៅក្នុងមន្ទីរគាត់នៅខាងជើងផ្សារថ្មី ពេលនោះគាត់កំពុងតែនិយាយទូរស័ព្ទ ហើយខ្ញុំនៅ១០០ម៉ែត្រពីគាត់អីទុំងឯងអង្កាល់ទុំង។ ហើយខ្ញុំឃើញឡានមក មានកម្មាភិបាលបីនាក់ជិះមកជាមួយ មកឈប់នៅមុខមន្ទីររបស់គាត់ ហើយសុំឱ្យគាត់ឡើងជិះលើឡានហ្នឹងទៅ ហើយក៏ពួកគេចេញទៅទាំងអស់គ្នាទៅ។" សូមបញ្ចប់ការកស្រង់។

អ៊ីចឹងនៅក្នុងចម្លើយនេះ យើងឃើញថា លោកស្រីជាសាក្សីផ្ទាល់ភ្នែក ឃើញការចាប់ខ្លួនហ្នឹង។ អ៊ីចឹងលោកស្រីអាចបញ្ជាក់បានដែរឬទេថា នេះជាកំហុសហើយនៅក្នុងឯកសារនេះ ដែលថា លោកស្រីហ្នឹងជាសាក្សីផ្ទាល់ភ្នែក ឃើញគេចាប់ គេឱ្យប្ដីលោកស្រីឡើងឡានអីចេញទៅ ឬក៏លោកស្រីដឹងហ្នឹងតាមរយៈកូនរបស់លោកស្រីដែលបានប្រាប់បន្តទេ?

[១១:១៣:៤២]

**ឆ៖** ចាស ខ្ញុំបាននិយាយខាងដើម តែខ្ញុំមិនឃើញផ្ទាល់ តែខ្ញុំដឹងនឹងកូនខ្ញុំ។ ក្រែងថាភ័ន្តច្រឡំកត់ច្រឡំយ៉ាងម៉េច អត់ដឹងទេ ប៉ុន្តែខ្ញុំបានដឹងដំណឹងតែនឹងកូនខ្ញុំទេ ថាខ្ញុំឃើញផ្ទាល់នឹងភ្នែកខ្ញុំ អត់ទេ។

**ស៖** អ៊ីចឹងខ្ញុំមានសំណួរមួយទៀតចេញពីចម្លើយលោកស្រីនេះ ព្រោះលោកស្រីបានជម្រាបជូនតុលាការ ហើយលោកស្រីបានពិគ្រោះបញ្ជីមួយនៅទីនោះ លោកស្រីថាលោកស្រីចេះអាន និងសរសេរ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា អ្នកណាអ្នកជួយបំពេញទម្រង់បែបបទនេះ ជូនលោកស្រី? ហើយលោកស្រីមានបានអានឡើងវិញទេ ពេលដែលបំពេញហើយហ្នឹង?

**ឆ៖** ខ្ញុំអានដែរ ប៉ុន្តែខ្ញុំវាច្រើនភ្លេច គឺថារោគវាឡើងឈាម វាឈឺក្បាលទៅ វាងងឹតគ្រាប់ភ្នែកទៅ ក៏ខ្ញុំមិនសូវចាំច្បាស់ ដូចថាវាមិនសូវច្បាស់នឹងខ្លួនឯងដែរ អារឿងអានអក្សរ អានអី។ ខ្ញុំច្រើនព្រិលភ្នែក។

**ស៖** អ៊ីចឹងអ្វីដែលលោកស្រីចង់និយាយនោះគឺថា នៅពេលដែលគេ លោកស្រីអាននូវចម្លើយ

លោកស្រីនុំងឡើងវិញហ្នឹង គឺលោកស្រី<>មិនសូវច្បាស់លាស់<ក្នុងចិត្ត> ហើយអ៊ីចឹងលោកស្រីបានចុះហត្ថលេខាលើចម្លើយហ្នឹងទៅ ឬក៏យ៉ាងម៉េច? លោកស្រីអាចពន្យល់ឲ្យបានលម្អិតបន្តិចបានទេ ពីរឿងដែលកើតឡើងនេះ ក្រោយពេលផ្តល់ចម្លើយឲ្យគេហើយហ្នឹង?

**ឆ៖** ចាស ខ្ញុំដែលដូចថា អានហើយអីហើយ ខ្ញុំព្រមព្រៀងចុះៗចម្លើយនេះឲ្យហើយ ក៏ខ្ញុំ គឺថា ខ្លួនខ្ញុំជាសាក្សីដែរ ក៏ខ្ញុំឯកភាពជាមួយទៅ។

[១១:១៦:០៨]

**ស៖** អ៊ីចឹងលោកស្រីចង់និយាយប្រាប់ជូនតុលាការថា កំហុសនៅក្នុងចម្លើយរបស់លោកស្រីដែលខ្ញុំទើបនឹងលើកឡើងជូន អានជូនលោកស្រីនេះ គឺថាអ្វីដែលទាំងអស់ហ្នឹង គឺលោកស្រីបាននិយាយអ៊ីចឹងមែន ប៉ុន្តែឥឡូវនេះ គឺលោកស្រីកំពុងតែកែប្រែចម្លើយរបស់លោកស្រី ត្រង់ចំណុចដែលខ្ញុំអានជូនហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំអត់មានកែប្រែទេ រឿងចម្លើយនោះ គឺខ្ញុំ ដូចថាខ្ញុំវាចាំត្រឹមណា ក៏ខ្ញុំនិយាយត្រឹមនោះចុះ។ វាដូចថា វាយូរយារឆ្នាំមកហើយដែរហ្នឹង តែខ្ញុំកែ ខ្ញុំមិនបានកែទេ។

**ស៖** តើលោកស្រីយល់ទេ ថាវាមានភាពខុសគ្នា រវាងការដែលយើងឃើញផ្ទាល់ភ្នែក ហើយនិងគ្រាន់តែថា ឮគេនិយាយតគ្នា ថាដូចកូនលោកស្រីនិយាយប្រាប់អីអ៊ីចឹង ដូចលោកស្រីបាននិយាយហើយ ថាលោកស្រីមិនកែប្រែចម្លើយអីទេ ក៏ប៉ុន្តែយើងឃើញថា សំណៅពីរនេះវាខុសគ្នា ពាក្យសម្តីនេះវាខុសគ្នា។ អ៊ីចឹងគឺលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើតុលាការត្រូវយកចម្លើយមួយណារបស់លោកស្រី? ត្រូវយកចម្លើយដែលលោកស្រីកំពុងតែឆ្លើយនៅទីនេះ ឬក៏យកចម្លើយជាលាយលក្ខណ៍អក្សររបស់លោកស្រី?

**ឆ៖** ខ្ញុំនិយាយពីខាងដើម ខ្ញុំថា ចំណែករូបខ្ញុំជាម៉ែនេះមិនបានឃើញទេ តែកូនវានៅលេងជាមួយឪពុក វាឃើញ តែខ្ញុំសួរ។ សួរវាទៅ វាថា ឪពុកវា គេដាក់ឡានទៅបាត់ហើយ ជាមួយ ពូរុន, ពូយ៉ែនោះឯង។ ខ្ញុំនិយាយពីខាងដើម ខ្ញុំចុះលាយលក្ខណ៍អក្សរជាមួយនឹងមជ្ឈមណ្ឌលឯកសារក៏ដោយ ក៏ខ្ញុំនិយាយតែរឿងការពិតតែប៉ុណ្ណោះឯងទេ។

[១១:១៨:២០]

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមលើកពីចំណុចមួយទៀតជាមួយលោកស្រី។ លោកស្រីបានឆ្លើយទៅនឹងមេធាវីនាំមុខ<ដើមបណ្តឹងរដ្ឋប្បវេណី>ថា បន្ទាប់ពីគេចាប់ខ្លួនប្តីលោកស្រីហើយហ្នឹង គេ

បាននាំលោកស្រីទៅបាត់ដំបងដើម្បីឲ្យធ្វើស្រែ។ ថាដំបូងហ្នឹងបញ្ជូនទៅវត្ត ហើយក្រោយមកទៀត ថា បញ្ជូនទៅបាត់ដំបង ដើម្បីឲ្យធ្វើស្រែ។ តើខ្ញុំយល់នេះត្រឹមត្រូវទេ<>?

**ឆ៖** ចាស កន្លែងដូចថា គេចាប់បញ្ចេញខ្ញុំមកជាមួយថ្ងៃប្ដីខ្ញុំនេះ គេឲ្យមកធ្វើស្រែនៅនឹងវត្ត ជ័យឧត្តមនេះទេ។ តែផុតពីនោះទៅ គេឲ្យទៅបាត់ដំបងនោះ អត់មានធ្វើស្រែទេ គ្រាន់តែដើរស្នាក់នៅ ព្រៃប្រទៅមក ទៅមកៗនេះឯង ដូចថា មិនដឹងជាមានបញ្ហាអីៗទេ ចេះតែទៅតាមគេ តាមគ្នីតាមគ្នា មនុស្សវាច្រើន តែប៉ុណ្ណោះឯងទេ។ ធ្វើស្រែនៅវត្តជ័យឧត្តមនោះទេ។

**ស៖** ហើយវត្តជ័យឧត្តមនុ៎ង នៅពេលណាដែរ ដែលគេបញ្ជូនទៅធ្វើស្រែនៅជ័យឧត្តមនោះ?

**ឆ៖** នៅពេលដែលគេបញ្ចេញខ្ញុំមកពីថ្ងៃជាមួយនឹងប្ដីខ្ញុំនេះឯង។ ម៉្លោះហើយ គេឲ្យមកនៅច្រូត ស្រូវបណ្ដោយ។

**ស៖** លោកស្រី ចម្លើយក្នុងចម្លើយពីមុនមកហ្នឹងលោកស្រីថា ពេលដែលគេយកលោកស្រីទៅ ហ្នឹងលោកស្រីមានផ្ទៃពោះ។ អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា ដែលទាំងមានផ្ទៃពោះហ្នឹងគេឲ្យលោកស្រីធ្វើ ស្រែ ឬយ៉ាងម៉េច?

**ឆ៖** ចាស ក្រែងធ្វើដំណើរគេឲ្យចេញមកហើយ មកដល់គេឲ្យច្រូតស្រូវបណ្ដោយខ្ញុំ គេអត់ មានឲ្យសម្រាក។

**ស៖** តើលោកស្រីនៅនឹងវត្តហ្នឹង វត្តជ័យឧត្តមហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

[១១:២១:១៣]

**ឆ៖** ខ្ញុំមិនអាចចាំបានទេ។ ប៉ុន្តែនៅមិនទាន់ច្រូតរួចផង គេបញ្ជូនខ្ញុំធ្វើដំណើរទៅមុខទៀត មិន ដឹងបានប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យទេ ខ្ញុំអត់ចាំបានដែរ។

**ស៖** ឥឡូវខ្ញុំសូមឲ្យលោកស្រីជួយបំភ្លឺលើចម្លើយរបស់លោកស្រី ដែលលោកបានឆ្លើយទៅ សហចៅក្រមស៊ើបអង្កេត អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ខ្ញុំចង់ឲ្យលោក ស្រីកំណត់ពេលវេលាថា លោក<ស្រី>ឆ្លើយនៅពេលណា គឺឯកសារ E3/9479។ នៅចម្លើយ៣១ ដល់ ៣៣ ពេលនោះលោកស្រីនិយាយអំពីរយៈពេលដែលលោកស្រីស្នាក់នៅបាត់ដំបងកាលនោះ។ អ៊ីចឹងខ្ញុំ ចង់ឲ្យលោកស្រីបញ្ជាក់ពីពេលវេលា ថាកាលនៅបាត់ដំបងនោះនៅពេលណាដែរ? “សំណួរ៣១៖ ពេល បាត់ដំបងគេឲ្យលោកស្រីធ្វើការអីដែរ? ចម្លើយរបស់លោកស្រីគឺថា៖ ខ្ញុំទៅដល់បាត់ដំបង គេមិនឲ្យខ្ញុំធ្វើ អីទេ ប៉ុន្តែប្រធានកងបានឲ្យពួកយើងដើររកបន្លែដើម្បីមកធ្វើម្ហូប។ សំណួរបន្តទៀត៖ ថាតើគេឲ្យលោក

ស្រីធ្វើការអីទេ? ចម្លើយ៖ នៅទីនោះគេឲ្យអ្នកនៅលីវទៅប្រមូលស្រូវម៉ោងបួនភ្លឺ ប៉ុន្តែខ្ញុំមានផ្ទៃពោះអ៊ីចឹង គេគ្រាន់តែឲ្យខ្ញុំសម្រាកនៅទីនោះតែប៉ុណ្ណោះ។ សំណួរ៖ តើគេឲ្យលោកស្រីធ្វើការទេ ពេលសម្រាលកូនហើយ? ចម្លើយ៖ ក្រោយសម្រាលកូនហើយ ខ្ញុំទៅភូមិខ្ញុំវិញ។ ខ្ញុំចំណាយពេលអស់មួយរយៈដែរ ទម្រាំទៅដល់ស្រុកកំណើតវិញ។" សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា តើនៅពេលដែលលោកស្រីនិយាយអំពីការធ្វើស្រែនេះ ហើយដែលលោកស្រីនិយាយថា ពេលដែលថាឲ្យលោកស្រី<ធ្វើ> ស្រែទាំងមានផ្ទៃពោះនេះ តើពេលណាដែរ គេឲ្យធ្វើស្រែទាំងមានផ្ទៃពោះនេះ? ក្រោយពីចេញពីភ្នំពេញហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

[១១:២៣:៣៤]

**ឆ៖** ចាស គេឲ្យខ្ញុំធ្វើស្រែដែលច្រូតស្រូវនេះ ក្រោយពីរយៈពេលចេញពីភ្នំពេញមកដល់ ដូចថាមកដល់ថ្ងៃនេះស្អែកឡើងគេឲ្យកាន់កណ្ដៀវច្រូតស្រូវ អត់មានឲ្យពេលសម្រាកឯណា ព្រោះគេ ការងារគេទៅទាំងហ្វូងៗហើយ គេឲ្យពួកខ្ញុំទៅច្រូតស្រូវដែរ។ ខ្ញុំមានផ្ទៃពោះ ពោះប្រាំមួយប្រាំពីរខែក្នុងពោះ ក៏ខ្ញុំមិនហ៊ានប្រកែកគេដែរ ព្រោះអីខ្ញុំខ្លាចគេ ប្ដីក៏បែក កូនក៏តូច មានប្ដីពោះទៀតខ្ញុំអត់ហ៊ានប្រកែកទេ ខ្ញុំធ្វើការរាល់ថ្ងៃនេះដែរ។

**ស៖** អ៊ីចឹងសំណួរខ្ញុំនៅតែដដែលទេ ថាតើនៅបាត់ដំបងនេះ ពេលណាដែលពេលលោកស្រីនិយាយថា កាលនោះគេឲ្យតែពួកនៅលីវទេទៅធ្វើស្រែនោះ? អ៊ីចឹងពេលហ្នឹង ពេលណាដែរនៅបាត់ដំបងនោះដែលគេឲ្យតែអ្នកនៅលីវទៅធ្វើស្រែហ្នឹង?

**ឆ៖** ចាស បើនិយាយទៅខ្ញុំមិនចាំខែដែរ។ បើខែខ្ញុំចេញពីភ្នំពេញ ហើយទៅដល់នោះទៀត មិនដឹងជាខែ៣ -- អំ! ខែ២ ខែ៣ទេ។ គ្រាន់តែខែគេជញ្ជូនស្រូវ មិនមានធ្វើស្រែទេ ខែគេប្រមូលផល អ្នកនៅលីវគេឲ្យកាន់បេកាន់អីទៅជញ្ជូនស្រូវដាក់ឃ្លាំង តែមិនដឹងដាក់ឃ្លាំងឯណាទេ គ្រាន់តែគេថា។ តែខ្ញុំអ្នកមានផ្ទៃពោះនេះគេឲ្យនៅមួយកន្លែង គ្រាន់តែមើលកូនក្មេងតាក់តូច ទម្រាំតែម្ដាយមកដល់វិញ តែប៉ុណ្ណោះហើយទេ។

**ស៖** អ៊ីចឹងឥឡូវហ្នឹងលោកស្រីនិយាយថា ប្រហែលជាខែកុម្ភៈ មីនា ឆ្នាំណាដែរ? ឆ្នាំ៧៨ ឬ៧៩?

**ឆ៖** នៅក្នុងឆ្នាំ៧៨ ដែលចូលជិត៧៩ហើយ។

[១១:២៥:៤៧]

**ស៖** អ៊ីចឹងនេះ ឥឡូវខ្ញុំមានបញ្ហាពីកាលប្បវត្តិនេះ លំដាប់លំដោយពេលវេលានេះ ព្រោះថាបើ

តាមខ្ញុំយល់ នៅពេលដែលគេចាប់ប្ដីលោកស្រីហ្នឹង លោកស្រីចេញដែរ ចេញទៅបាត់ដំបង។ កាលនុ៎ង ខ្ញុំដឹងថា លោកស្រីមានផ្ទៃពោះ៧ខែហើយ។ អ៊ីចឹងបើសិនជាលោកស្រីនិយាយថា ប្ដីរបស់លោកស្រីនេះ ត្រូវបានគេចាប់ខ្លួននៅខែតុលា ឆ្នាំ៧៨នោះ វាមានបញ្ហាហើយ។ លោកស្រីនៅមានផ្ទៃពោះទៀតអ៊ីចឹង? នៅពេលនុ៎ង មាន<ផ្ទៃពោះ>៧ខែនេះ។ <>ខ្ញុំស្មានតែថា លោកស្រីបានទៅបាត់ដំបងហ្នឹង ក្រោយពេលគេចាប់ប្ដីលោកស្រីហើយ គឺថាក្រោយខែតុលា ឆ្នាំ១៩៧៨។ អ៊ីចឹងលោកស្រីច្រឡំពេលវេលាទេដឹង?

**ឆ៖** ចាស ខ្ញុំសុំចម្លើយ។ តែចុះក្នុងឯកសារហ្នឹង ស្ដាប់បានខ្ញុំ វាមិនបាន។ ខ្ញុំមកក្នុងឆ្នាំ៧៨នេះ ខ្ញុំមកចូលឆ្នាំ គេយកខ្ញុំមកចូលឆ្នាំ។ ខ្ញុំរស់នៅជាមួយប្ដីខ្ញុំ គិតទៅពីខែ៤ ចូលឆ្នាំគេហៅថាខែ៤។ ហើយបែកគ្នាដល់ទៅខែប៉ុន្មាន ខែ១២។ ហើយខ្ញុំទម្ងន់ក្នុងពោះ៧ខែ គិតទៅរយៈប៉ុន្មានខែ ខ្ញុំមិនចាំដែរទេ វាដូចថាវាយូរឆ្នាំហើយ។ ខ្ញុំទម្ងន់នឹងពោះ៧ខែ បានប្ដីខ្ញុំនេះ វាបែកពីខ្ញុំទៅ។ ហើយខ្ញុំនៅរស់នៅជាមួយនឹងកូនតូច និងមានផ្ទៃពោះ៧ខែតែប៉ុណ្ណោះឯងទេ។

**ស៖** អ៊ីចឹងសំណួរដែលខ្ញុំសួរនោះ ថាតើលោកស្រីទៅដល់បាត់ដំបងហ្នឹងនៅខែណាដែរ? នៅពេលណាដែរ?

**ឆ៖** ខ្ញុំវាមិនចាំដែរ អារឿងនេះវា ដូចថាជាយូរហើយ ខ្ញុំមិនដឹងថ្ងៃខែ មិនដឹងប៉ុន្មាន ជាប៉ុន្មានដែរ។ ប៉ុន្តែកូនខ្ញុំកើតនៅមោងឫស្សី ដឹងថាកើតខែ៣ វិលពីបាត់ដំបងដើរព្រួចុះព្រួឡើងតាមគេ មកកើតនៅមោងឫស្សី នៅពេទ្យមោងឫស្សីនេះ កើតខែ៣ កើតខែ៣ ឆ្នាំមមី។

[១១:២៨:៣២]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំមានចំណុចមួយទៀត ចង់សួរទៅដើមបណ្ដឹងរដ្ឋប្បវេណីនេះ ពាក់ព័ន្ធនឹងលោក ខៀវ សំផន ប៉ុន្តែលោកប្រធានចង់ឲ្យខ្ញុំបញ្ចប់មុនពេលអាហារថ្ងៃត្រង់ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! ទំនងវែងទេ? ប៉ុន្មាននាទី? ១៥នាទីបានទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំពិបាកប៉ាន់ប្រមាណពេលវេលាដែរ លោកប្រធាន។ ខ្ញុំគិតថាប្រហែលជាយ៉ាងច្រើនបំផុតនោះ

១៥នាទី ក៏ប៉ុន្តែលោកមេធាវី គង់ សំអុន នោះគាត់ចង់ចោទសំណួរដែរ។ អ៊ីចឹងខ្ញុំគិតថា យើងត្រូវការពេលវេលាទៀត។ យើងមិនអាចបញ្ចប់នៅពេលមុនអាហារថ្ងៃត្រង់នេះទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះជម្រាបរំឭកឡើងវិញថា បញ្ហាស្តាប់សក្ខីកម្មសាក្សី 2-TC-1066 អង្គជំនុំជម្រះសម្រេចថា នៅតម្កល់សេចក្តីសម្រេចរបស់ខ្លួននៅតែកោះហៅសាក្សីរូបនេះមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកដដែល ប៉ុន្ទាប់ពីស្តាប់សក្ខីកម្មសាក្សី 2-TC -- ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063។ ហើយចំណែកឯ ឯកសារដែលមានការពាក់ព័ន្ធហ្នឹងគឺនឹង*ហ្វាល*ចូលសំណុំរឿង នៅរៀបចំរួចរាល់នៅពេលអាហារថ្ងៃត្រង់នេះហើយ។ នេះតាមព័ត៌មានដែលយើងទទួលបានពីមន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង។

[១១:៣០:១២]

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ឥឡូវនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រីដើមបណ្តឹង ជម្រាបសួរសាជាថ្មីម្តងទៀត។ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីប្រធានបទចុងក្រោយដែលខ្ញុំចង់ពិភាក្សាជាមួយលោកស្រីនៅរសៀលនេះ គឺថ្ងៃដែលលោកស្រីបានឃើញ ខៀវ សំផន នៅផ្សារថ្មី។ កាលពីម្សិលមិញ ប្រហែលជាម៉ោង០៣:៤១នាទី លោកស្រីបាននិយាយថា លោកស្រីបានឃើញលោក ខៀវ សំផន ប្រហែលជា៥នាទី។ ហើយនៅក្នុងចម្លើយរបស់លោកស្រីជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺឯកសារ <E3/9479> នៅចម្លើយទី៩០ លោកស្រីបាននិយាយថា គាត់មកតែមួយភ្លែតទេ។ ដូច្នេះលោកស្រីទឹកឃើញទេ ថានៅក្នុងឯកសារនុ៎ង លោកស្រីបានឆ្លើយថា ឃើញគាត់ហ្នឹងតែមួយភ្លែតទេ?

[១៣:៣៥:១៣]

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ខ្ញុំឃើញតែមួយភ្លែតមែន។

**ស៖** លោកស្រីបានឆ្លើយថា ប្តីលោកស្រីជាអ្នកប្រាប់ថា គាត់ជា ខៀវ សំផន។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលហ្នឹងជាពេលណាដែរ ដែលលោកស្រីឃើញលោក ខៀវ សំផន? ហ្នឹងពេលព្រឹក ពេលរសៀល ឬក៏ពេលល្ងាច?

**ឆ៖** ចាស ប្រហែលជាម៉ោងប្រាំពីរព្រឹក។ តែគាត់ទៅផុត ខ្ញុំសួរប្តីខ្ញុំ បានខ្ញុំដឹងថា លោក ខៀវ សំផន។

**ស៖** លោក<ស្រី>អាចជម្រាបជូនបានទេ លោកស្រីឃើញលោក ខៀវ សំផន ហ្នឹងនៅកន្លែងណាដែរ នៅក្នុងផ្សារថ្មីហ្នឹង? នៅក្បែរអគារណាមួយ? នៅកន្លែងណាមួយឲ្យពិតប្រាកដទៅនៅផ្សារថ្មីហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គាត់នៅនឹងផ្សារថ្មី នៅនឹងក្នុងផ្សារដែលគេកំពុងចែកចាយម្ហូបអាហារ ប្រជាជនដែលកំពុងទទួលក្នុងពេលព្រឹកនោះឯង។

**ស៖** ខ្ញុំមិនសូវយល់ ខ្ញុំចង់ដឹងអ៊ីចេះលោកស្រី។ នៅផ្សារហ្នឹង មានជាអគារមានជាអី ជាតម្រុយឲ្យយើងដឹងថា គាត់ឈរនៅកន្លែងណា ចែងហ្នឹងឲ្យប្រាកដទេ?

**ឆ៖** ចាស ខ្ញុំវាមិនដឹងឯណាអីជើង ត្បូងផង ដល់ប៉ុនថា បើយល់ខ្ញុំ ខ្ញុំថា វាចេញឈ្វេងមកខាងជើងឈ្វេងផ្សារ ឡាបផ្សារ ខ្ញុំថាឈ្វេងខាងជើង។ ឈរផ្តុំជុំគ្នាទាំងអស់ ទាំងប្រជាជនអ៊ូអរនៅក្នុងផ្សារ និងពួកដែលអ្នកចែកបាយទៅ នៅធ្វើការកន្លែងនោះឯង ក៏នៅ បើនិយាយទៅ បើតាមយល់ខ្ញុំ ខ្ញុំថាឈ្វេងខាងជើង បើខ្ញុំវង្វេង មិនដឹងឯណាជើងត្បូងដែរ។ ប៉ុន្តែនេះជាទិសរបស់ខ្ញុំ ខ្ញុំស្មានទេ ក្នុងទីផ្សារហ្នឹង។

[១៣:៣៧:៥៩]

**ស៖** លោកស្រីស្ថិតនៅចម្ងាយប៉ុន្មានម៉ែត្រដែរពីគាត់?

**ឆ៖** ចាស ខ្ញុំចម្ងាយថា ប្រហែលជាថា ៥ម៉ែត្រចុះ ព្រោះខ្ញុំឈរនៅខាង។ ៥ម៉ែត្រពីគាត់ចុះ បើគាត់ រូបគាត់ច្បាស់ដែរ គាត់ពាក់អាវស កម្ពស់ ដៃខ្លី គាត់ស្លៀកខោខ្មៅ។ បានឃើញរូបរាងគាត់ច្បាស់ដែរ។

**ស៖** ខោគាត់ហ្នឹង ខោពណ៌អីដែរលោកស្រី?

**ឆ៖** ចាស ខោពណ៌ខ្មៅ។

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានឃើញគាត់មួយភ្លែត។ អ៊ីចឹងពេលដែលគាត់ចេញទៅវិញហ្នឹង ពេលចេញពីផ្សារហ្នឹង លោកស្រីឃើញគាត់ដើរចេញទេ?

**ឆ៖** ខ្ញុំត្រង់គាត់ទៅវិញ ខ្ញុំអត់បានឃើញទេ។ តែឃើញគាត់ឈរក្នុងមួយពេលនុំងឯង ខ្ញុំឃើញតែគាត់ចេញទៅវិញ ខ្ញុំអត់បានឃើញទេ។

**ស៖** ចុះលោកស្រីឮគាត់និយាយអ្វីទេ?

**ឆ៖** ចាស អត់មានឮអីទេ។

**ស៖** ហើយចុះប្តីលោកស្រីគាត់នៅឈរកន្លែងណាដែរ នៅក្បែរលោកស្រីហ្នឹងមែនទេ?

**ឆ៖** ចាស គាត់ឈរនៅកន្លែងនោះដែរ។

**ស៖** ប្តីលោកស្រីអត់ធ្វើការទេ នៅថ្ងៃនោះ?

**ឆ៖** ប្តីខ្ញុំខាងចែកបាយ ចែកអី ហុចទៅប្រជាជនដែលនៅក្នុងនោះឯង ធ្វើដំណើរមកនៅស្នាក់

នោះឯង ជាមួយពួកខ្ញុំទាំងអស់គ្នានោះឯង។

[១៣:៤០:៤១]

**ស៖** លោកស្រីបានឆ្លើយថា ហេតុការណ៍ហ្នឹង កើតឡើងនៅម៉ោងប្រាំពីរព្រឹក។ អ៊ីចឹងលោកស្រីនៅផ្សារថ្មីហ្នឹង ពេញមួយព្រឹកតែម្តង ឬក៏លោកស្រីទៅកន្លែងដែលលោកស្រីស្នាក់នៅវិញ?

**ឆ៖** ចាស នៅមិនបានពេញមួយព្រឹកដល់ម៉ោងប្រាំបួន ដប់ទេ គ្រាន់ថានាំគ្នាចែកបាយពួកប្រជាជនហើយ ក៏វិលមកកន្លែងស្នាក់នៅវិញទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែលោកមេធាវី គង់ សំអុន គាត់មានសំណួរមួយចំនួនបន្ថែមទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។ ខ្ញុំបាទ គង់ សំអុន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ្នកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមសួរអ្នកស្រីបន្ត។ ខ្ញុំចង់បញ្ជាក់សួរអ្នកស្រី ទាក់ទងនឹងឈ្មោះប្តីអ្នកស្រីទី១។ នៅពេលដែលអ្នកស្រីបានរៀបការ អ្នកស្រីបានចុះអេតាស៊ីវិលជាមួយគ្នាទេនៅពេលនោះ?

[១៣:៤២:០៧]

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស អង្កាល់ពីសម័យ៧៣ គឺសុំច្បាប់រៀបការ គឺពួកខ្មែរក្រហមគេចុះដល់ហើយ គេធ្វើការ គេហៅថា ឃុំសង្កាត់ តែគេមូលដ្ឋាននេះ ខ្ញុំសុំច្បាប់ ម៉ែឪខ្ញុំសុំច្បាប់ពួកគេនេះឯង។ គេអនុញ្ញាតឲ្យការ បានការបាន។ តែការឆ្នាំ៧៣ ការខ្ញុំនេះនៅមានលោកខ្លះ តិចខ្លះទេ មិនមានលោកច្រើន។ ហើយតែក្រេមម្សៅ គឺគ្មានលាបទេ។ ភ្លេងអីនៅមានលេង ផ្លែឈើអីមាន កាត់សក់។

**ស៖** បាទ សូមអរគុណ។ នៅពេលនោះអ្នកស្រីបានចាំទេថា ប្តីអ្នកស្រីប្រើឈ្មោះអីដែរ ដើម្បីសុំរៀបការជាមួយនឹងអ្នកស្រីហ្នឹង?

**ផ៖** ចាស ឈ្មោះ ខេង ជី។ ពីដើមឈ្មោះ ខេង ជី។

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីធ្លាប់ដឹងឈ្មោះប្ដីរបស់អ្នកស្រី ដែលផ្លាស់ប្ដូរឈ្មោះផ្សេងៗទៀតដែរទេ? ហើយមានឈ្មោះអីខ្លះ?

**ផ៖** ចាស ប្ដីខ្ញុំដែលផ្លាស់ប្ដូរឈ្មោះ កាលមកនៅភ្នំពេញនេះ គេហៅថា ខេង ជី ហៅ ខេង ជឿន តែជីតាគឺ គង់ – គង់ ជី, គង់ ជឿន។ ឈ្មោះដើម ជី, ឈ្មោះបដិវត្តន៍ ជឿន។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងឈ្មោះ គង់ ជី, គង់ ជើន ដែលលោកស្រីនិយាយហ្នឹង គឺលោកស្រីដឹងតាំងពីសម័យឆ្នាំ៧៨ នៅពេលដែលលោកស្រីផ្លាស់មកនៅភ្នំពេញហ្នឹង ឬមួយក៏ទើបតែដឹងក្រោយនេះទេ?

[១៣:៤៤:០១]

**ផ៖** ចាស ដែលបានដំណឹងនេះ គឺបើនិយាយទៅ គេមក -- គាត់មកដាក់ គង់ៗនេះ បើនិយាយទៅ ជីតាគាត់ពិតប្រាកដហើយ ប៉ុន្តែខ្ញុំដឹងតែ គង់ -- ខេង ជី នោះខ្ញុំដឹង។ ដល់មក គង់ ជី, គង់ ជឿន នេះ ខ្ញុំស៊ើបសួរឯស្រុកអីទៅ ថាជីតារបស់គាត់បង្កើតពិតមែន។ ដល់គាត់មកដាក់នឹងកន្លែងឈ្មោះឯកសារនេះគឺ គង់ ជី ហៅ ជឿន តែឈ្មោះពីដើមនោះ ខេង ជី, ខេង ជឿន ប៉ុន្តែជីតា ឪពុកគាត់នោះឯង "គង់" នោះ។

**ស៖** ជីតា ឪពុកហ្នឹង លោកស្រីចង់សំដៅលើអ្វី? លើឈ្មោះតា ឈ្មោះត្រកូល "គង់" ឬមួយក៏យ៉ាងម៉េច? ឬក៏ គង់ ជឿន?

**ផ៖** ចាស ឈ្មោះនេះ គឺខ្ញុំបានជម្រាបថា "គង់"ៗនេះ ឪពុកតាខេង ជាឪពុកបង្កើតឈ្មោះ ជីនេះ ត្រកូលខាងឪពុក។

**ស៖** បាទ សូមអរគុណ។ មានៗអំណានបីដែលខ្ញុំអាចស្ដាប់បានទាក់ទងឈ្មោះហ្នឹង។ ទី១ ឈ្មោះ ជី, ទី២ ឈ្មោះ ជើន និងទី៣ ឈ្មោះ ជឿន។ អ្នកស្រីអាចបញ្ជាក់ឲ្យច្បាស់ទេ ថាឈ្មោះណាមួយដែលជាឈ្មោះប្ដីអ្នកស្រីពិតប្រាកដ?

**ផ៖** ឈ្មោះប្ដីខ្ញុំគឺ "ជ" ដាក់ស្រះ "ី" ហើយនិង "ជ" ដាក់ស្រះ "ឿ" ដាក់នឹង "ន"។ ឈ្មោះបដិវត្ត "ជ" ដាក់ស្រះ "ឿ" ឈ្មោះដើម "ជ" ដាក់ស្រះ "ី"។

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលដែលអ្នកស្រីតាំងខ្លួនជាដើមបណ្ដឹងដំបូង ជាពិសេសនៅពេលដែលអ្នកស្រីឆ្លើយចំពោះមុខអង្គជំនុំជម្រះនេះ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ អ្នកស្រីបាន

ឆ្លើយនៅត្រង់ម៉ោងប្រហែលជា១០:០៣ ថាប្ដីអ្នកស្រីហ្នឹងឈ្មោះ ហេង ពុន ហៅ ជុន។ អ៊ីចឹងឈ្មោះនេះអ្នកស្រីបានមកពីណា?

**ឆ៖** ចាស អត់ទេ ខ្ញុំមិនដែលមានឈ្មោះ ពុន, ជុន អីអត់មានទេ។ ខ្ញុំមិនដែលបាននិយាយពាក្យនេះទេ អត់មាន។

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន។ សូមអនុញ្ញាតឲ្យមេធាវីខាងការពារក្ដីជួបបង្ហាញបញ្ជាក់ពីឯកសារម្ដងទៀត។ អម្បាញ់មិញហាក់ដូចនិយាយថាលោកស្រីបានឆ្លើយចំពោះតុលាការតែឆ្នាំ២០០៩ ហាក់ដូចជាខ្ញុំមិនបានស្ដាប់ច្បាស់លាស់អំពីបញ្ហាហ្នឹង។ សូមជួយបញ្ជាក់បន្តិច។

**លោក គង់ សំអុន៖**

បាទ សូមបញ្ជាក់ម្ដងទៀត គឺឯកសារនៅចំពោះមុខអង្គជំនុំជម្រះ អានេះជាសំណុំរឿង០០១ ហើយដែលមានថ្ងៃទី១២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ម៉ោង១០:០៣។

**ប្រធានអង្គជំនុំ៖**

មើល១ប្រតិចារឹកលេខប៉ុន្មាន?

**លោក គង់ សំអុន៖**

E1/78.1។

[១៣:៤៩:០៦]

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំសូមបន្តទៀត។ ហើយស្របគ្នានឹងដែរ ក៏មានឯកសារមួយទៀតដែលជាឯកសារបញ្ជាក់ដោយមេធាវី ខាងក្រុមមេធាវីរបស់លោកស្រីគឺមានចំណងជើងថា "ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ សារណាសន្និដ្ឋានចុងក្រោយ" ដែលមាន ខ្ញុំសូមអានឯកសារលេខ D288/6.159/7។ នៅក្នុងកថាខណ្ឌ៧០បានសរសេរថា៖ "ជនរងគ្រោះផ្ទាល់ ហេង ពុន ឬ ជន ហៅ ជុន ជាស្វាមីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីខៀវ នាប" ហើយដែលមានលេខយោងគឺ (E2/75) ហើយមានលេខ២០៤។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកស្រី ថាតើលោកស្រីដែលបានផ្ដល់--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកអានលេខឯកសារម្ដងទៀត ព្រោះថាអ្នកបកប្រែបកអត់ទាន់។

**លោក គង់ សំអុន៖**

បាទ សូមបញ្ជាក់ឯកសារម្តងទៀត គឺលេខ D288/6.159/7 ត្រង់កថាខណ្ឌទី៧០។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា តើលោកស្រីធ្លាប់ផ្តល់ឈ្មោះ ហេង ពុន ថាជាប្តីរបស់អ្នកស្រីទៅឲ្យក្រុមមេធាវីរបស់អ្នកស្រីដែរទេ?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ខ្ញុំមិនដែលទេ មិនដែលមានពាក្យនេះយកមកដាក់ផ្តល់ព័ត៌មានអី អត់ មិនដែលមានទេ។

[១៣:៥១:៤១]

**ស៖** បាទ សូមអរគុណ។ មុននេះអំមិញលោកស្រីបញ្ជាក់ថា ប្តីលោកស្រីអាចប្រើឈ្មោះត្រកូលរបស់ខាងជីតាដែលមានឈ្មោះ គង់។ ហើយលោកស្រីបញ្ជាក់ថា គង់ ជឺ ដែលលោកស្រីបញ្ជាក់ថា ជាឈ្មោះដើម ហើយឈ្មោះបដិវត្តន៍ គង់ ជឿន តើអ្នកស្រីនិយាយអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំនិយាយអ៊ីចឹងហើយតើ។

**ស៖** ខ្ញុំចាំម្សិលមិញ ខ្ញុំនឹងរកទីតាំងឲ្យ តែខ្ញុំសូមសួរជាមុនសិន។ ម្សិលមិញអ្នកស្រីឆ្លើយថា ជីតារបស់ប្តីលោកស្រី គឺឈ្មោះ គង់ ជឺ តើអ្នកស្រីបានមានប្រសាសន៍អ៊ីចឹងទេ?

**ឆ៖** ចាស ខ្ញុំថា ជីតាគាត់ឈ្មោះ គង់ ហើយក៏ដាក់ គង់ ជឺ , គង់ ជឿន តែខ្ញុំនោះ ហៅតែ ខេង ជឺ, ខេង ជឿន តែជីតាគាត់ទេ ឪពុក តាខេង នោះ។ ខេង ជឺ, ខេង ជឿន។ តែដល់ពេលគាត់នេះ គាត់ប្រែត្រកូល ខ្ញុំអត់ដឹងដែរ ស្រាប់តែមកឃើញ ប៉ុន្តែជីតាគាត់បង្កើតរបស់ តាខេង នោះ ដែលឪ ជឺ នោះឈ្មោះ តាខេង។ ឪ ជឺ ឈ្មោះ តាខេង។ តាខេង នេះឪពុកគាត់ ឈ្មោះ គង់ បានគាត់យក ជីតាគាត់ដាក់នេះ បានខ្ញុំដឹង ឃើញឯណោះ បានដឹងថាជីតារបស់គាត់ពិតប្រាកដមែន។

**ស៖** អ៊ីចឹងសូមបញ្ជាក់ឡើងវិញ អ៊ីចឹងមិនមែនមានន័យថា ឈ្មោះ គង់ ជឺ ជាជីតាទេ គឺឈ្មោះ គង់ ខេង អ៊ីចឹងមែនទេ? ត្រូវជាជីតានោះ ឈ្មោះអី ឈ្មោះមែនទែនទៅ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ឈប់! ឈប់! ឥឡូវខ្មែរបើខ្ញុំសរុបមក គ្រប់គ្រាន់ហើយ។ ឈ្មោះ គង់ ហ្នឹងគឺឈ្មោះ ជីតា ឈ្មោះ

ខេង ហ្នឹងឈ្មោះឪពុកបង្កើតរបស់ប្ដីគាត់ ដែលគាត់ភ្ជាប់ជាមួយនឹងឈ្មោះឪពុក -- ជាមួយប្ដីរបស់គាត់ទេ បានទៅជាអ៊ីចឹងនោះ។ អ៊ីចឹងឈ្មោះចុងក្រោយនេះ ឈ្មោះប្ដីរបស់គាត់។ អ៊ីចឹងម្ដងយកត្រកូលឪពុក ម្ដងយកត្រកូលជីតា។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ម្សិលមិញនៅម៉ោង០៣:៤៩នាទី គាត់ -- លោកស្រីបានបញ្ជាក់ថា គង់ ជី ហ្នឹងជាជីតា បានន័យថា ប្ដីរបស់លោកស្រីហ្នឹងមានជីតាឈ្មោះ គង់ ជី អ៊ីចឹងហើយបានខ្ញុំសួរបញ្ជាក់ទៅលើឈ្មោះនេះ។ លោកស្រីបានឆ្លើយអ៊ីចឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកអ៊ីចេះ! ឥឡូវសួរអ៊ីចេះ បានងាយ លោកសួរថា តើជីតារបស់ប្ដីលោកគាត់ហ្នឹងឈ្មោះអី? ហើយឪពុកបង្កើតរបស់ប្ដីគាត់ឈ្មោះអី? នុ៎ងបានយល់។ ងាយស្រួលឆ្លើយ អ៊ីចឹងគឺឆ្លើយមិនត្រូវទេណា៎។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទឥឡូវសុំលោកស្រីឆ្លើយតាមសំណួររបស់លោកប្រធានទៅថា ជីប្ដីរបស់លោកស្រីឈ្មោះអ្វី?

**លោកស្រី ខៀវ នាប៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១៣:៥៥:២៧]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! ចាំៗក្បាលមីក្រូហ្វូនសិនណា៎!

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ជីតាគាត់ឈ្មោះ គង់។ ឪពុកឈ្មោះ ខេង។ ជីតា ជី ឈ្មោះ គង់។ ឪពុក ជី ឈ្មោះ ខេង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អត់មានឈ្មោះពេញរបស់ជីតាហ្នឹងថា ឈ្មោះអីទេ មានតែឈ្មោះ គង់ មួយម៉ាត់អ៊ីចឹងឬមួយយ៉ាងម៉េច?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** សូមអញ្ជើញឆ្លើយមក អំមិញព្រោះអត់ទាន់បើកក្បាលមីក្រូ។

**ឆ៖** ចាស ខ្ញុំមានដូចថា វាក្មេងសាមួយជំនាន់ប្ដីខ្ញុំដែរ ខ្ញុំមិនស្គាល់ត្រកូលពីដើម ចាស់ពីដើមអស់ទេ ខ្ញុំមិនស្គាល់គាត់ទេ។ ស្គាល់ត្រឹម គង់, ខេង ហ្នឹងឯង។

**ស៖** លោកស្រីអាចបញ្ជាក់ពីឈ្មោះថា គង់ ជី ហៅ ជឿន ដែលលោកស្រីចាត់ទុកថា ប្ដីទី១ របស់លោកស្រីហ្នឹង លោកស្រីដឹងពីវត្តមានថាគាត់ ថាឈ្មោះហ្នឹងនៅស-២១ហ្នឹងនៅពេលណា? លោកស្រីអាចបញ្ជាក់បានទេ?

[១៣:៥៧:១៨]

**ឆ៖** ចាស ខ្ញុំអាចមិនដឹងដែរ ពីនៅស-២១ ពីនៅពេលណាៗខ្ញុំអត់ដឹងដែរ។ ដឹងពីពេលប្ដីខ្ញុំបាត់សូន្យនេះ ខ្ញុំចេះតែស្រាវជ្រាវរកហ្នឹងឯង។

**ប្រធានអង្គជំនុំ៖**

ការស្រាវជ្រាវរបស់លោកស្រីនុ៎ង លោកស្រីបានទទួលដំណឹងថា ប្ដីរបស់លោកស្រីហ្នឹងមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសនៅស-២១ ដំណឹងដែលលោកស្រីទទួលបាននុ៎ង ទទួលបានពីពេលណាមក? សំណួរហ្នឹងបានសួររួចហើយ ប៉ុន្តែដើម្បីបញ្ជាក់ឱ្យច្បាស់លាស់ម្ដងទៀតមើល ថាលោកស្រីបានទទួលដំណឹងហ្នឹងពីពេលណាមក? ហើយអ្នកណាជាអ្នកប្រាប់លោកស្រី?

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ខ្ញុំបានទទួលដំណឹងនេះក្នុងរយៈពេលស្រាវជ្រាវ មេធាវីស្រាវជ្រាវទៅឃើញក្នុងពេលរយៈមួយជាងនេះទេ។ ពីខែ ប៉ុន្មាន ខែ១០ហ្នឹង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ចុះកាលពីសំណុំរឿង០០១ តាមព័ត៌មានដែលមេធាវីនាំមុខរបស់អ្នកស្រីពីម្សិលមិញ ថាលោកស្រីត្រូវបានដកចេញពីសំណុំរឿង០០១ ដោយសារតែមិនមានជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងហ្នឹងផ្ទាល់ ដែលឈ្មោះប្ដីលោកស្រីហ្នឹងរកមិនឃើញ។ តើអ៊ីចឹងមែនទេ?

[១៣:៥៩:៥៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសុំការបញ្ជាក់បន្តិច។ ប្រសិនបើយើងមើលទៅលើប្រតិចារឹក ខ្ញុំចាំថានៅពេលនោះគឺមានបញ្ជី

គឺថាមានបញ្ជីដែលត្រូវបានកែសម្រួលរួចហើយ។ ឥឡូវហ្នឹងយើងមានបញ្ជីថ្មី ហើយយើងមានបញ្ជីច្រើន។ ប្រសិនបើខ្ញុំយល់ខុស ជួយកែផង។ ប៉ុន្តែថាតើវាមានហេតុដូចថា បញ្ជីដែលដាក់នៅក្នុងសំណុំរឿង០០១ ហើយត្រូវបានបដិសេធហ្នឹង អត់មានឈ្មោះនោះទេ។ តើអ៊ីចឹងមែនទេ ឬក៏យ៉ាងម៉េចដែរ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

ខ្ញុំមិនដឹងថា លោកស្រីចៅក្រមឲ្យខ្ញុំបញ្ជាក់ ឬក៏យ៉ាងម៉េច? ខ្ញុំយល់ថា លោកស្រីចៅក្រមយល់ត្រឹមត្រូវហើយ។ បញ្ជីដែលយើងបាននិយាយរយៈពេលពីរថ្ងៃមកហើយ ដែលមានឈ្មោះប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង កាលនុំងគឺអត់ទាន់មានទេ នៅឆ្នាំ២០០៩ហ្នឹង ទើបតែមើលឃើញក្រោយពេលដែលមានបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត។ ហេតុហ្នឹងហើយបានជា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ មិនត្រូវបានទទួលយកនៅក្នុងសំណុំរឿង០០១ ដោយសារ<ឭសនកម្ម> <>មិនមានទំនាក់ទំនងគ្រប់គ្រាន់ <ទៅនឹងមន្ទីរ ស-២១ទេ>។ ហើយឥឡូវនេះ វាស្ថានភាពខុសគ្នា យើងទទួលបានបញ្ជីថ្មី ដែលមិនមាននៅឆ្នាំ២០០៩ហ្នឹង ហើយនៅក្នុងបញ្ជីថ្មីហ្នឹង គឺមានឈ្មោះរបស់ប្តីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយក្នុងភាសាបារាំងហ្នឹង ខ្ញុំគិតថា មានការភ័ន្តច្រឡំ។ យើងមានអារម្មណ៍ថា មេធាវីថាបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០១ តាមពិតមិនមែនអ៊ីចឹងទេ។ បើខ្ញុំពិនិត្យមើលសម្រង់ប្រតិចារឹកហ្នឹង គឺគ្រាន់តែជាសេចក្តីសន្និដ្ឋានរបស់មេធាវីទេ មិនមែនជាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងសំណុំរឿង០០១ទេ។ ខ្ញុំមិនដឹងថាតើគេបកប្រែជាភាសាបារាំងមកឲ្យខ្ញុំហ្នឹងត្រូវ ឬក៏អត់ទេ។ អ៊ីចឹងមេធាវីជាតិគាត់សូមបញ្ជាក់បន្តិច។

[១៤:០១:១៧]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ អ្វីដែលបានលើកដោយលោកមេធាវីគង់ សំអុន ថាជា*ត្រេនស្ក្រីប*នៃ ជាប្រតិចារឹកសក្ខីកម្មរបស់លោកស្រីដើមបណ្តឹងរដ្ឋប្បវេណីនេះ ហើយដែលលោកបាននិយាយថា មានវគ្គខណ្ឌ៧១នោះ គឺជាសេចក្តីសន្និដ្ឋានចុងក្រោយរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុមទី១ ដែលមានលេខឯកសារ D288/6.159។ ហើយដូច្នេះ មិនមែនជាឯកសារមិនមែនជាប្រតិចារឹកផ្ទាល់មាត់ ដែលគាត់បាននិយាយផ្ទាល់មាត់ចំពោះអង្គជំនុំជម្រះទេ។ ហើយខ្ញុំសូមៗអនុញ្ញាតបញ្ជាក់បន្ថែមបន្តិច គឺកថាខណ្ឌ៧០។ ហើយនៅក្នុងកថាខណ្ឌ៧០ហ្នឹង គឺជាភាសាខ្មែរបានសរសេរថា ប្តីរបស់លោកស្រីឈ្មោះ ហេង ពុន ឬ ជុន ហៅ ជុន ហើយគេបានយោងទៅឯកសារជា

ភាសា -- ឯកសារដើមដែលជាពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ដែលគេដាក់នៅពេលនោះ ដែលមានលេខឯកសារ E2/75។ ឯកសារនេះសរសេរ ជាឯកសារដូចគ្នាសុទ្ធសាធដែលយកមកដាក់ប្រើប្រាស់នៅក្នុងករណី០០២។ នេះដែលនៅក្នុងនោះលោកស្រីបាននិយាយថា ប្ដីរបស់លោកគាត់ឈ្មោះ ហេង ជឿន ឬ ហេង ជឺន។ ដូច្នេះពាក្យដែលគាត់បកប្រែជាភាសាខ្មែរនៅពេលនោះ និយាយថាជា ហេង ពុន ឬ ហេង ផុន ហៅ ផុន នោះគឺជាពាក្យមិនត្រូវទេ ហើយលោកស្រីរូបនេះ គាត់មិនដែលប្រើទេពាក្យនេះ។ ក៏ប៉ុន្តែមេធាវីនៅក្នុងករណី០០១ គាត់បានប្រើពាក្យនោះខុស ដោយហៅថាប្ដីរបស់គាត់ឈ្មោះ ហេង ផុន ឬ ផុន ហៅ ផុន។ តែនៅក្នុងពាក្យសុំរបស់លោកស្រីដែលពីមុន ហើយជាពាក្យដដែល ដែលយកមកដាក់ករណី០០២គឺប្រើពាក្យ ហេង ជឿន ឬ ហេង ជឺន តែប៉ុណ្ណោះ។ សូមអរគុណលោកប្រធាន។

[១៤:០៣:៣៧]

**លោក គង់ សំអុន៖**

បាទ--

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំសុំឆ្លើយតបទៅលោកស្រីចៅក្រម ហ្វេនស៍។ បន្ថែមទៅលើបញ្ជីដែលដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើង។ ខ្ញុំសុំបញ្ជាក់បញ្ជីមួយទៀតដែលមានឈ្មោះប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងមិត្តភក្តិពីរនាក់របស់គាត់គឺឯកសារ E3/1974 គឺបញ្ជីនេះធ្វើដោយការិយាល័យសហព្រះរាជអាជ្ញា។ ឈ្មោះនេះគឺមាននៅ គឺមានបានបញ្ជាក់រួចហើយ។ អ៊ីចឹងខ្ញុំមិនដឹងថា តើមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ហ្នឹង គាត់រកមិនឃើញដោយសារតែវា អក្ខរាវិរុទ្ធសរសេរខុសគ្នា ប្រហែលជាអ៊ីចឹងហើយមើលទៅ។

**លោក គង់ សំអុន៖**

បាទ លោកប្រធាន ខ្ញុំសុំអនុញ្ញាតបន្ត។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំចង់បញ្ជាក់ទៅលើបញ្ហាឈ្មោះនេះគឺ ដោយសារទាក់ទងទៅនឹងឯកសារមួយ គឺឯកសារ E3/342។ ត្រង់ ERN ជាភាសា មានភាសាទាំងអស់ ព្រោះក្នុងនេះមានភាសាខ្មែរ និងអង់គ្លេសជាមួយគ្នាគឺ 00329780។ ហើយដែលជាឯកសារមួយធ្វើដោយការិយាល័យសហព្រះរាជអាជ្ញា តាំងពីថ្ងៃទី

១៩ ខែ៥ ឆ្នាំ២០០៩ ហើយដែលមាននៅក្នុងលេខរៀង៤២៧ មានឈ្មោះ គង់ ជឹ ហៅ ជឿន។ តួនាទីគឺ យុទ្ធជនផ្គត់ផ្គង់ផ្សាររដ្ឋ។ ដូច្នេះនៅក្នុងឯកសារនេះ បានន័យថា មានឈ្មោះនេះតាំងពីៗមុនមក មិនមែនដូចការលើកឡើងរបស់មេធាវីនាំមុខថា ទើបតែឃើញនៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើបញ្ជីនោះទេ។ អ៊ីចឹងខ្ញុំចង់សុំអនុញ្ញាតសួរបន្ត។ ខ្ញុំចង់សួរបញ្ជាក់អ្នកស្រីថា តើប្ដីអ្នកស្រីដែលធ្លាប់ប្រើឈ្មោះ គង់ ជឹ ពីមុនមកដែរទេ?

[១៤:០៦:២៥]

**លោកស្រី ខៀវ នាប៖**

**ឆ៖** ចាស ពីដើមមកគាត់ ដូចថាខ្ញុំវាមិនសូវដឹងដែរត្រង់ គង់ ជឹ, គង់ ជឿន នោះ ប៉ុន្តែថាជីតារបស់គេ តែខ្ញុំស្គាល់តែឪពុកគាត់បង្កើត ក៏ខ្ញុំហៅ ខេង ជឹ, ខេង ជឿន ដែរ។ តែគាត់ៗដើរធ្វើការ គាត់ដាក់ត្រកូល "គង់"ៗ ខ្ញុំមិនអាចដឹងដែរ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយ បាទជាចុងក្រោយនេះ លោកស្រី ខៀវ នាប លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការ ស្ដាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ដែលនាំឲ្យប៉ះពាល់ដល់លោកស្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណង និងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងពីព្យសនកម្ម ការខូចខាតសម្ភារៈ ផ្លូវកាយ ផ្លូវចិត្ត និងផលវិបាកដែលកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

[១៤:០៧:៥៥]

**លោកស្រី ខៀវ នាប៖**

ចាស នាងខ្ញុំ គឺមានតែការទុក្ខសោកពីសម័យ៣ឆ្នាំ គឺខ្ញុំ គឺការទុក្ខសោក វាច្រើនដំណាក់ ដូចថានៅជាមួយគ្រួសារ វាមានការលំបាក ចំពោះដែលខ្ញុំមានផ្ទៃពោះ ធ្វើដំណើរចេញ។ គេឲ្យខ្ញុំចេញដំណើរទៅពីភ្នំពេញទៅតាមផ្លូវជាតិលេខប៉ុន្មានទេ ទៅបាត់ដំបង ពោធិ៍សាត់នោះ ខ្ញុំចេះតែដើរតាមគេទៅ ណា

មានផ្ទៃពោះ ណាកូនតូច។ ហើយខ្ញុំចេះតែដើរទន្ទឹងរកមើលប្តី ក៏មិនឃើញ ឃើញតែគេ ក៏ចេះតែរសាត់ទៅដល់បាត់ដំបង។ ចេញពីបាត់ដំបងមកវិញ ក៏ខ្ញុំចេះតែរកមើល។ រកមើលមិនឃើញ ហើយរហូតដល់ខ្ញុំហ្នឹងមកកើតកូននៅនឹងមោងឫស្សី។ ហើយក៏ខ្ញុំកើតបានតែ៣ថ្ងៃទេ ខ្ញុំស្ពាយកូនដើរដល់ផ្ទះ បានដល់៣ខែ ដើរសម្រាក ដើរសម្រាក។ ហើយទុក្ខសោកបោកខ្លួនរបស់ខ្ញុំ គឺខ្ញុំមាន ដូចថាមានច្រើន ទុក្ខវេទនានោះ វាមានហើយ។

ហើយខ្ញុំសូមសួរលោក ខៀវ សំផន ដែលគាត់ថា ធ្វើបដិវត្តន៍ ខ្ញុំសួរមួយសំណួរ។ ធ្វើបដិវត្តន៍ដើម្បីរំដោះប្រជាជន ប្រជាពលរដ្ឋដែលរងការលំបាកពីសម័យរបប ដែលសម័យរាស្ត្រនិយមនោះ គាត់ថា ឃើញប្រជាពលរដ្ឋវេទនា ចងការបណ្តាក់លុយស្រូវអង្ករ ឲ្យគាត់ធ្វើបដិវត្តន៍ដើម្បីរំដោះប្រជាជន។ តែចុះគាត់ធ្វើបដិវត្តន៍រំដោះប្រជាជនហើយ ចុះហេតុអីបានជាប្រជាជនដែលត្រូវស្លាប់ដូចជាស្រមោចសង្ការ តើគាត់នៅឯណា? ក៏គាត់មិនមើលឃើញប្រជាពលរដ្ឋដែលរងទុក្ខវេទនា? ម៉េចគាត់ថា មិនដឹង? នេះ ខ្ញុំសូមសួរសំណួរដែលៗគាត់ជាមេដឹកនាំក្នុងប្រទេសកម្ពុជាទាំងមូល។ ចាស ខ្ញុំសូមអស់មតិ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនលោកស្រី ខៀវ នាប ថានៅក្នុងកិច្ចដំណើរសវនាការលើអង្គសេចក្តីពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ តាំងពីដើមដំបូងទីនៃសវនាការ ជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន បានឆ្លើយថាគាត់អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួររបស់ភាគី ឬចៅក្រមនៃអង្គជំនុំជម្រះ។ ហើយនៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ជនជាប់ចោទទាំងពីររូប ឆ្លើយបញ្ជាក់បន្ថែម ពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីររូប ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបមកយល់ព្រមឆ្លើយតបនឹងសំណួរនោះឡើយ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបដែលថា អង្គជំនុំជម្រះតាមច្បាប់ជាធរមាន អង្គជំនុំជម្រះមិនមានសិទ្ធិក្នុងការបង្ខំឲ្យជនជាប់ចោទឆ្លើយតបនឹងសំណួររបស់ភាគី ឬរបស់ចៅក្រម របស់អង្គជំនុំជម្រះឡើយ សូមលោកស្រីជ្រាប។

[១៤:១១:០៨]

បាទ ហើយអង្គជំនុំជម្រះអរគុណលោកស្រី ខៀវ នាប។ សវនាការស្តាប់សក្ខីកម្ម និងថ្លែងរៀបរាប់ពីទុក្ខសោកវេទនា និងព្យសនកម្មរបស់លោកស្រីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដល់ពេល

នេះ ដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកស្រីនឹងអាចរួមវិភាគទានក្នុងស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកស្រីនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកស្រីអាចវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនដើមបណ្តឹងរដ្ឋប្បវេណីវិលត្រឡប់ទៅកាន់លំនៅឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកដែរហើយ អង្គជំនុំជម្រះសម្រាកចាប់ពេលនេះតទៅរហូតដល់ម៉ោងពីរ និងសាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:១២ នាទី ដល់ម៉ោង ១៤:៣១ នាទី)*

[១៤:៣០:៥៦]

**ក្រឡាបញ្ជី៖**

បាទ សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការតទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063។ មុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ថា ដើមបណ្តឹងរូបនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ដើមបណ្តឹងរូបនេះ ស្ថិតនៅក្នុងក្រុម "ក" នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន (ឯកសារ E319/35)។ ហើយបានស្នើថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គួរគប្បីប្រើរហស្សនាម ក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការមានកម្រិតបែបនេះ គឺត្រឹមត្រូវ សមស្របតាមច្បាប់ក្នុងករណីជាក់ស្ដែងបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវឱ្យមានតុល្យភាពគ្នារវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកផងដែរថា ភាគីឱ្យគោរពខ្ជាប់ខ្ជួននូវសេចក្ដីណែនាំ នៅក្នុងឯកសារ E319/7 ក្នុងករណីប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

ហើយមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី 2-TCCP-1063 មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:៣៤:៣០]

សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងនឹងមិនប្រើប្រាស់ -- យើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោកតែប៉ុណ្ណោះ ហើយលោកមានរហស្សនាម 2-TCCP-1063។ ជាទូទៅ និងជាធម្មតា គឺភាគី រួមទាំងអង្គជំនុំជម្រះពាក់ព័ន្ធផង គឺតែងតែហៅលោកក្នុងនាមលោកដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ។ អ៊ីចឹង សូមលោកយល់ថា អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំជម្រះខ្លួនឯងផង ប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះឡើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារ E -- នេះឯកសារនេះ។ បាទ ឯកសារ E3/10670a ដែលអង្គជំនុំជម្រះឱ្យមន្ត្រីរដ្ឋបាលតុលាការយកទៅប្រគល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះឱ្យលោកពិនិត្យ ហើយបញ្ជាក់អំពីអត្តសញ្ញាណដែលនៅក្នុងឯកសារ E3/10670a ដែលមានលេខ ERN ជាភាសាខ្មែរ 00397755 ដល់7756, ERN ជាភាសាអង់គ្លេស 00422199 ដល់ 004222 មិនមានភាសាបារាំងទេ។ ហើយសូមដើមបណ្ដឹងរដ្ឋប្បវេណីមើល។ នៅត្រង់ចំណុច*ហាយឡាយ*ពណ៌ទឹកក្រូច។ យើងឱ្យអំមិញ E3/10670a។ សូមដើមបណ្ដឹងរដ្ឋប្បវេណីពិនិត្យកន្លែងដែលមាន*ហាយឡាយ*ពណ៌ទឹកក្រូច តើនាមត្រកូល និងនាមខ្លួនរបស់លោក ទីកន្លែងកំណើត សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធ

និងចំនួនកូនរបស់លោក ព្រមទាំងទំព័របន្ទាប់ គឺអំពីអាសយដ្ឋានបច្ចុប្បន្នរបស់លោក តើសរសេរនេះពិតជាត្រឹមត្រូវដែរឬទេ? ហើយដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែឆ្លើយថា ព័ត៌មាននេះ ពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវចំណុចណាបានហើយ ដើម្បីយើង ដោយមិនបាច់បង្ហាញនូវអត្តសញ្ញាណឈ្មោះដែលយើង *ហាយឡាយ*នោះទេ។ បើត្រឹមត្រូវ គ្រាន់តែឆ្លើយបញ្ជាក់ថា សរសេរនេះគឺត្រឹមត្រូវហើយប៉ុណ្ណោះ។ ជាការគ្រប់គ្រាន់ហើយ។

[១៤:៣៨:១១]

**2-TCCP-1063៖**

**ឆ៖** ត្រឹមត្រូវ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការផ្ដល់សក្ខីកម្មនៅថ្ងៃនេះ ក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះ ហេតុដូច្នេះនៅក្រោយពេលបង្អស់នៃកិច្ចដំណើរការសវនាការ អង្គជំនុំជម្រះផ្ដល់សិទ្ធិឱ្យលោកធ្វើសេចក្ដីថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកធ្វើដូច្នេះ។ ហើយការនេះ យើងនឹងរំឭកលោកម្ដងទៀត នៅចុងបញ្ចប់នៃការផ្ដល់សក្ខីកម្មរបស់លោក។

ក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសហមេធាវីនាំមុខ រួមទាំងតំណាងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការសួរដេញដោលសាក្សីរូបនេះ -- ក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមអនុញ្ញាតផ្ទេរសិទ្ធិជូនលោកស្រីមេធាវី ទ្វី ស្រ៊ីនណា ដើម្បីសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:៣៩:៤៤]

**លោកស្រី ទី ស្រ៊ុនណា៖**

ជាបឋម នាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ទី ស្រ៊ុនណា ជាមេធាវីរបស់លោក ហើយខ្ញុំនឹងធ្វើការតាំងសំណួរដល់លោកដូចតទៅ។ ដោយសារតែខ្ញុំពិនិត្យឃើញថា លោករាងផ្លង់ត្រចៀក ហើយបើសិនជាករណីដែលខ្ញុំសួរទៅ មានការមិនច្បាស់លាស់អី សូមលោកអាច -- មិនច្បាស់ ឬក៏ស្តាប់មិនសូវបានអី សូមលោកជួយសួរខ្ញុំឡើងវិញ។

**ប្រធានអង្គជំនុំ៖**

បើដូច្នេះសូមលោកមន្ត្រីរដ្ឋបាលតុលាការ កែសម្រួលអាចដំឡើងសំឡេងនូវឧបករណ៍របស់គាត់ឲ្យឡើងសំឡេងខ្ពស់បន្តិចទៅ។ បាទ សូមអញ្ជើញ!

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ជាដំបូងខ្ញុំចង់សួរលោកថា កាលពីសម័យ លន់ នល់ លោកនិងក្រុមគ្រួសារលោក រស់នៅឯណាដែរ លោក?

[១៤:៤១:០៩]

2-TCCP-1063៖

**ឆ៖** បាទ កាលសម័យ លន់ នល់ ខ្ញុំរស់នៅក្នុងទីរួមខេត្តស្វាយរៀង។ ហើយក្នុងពេលនោះខ្ញុំបានធ្វើជាទាហាន លន់ នល់។

**ស៖** សូមអរគុណ។ ចុះសមាជិកក្រុមគ្រួសាររបស់លោក មានចំនួនប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ ក្នុងសមាជិកគ្រួសារខ្ញុំបាទ ទាំងអស់មានចំនួនប្រាំបីនាក់។ មានឪពុកឈ្មោះ ព្រាប ឈិន, ម្តាយឈ្មោះ សុខ ញ៉េប, បងប្រុសឈ្មោះ សុខ ពិល, បងស្រីឈ្មោះ ព្រាប សុន, ប្អូនប្រុសឈ្មោះ ព្រាប ឈាន, ប្អូនស្រីឈ្មោះ ព្រាប ទឹម រួមត្រង់ឈ្មោះខ្ញុំ ឈ្មោះ 2-TCCP-1063។

**ស៖** សូមអរគុណពូ។ ខ្ញុំសូមជម្រាបជូនពូ ដោយសារលោកសាក្សី -- លោកដើមបណ្តឹង ដោយសារឈ្មោះលោកត្រូវបានការពារ អ៊ីចឹងសូមលោកកុំបញ្ចេញ ហើយខ្ញុំសង្ឃឹមថា ពីពេលនេះតទៅ កុំប្រើរហស្សនាម កុំប្រើឈ្មោះខ្លួនឯងទៀត។ អ៊ីចឹងខ្ញុំសូមឲ្យលោកនិយាយថា "ខ្ញុំ" បានហើយ។ ចាស អរគុណ។ អំឡុងពេលនោះ លោកមានអាយុប៉ុន្មានដែរ? ហើយលោកធ្វើអីដែរ នៅពេលនុ៎ង?

**ឆ៖** បាទ ក្នុងពេលនោះខ្ញុំមានអាយុ២៥ឆ្នាំ។ ហើយខ្ញុំកាលនោះ ខ្ញុំនៅកសិករ។ ដល់ក្រោយមក បានគេជំរឿនខ្ញុំ ឲ្យចូលជាទាហាន លន់ នល់។

[១៤:៤៣:១៣]

**ស៖** សូមអរគុណ។ ពេលលោកធ្វើទាហាន លន់ នល់ ហ្នឹង នៅក្នុងកងពលណាដែរ លោក? ហើយនៅឯណា?

**ឆ៖** បាទ ពេលខ្ញុំធ្វើជាទាហាន លន់ នល់ នោះ គឺថាខ្ញុំនៅក្នុងកងពល៤១០ ឈរជើងនៅជាយខេត្តស្វាយរៀងខាងត្បូង ក្នុងឃុំបាសាក់។

**ស៖** សូមអរគុណ។ ចុះនៅថ្ងៃ១៧ មេសា ១៩៧៥ នៅពេលដែលកងទ័ពកម្ពុជាប្រជាធិបតេយ្យចូលមកដល់ តើក្រុមៗ ក្រុមគ្រួសាររបស់លោក ក៏ដូចជារូបលោកផ្ទាល់ កំពុងធ្វើអីដែរ? ហើយពេលនុ៎ងមានអីកើតឡើងចំពោះក្រុមគ្រួសាររបស់លោកដែរឬទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំសូមជម្រាបលោកប្រធាន។ ក្នុងឆ្នាំ១៩៧៥នោះ ថ្ងៃ១៨ មីនា ពួកខ្មែរក្រហមបានជម្លៀសខ្ញុំចេញពីទីក្រុងស្វាយរៀង ពីទីរួមខេត្តស្វាយរៀង ឲ្យចេញមកនៅភូមិតាដៃ ឃុំកំពង់ចំលង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ក្នុងពេលនោះ កងទ័ពវៀតណាមបានបង្ខំឲ្យប្រជាជនចេញពីទីរួមខេត្តជាបន្ទាន់ ពីព្រោះខាងកងទ័ពខ្មែរក្រហម គាត់បានប្រាប់ថា ឲ្យបងប្អូនខ្មែរ បងប្អូនប្រជាពលរដ្ឋ ពុកម៉ែ ចេញពីទីក្រុងចំនួនពីរបីថ្ងៃទេ ដើម្បីទុកឲ្យកងទ័ពបោសសម្អាតខ្មាំង។ ហើយក្នុងពេលនោះ គឺថាខ្ញុំបាទ គ្រួសារខ្ញុំ ទាំងប្រជាជនទាំងអស់ បានចេញដោយបង្ខិតបង្ខំ ដោយគ្មានយកបានទ្រព្យសម្បត្តិអ្វីទេ គឺថាយកបានតែខោអាវបន្តិចបន្តួច ដោយគេបង្ខិតបង្ខំ។ ពីព្រោះបើអ្នកណាមិនចេញ គឺថាកងទ័ពត្រូវបាញ់សម្លាប់ចោល។

[១៤:៤៥:២៣]

ក្នុងពេលនោះ មានតាចាស់ម្នាក់គាត់ដើរមិនរួចមុខខ្ញុំ ដល់ហើយគាត់ដើរទទឹងទទាម ទទួលគាត់ជាចាស់ ហើយកងទ័ពវៀតណាមក៏បានបាញ់គាត់ដួលនៅមុខខ្ញុំ។ ពេលនោះហើយដែលខ្ញុំមានការភ័យ

តក់ស្លុត ក៏បាននាំគ្នាចេញដោយរួសរាន់ ព្រោះខ្លាចកងទ័ពបាញ់សម្លាប់ទៀត។ រហូតគេជម្លៀសខ្ញុំមកដល់ស្រុក -- ដល់ភូមិតាជ័យ ឃុំកំពង់ចំលង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង បានរយៈពេល១ខែ បានរយៈពេល១ខែ គេចាប់ផ្ដើមយកបងប្រុសខ្ញុំឲ្យទៅរៀនសូត្រ នៅវត្តគ្រួស។ ពីព្រោះគេដឹងថា បងប្រុសខ្ញុំធ្វើជាទាហាន លន់ នល់។ ពេលយកបងប្រុសខ្ញុំទៅរៀនសូត្រនោះ គឺថាយកទៅ តាមពិតមិនមែនយកទៅរៀនសូត្រទេ គឺថាយកទៅសម្លាប់បាត់ខ្លួនទាល់នឹងថ្ងៃហ្នឹងតែម្ដង។ ហើយបន្ទាប់មកទៀត ប្រហែលជាកន្លះខែ កងទ័ព ពួកខ្មែរក្រហមហ្នឹងគឺថាបានយកឪពុកខ្ញុំឲ្យទៅរៀនសូត្រនៅវត្តតាដៃ ព្រោះពួកគេចោទថាឪពុកខ្ញុំធ្វើជាកងស្វ័យត្រាណ។ តែតាមពិតឪពុកខ្ញុំជាប្រជាពលរដ្ឋស្មោះត្រង់ គ្រាន់តែ ប៉ុន្តែគេឲ្យជួយការពារ គេឲ្យអាវុធដើម្បីជួយយាមយប់ៗ ដល់ហើយគេថាពួកកងស្វ័យត្រាណ ប្រឆាំងនឹងបដិវត្តន៍។ ពេលយកមករៀបនេះគឺថា ខ្ញុំក៏មិនទាន់បានមកដែរ គឺថាខ្ញុំនៅ រហូតដល់កន្លះក្រោយទៀត។ ចុងក្រោយគេបានមកហៅខ្ញុំទៅ ឲ្យរៀននៅវត្តតាដៃដែរ។ ពេលដែលខ្ញុំទៅរៀននោះ គឺថាមានប្រជាជនដែលមានតួនាទីខ្លះជាទាហាន ខ្លះជាកងស្វ័យត្រាណ ខ្លះជាប្រជាជនដែលគេយកទៅដាក់គុកនៅកន្លែងនោះចំនួនប្រហែលជា៥០០នាក់ ប្រហែលជា៥០០នាក់។ ពេលដែលខ្ញុំជាប់គុកនោះ គឺថាគេប្រើឲ្យធ្វើការគ្មានពេលគ្មានវេលាទេ។ ចំណែកហូបគឺថាអត់មានអីហូប គឺថាក្នុងមួយពេល គេឲ្យហូបអង្ករពីរកំប៉ុង ចំនួន១០នាក់ក្នុងមួយក្រុម ហូបជាមួយសម្លកំប្លោក។

[១៤:៤៨:១៧]

ហើយក្នុងពេលនោះ គេបានបង្ខិតបង្ខំឲ្យខ្ញុំធ្វើការជាទម្ងន់ ឲ្យធ្វើការជាទម្ងន់ ដូចជា ជីកព្រែក ជីកប្រឡាយ និងអូសរទេះ ដឹកអុសមកដាក់រោងបាយ។ គឺថាយើងយកកម្លាំងមនុស្សធ្វើជាគោជាក្របី។ ក្នុងពេលនោះហើយដែលខ្ញុំមានការតក់ស្លុត មានការរងគ្រោះជាទម្ងន់ វេទនាជាទម្ងន់។ រហូតដល់ខ្ញុំ ក្នុងពេលខ្ញុំជាប់គុកឥតជញ្ជាំងបានរយៈពេល៩ខែ រយៈពេល៩ខែ បានគេដោះលែង ដោះលែងខ្ញុំ ឪពុកខ្ញុំមានបងប្អូនមួយចំនួនទៀត ដែលខ្ញុំមិនបានស្គាល់ មិនបានចាំច្រើនទេ ក្នុងលែងម្ដងមាន២០០, ១០០ជាង និងខ្ញុំមិនបានចាំទេ។ ហើយខ្ញុំនិងឪពុកខ្ញុំទៅជួបជុំជាមួយគ្រួសារនៅតាមសហករណ៍វិញ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកបញ្ជាក់បន្តិច ទាក់ទងទៅនឹងមុននឹងបន្តិចលោកថា ថ្ងៃ១៨ មេសា -- អ៎! ១៨ មីនា។ អ៊ីចឹងខ្ញុំសូមសួរបញ្ជាក់បន្តិចមើល ការពេលដែលគេជម្លៀសចេញហ្នឹង គឺថ្ងៃ ១៨ មីនា ឬមួយក៏ថ្ងៃ១៧ មេសា?

**ឆ៖** បាទ សុំទោស ខ្ញុំច្រឡំអំមិញគឺថា ថ្ងៃ១៧ មេសា ៧៥។ បាទ អំមិញខ្ញុំច្រឡំ សុំទោស។

**ស៖** សូមអរគុណ។ ហើយមួយទៀត លោកបានលើកឡើងថា កងទ័ពវៀតណាមជាអ្នកបង្ខំឲ្យលោកចេញ។ អ៊ីចឹងកន្លែងហ្នឹង សូមលោកបញ្ជាក់ឡើងវិញមើល ថាតើកងទ័ពវៀតណាម ឬមួយក៏ក្រុមណាផ្សេងទៀត?

**ឆ៖** បាទ កន្លែងនេះគឺថាខ្ញុំ អំមិញក៏ខ្ញុំច្រឡំដែរ គឺថា តាមពិតកងទ័ពខ្មែរក្រហម។ កងទ័ពខ្មែរក្រហមអ្នកបានបណ្ដេញយើង ជម្លៀសយើងឲ្យចេញពីទីក្រុង។

[១៤:៥០:៥១]

**ស៖** សូមអរគុណ។ មុននឹងឈានចូលទៅក្នុងអង្គហេតុដែលយើងត្រូវសួរនៅពេលនេះ ខ្ញុំសូមសួរបញ្ជាក់លោកទៅលើចំណុចមួយ ទាក់ទងនឹងកងស្វ័យត្រាណ។ ខ្ញុំសូមឲ្យលោកជួយពន្យល់តិចមើល កងស្វ័យត្រាណហ្នឹង មានន័យម៉េចដែរ? ហើយជាកងទាហានខាងណាដែរ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ កងស្វ័យត្រាណនេះ គេសំដៅទៅលើកងកម្លាំងរបស់លោក លន់ នល់។ កងកម្លាំងលោក លន់ នល់ នេះគឺថាប្រជាជនដែលនៅក្រោយ នៅក្រោយ នៅសមរ-ភូមិក្រោយ។ គេឲ្យយើងកាន់អាវុធដើម្បីជួយការពារកុំឲ្យពួកខ្មែរក្រហមចូលទៅក្នុងទីរួមខេត្ត។ ហើយពួកនេះ អត់មានប្រាក់ខែទេ។ អ៊ីចឹងបានហើយ ខាងខ្មែរក្រហម ពួកខ្មែរក្រហមគាត់ឆ្លើយឡើង គាត់ថាឡើង គាត់ថា ពួកជួយរវល់។ គាត់ថាពួកជួយរវល់ តែតាមពិត គេដាក់ កងស្វ័យត្រាណ។

**ស៖** សូមអរគុណ។ ដោយសារតែអង្គហេតុរបស់លោក ភាគច្រើនពាក់ព័ន្ធជាមួយនឹងការជម្លៀស ប៉ុន្តែដោយសារឥឡូវនេះ តួនាទី -- ដោយសារអង្គហេតុដែលលោកត្រូវឆ្លើយបំភ្លឺហ្នឹង ពាក់ព័ន្ធជាមួយនឹងតួនាទីរបស់ជនជាប់ចោទ អ៊ីចឹងខ្ញុំសូមចូលទៅដល់សំណួរដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុតែម្ដង ដើម្បីកុំឲ្យខាតពេលវេលា។ អ៊ីចឹងខ្ញុំសូមសួរលោកថា នៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យហ្នឹង លោកមានដែលធ្លាប់ដឹង ឬក៏ធ្លាប់ឮ ឬក៏ធ្លាប់ឃើញថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យណាមួយដែរឬទេលោក?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ក្នុងពេលរបបសម័យកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមនេះ គឺថាខ្ញុំ ពេលដែលពួកគាត់បានជម្លៀសខ្ញុំចេញពីស្វាយរៀងមក បានដល់អ្នកលឿង ដល់មកផ្សារច្បារអំពៅ។ ផ្សារច្បារអំពៅហ្នឹង បានខ្ញុំជួប ១លោក ខៀវ សំផន។ ជួបគាត់បានថ្ងៃទី៣ គាត់បានមកចែកសម្ភារៈដូចជាខោអាវ បាយ ដើម្បីឲ្យយើងឡើងរទេះភ្លើងទៅខាងនិរតី។ ហ្នឹងខ្ញុំជួបគាត់។

[១៤:៥៣:៤៣]

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំសូមធ្វើការបញ្ជាក់ជាមួយលោកបន្តិច ថាលោកបានលើកឡើងថាលោកបានជួបជាមួយលោក ខៀវ សំផន តើលោកជួបនៅកន្លែងណា? ហើយនៅក្នុងឆ្នាំណាដែរ លោក?

**ឆ៖** បាទ អរគុណ។ បាទខ្ញុំ ពេលដែលខ្ញុំជួបគាត់ ខ្ញុំជួបនៅក្នុងឆ្នាំ១៩៧៧។ ពេលដែលគេបានជម្លៀសខ្ញុំចេញពីស្វាយរៀងមកសម្រាកនៅកន្លែងផ្សារច្បារអំពៅ ផ្សារច្បារអំពៅ។ ពេលនោះ បានខ្ញុំជួបគាត់ ពេលដែលគាត់មកចែកខោអាវ ចែកសម្ភារៈឲ្យ។ ខ្ញុំជួបនៅពេលនុ៎ង។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់សុំឲ្យលោកជួបរៀបរាប់អំពីទិដ្ឋភាពនៅពេលនោះបន្តិចបានទេ? ស្ថានភាព និងទិដ្ឋភាពដែលលោកបានជួបគាត់នៅពេលនុ៎ង ដូចជានៅជុំវិញហ្នឹង ឬក៏នៅទីតាំងដែលលោកជួបគាត់ហ្នឹង វាមានទិដ្ឋភាពយ៉ាងម៉េចដែរ? លោកអាចជួយរៀបរាប់ឲ្យបានលម្អិតអំពីកន្លែងនោះ បន្តិចបានដែរឬទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំ ក្នុងពេលដែលខ្ញុំជួបគាត់នោះ ទិដ្ឋភាពជុំវិញ កន្លែងដែលខ្ញុំសម្រាកនៅនោះគឺថា ខាងៗមានការស្ងាត់ស្ងៀម តាមផ្ទះគឺថាអត់មានប្រជាជនណាឆ្វេចឆ្វាចទេ គឺថាមានតែអ្នកជម្លៀសមកនៅក្នុងផ្សារ នៅក្នុងផ្សារ។ ហើយជម្លៀសមកនៅក្នុងផ្សារនោះ ពេលនោះគឺថាប្រជាជនច្រើនណាស់ មិនដឹងជាប៉ុន្មាន ខ្ញុំស្មានមិនត្រូវទេ គឺវាច្រើនពេក។ ច្រើនពេក មកនៅផ្តុំគ្នាក្នុងផ្សារហ្នឹងរង់ចាំ រង់ចាំរថយន្តដឹកទៅឡើងរទេះភ្លើង នៅក្នុងពេលនុ៎ង។

[១៤:៥៥:៥១]

**ស៖** សូមអរគុណ។ លោកថា មានមនុស្សម្នាច្រើន អ៊ីចឹងខ្ញុំចង់សួរថា លោកអាចកត់សម្គាល់បានទេ មនុស្សម្នាច្រើនហ្នឹង គេមកពីប្រភពខាងណាខ្លះដែរ? លោកអាចមើលដឹង ឬក៏មានមធ្យោបាយដែលអាចដឹងថា ពួកគាត់មកពីខាងណាខ្លះដែរឬទេ លោក?

**ឆ៖** បាទ បើតាមខ្ញុំដឹង ប្រហែលជាមកពីខាងបូព៌ាទាំងអស់។ វាបញ្ជូនហ្នឹង ច្រើនមកពីបូព៌ា។ បូព៌ាហ្នឹង តាមខ្ញុំដឹងទៅ មកពីខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកំពង់ចាម។

**ស៖** សូមអរគុណ។ អ៊ីចឹងពេលនុ៎ង តើពេលដែលលោកមកដល់រយៈពេល -- ចង់និយាយថាពេលដែលលោកមកដល់ហ្នឹង កន្លែងហ្នឹង គេឲ្យលោកទៅគេងនៅកន្លែងក្នុងផ្សារហ្នឹងតែម្តង ឬមួយក៏ទីតាំងក្រៅផ្សារ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន គេឲ្យខ្ញុំគេងនៅក្នុងផ្សារទាំងអស់គ្នា សម្រាកនៅក្នុងផ្សារទាំងអស់គ្នា ព្រោះទីធ្លាផ្សារហ្នឹង វាធំ។ នៅម្តុំមួយគ្រួ ម្តុំមួយគ្រួទៅ ក្បែរៗគ្នាហ្នឹង។

**សៈ** សូមអរគុណ។ មុននឹងធ្វើការបញ្ចាក់លម្អិតអំពីទិដ្ឋភាពក្នុងផ្សារហ្នឹងបន្ថែមទៀត ខ្ញុំសូមសួរលោកបញ្ជាក់បន្តិច ដោយសារនៅក្នុងឯកសារមួយចំនួនបានមានព័ត៌មានមួយ ដែលខុសពីអ្វីដែលលោកបានលើកឡើងអម្បាញ់មិញ។

[១៤:៥៧:៣៩]

**លោកស្រី ទី ស្រ៊ុនណា៖**

អ៊ីចឹងខ្ញុំសូមស្នើសុំលោកប្រធាន អនុញ្ញាតឲ្យខ្ញុំយកឯកសារដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅពេលនេះលោកប្រធាន។ សូមអនុញ្ញាតប្រើប្រាស់ទម្រង់បែបបទព័ត៌មានបន្ថែមដែលមានលេខ--។ ទី១ គឺឯកសារទាក់ទងទៅនឹងទម្រង់បែបបទព័ត៌មានជនរងគ្រោះ D5/545 ដែលមានលេខ ERN 00397758 ជាភាសាខ្មែរ, ចំណែកជាភាសាអង់គ្លេស 00422204។ ហើយឯកសារមួយទៀត គឺឯកសារពាក់ព័ន្ធជាមួយនឹងទម្រង់បែបបទបន្ថែម កាលពីឆ្នាំ២០១០ នៅក្នុងសំណុំរឿង០០២ដដែល គឺលេខឯកសារ E3/5332a ត្រង់ ERN ជាភាសាខ្មែរ 00905784, ជាភាសាអង់គ្លេស 01332268។ ហើយឯកសារមួយទៀត គឺពាក់ព័ន្ធជាមួយនឹងទម្រង់បែបបទព័ត៌មានបន្ថែមដដែល ប៉ុន្តែនៅក្នុងសំណុំរឿងផ្សេង ដែលមានលេខឯកសារ E3/10670 មានលេខ ERN ជាភាសាខ្មែរ 00 -- អ៎ សូមទោស ERN 01118429, ជាភាសាអង់គ្លេស 01190623។ ចំពោះឯកសារទាំងបីនេះ គឺមានតែភាសាខ្មែរ និងភាសាអង់គ្លេសប៉ុណ្ណោះ ចំពោះភាសាបារាំងគឺពុំទាន់មាននៅឡើយទេ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតលោកប្រធាន ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[១៤:៥៩:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក គង់ សំអុន៖**

អំមិញខ្ញុំស្តាប់ឮថា មានឯកសារ D5/45 ហើយខ្ញុំចង់បញ្ជាក់ថា អាហ្នឹង វាមានឯកសារ E3 ជាប្រភេទក្នុងឯកសារក្នុងសំណុំរឿង០០២/២ នេះដែរទេ?

**លោកស្រី ទី ស្រ៊ុនណា៖**

ខ្ញុំសូមជម្រាបថា ឯកសារ D5/545 ហ្នឹង គឺជាឯកសារដែលមាននៅក្នុងសំណុំរឿង០០២។ ឯកសារដែលខ្ញុំលើកអម្បាញ់មិញទាំងអស់ គឺសុទ្ធតែមាននៅក្នុងសំណុំរឿង០០២ទាំងអស់។ ហើយ

ដែលមានឯកសារដើមរបស់វាហ្នឹង គឺមានលេខ D22/194។ ហើយ E *ណាំប៊ឺរ* E3/10670 លេខ៨។ នៅក្នុងឯកសារព័ត៌មានជនរងគ្រោះរបស់លោក ដែលបានជម្រាបជូន ដែលលោកបានបំពេញកន្លងមកហ្នឹង លោកបានបំពេញថា--

**ប្រធានអង្គជំនុំ៖**

ឈប់! ឈប់សិន! មើលដូចអត់ច្បាស់លាស់ ម៉េចទេ? លេខឯកសារអំមិញ E3/10670 លេខ ៨ ម៉េច?

[១៥:០១:០៦]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមជម្រាបលោកប្រធានថា ឯកសារដែលមាន D5/545 ហ្នឹងគឺមកពីឯកសារដើម ដែលមានលេខ D22/194 ហើយនិងបានចុះនៅក្នុងចំណាត់ថ្នាក់ E3/160 -- E3/10670 និងលេខ៨។ អេ អ្ហ៎! សុំទោស លោកប្រធាន គឺ “a”។

**ប្រធានអង្គជំនុំ៖**

បាទ តទៀតទៅ។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** នៅក្នុងឯកសារទម្រង់បែបបទព័ត៌មានជនរងគ្រោះដែលខ្ញុំបានលើកអម្បាញ់មិញ ដែលមានការភ័ន្តច្រឡំកន្ទុយបន្តិចនុ៎ង ខ្ញុំមានព័ត៌មានត្រង់ចំណុច E 00377758ហ្នឹង នៅក្នុងចំណុចខាងក្រោមហ្នឹង លោកបានលើកឡើងថា៖ “ឲ្យយើងឡើងលើកប៉ាល់ទាំងយប់ ព្រឹកឡើងទៅដល់ផ្សារថ្មី។ គេឲ្យយើងសម្រាកនៅទីនោះ។” ឯចំណែកឯកសារមួយទៀត ដែលពាក់ព័ន្ធជាមួយនឹងទម្រង់បែបបទព័ត៌មានបន្ថែមរបស់លោក ត្រង់ ERN ជាភាសាខ្មែរ 00905784 និងមាន ERN ជាភាសាអង់គ្លេស 01332268។ នៅក្នុងនុ៎ង លោកបានលើកឡើងថា៖ “ជិះកប៉ាល់ទៅភ្នំពេញ ដល់ភ្នំពេញមុំផ្សារច្បារអំពៅ ជាកន្លែង -- គេចែកខោអាវ (លោក ខៀវ សំផន)។”

[១៥:០៣:២៧]

ហើយឯកសារមួយទៀត ដែលលោកបានផ្តល់ជូនដែរនុ៎ង នៅក្នុង ERN 0 -- នៅក្នុងឯកសារទម្រង់បែបបទព័ត៌មានបន្ថែមដែរ ប៉ុន្តែនៅក្នុងសំណុំរឿងមួយផ្សេងទៀត ក្រៅពីសំណុំរឿង០០២ នៅត្រង់ ERN ជាភាសាខ្មែរ 01118429 និងភាសាអង់គ្លេស 01190623។ លោកបានលើកឡើងថា៖

"ពេលកប៉ាល់បានចេញដំណើរពីម៉ោងដប់ពីរយប់ ទៅដល់ផ្សារថ្មីម៉ោងដប់ព្រឹក។"

អ៊ីចឹងខ្ញុំសូម មួយវិញទៀត លោកបានលើកអម្បាញ់មិញនេះ លោកថា លោកបានធ្វើដំណើរដល់ច្បារអំពៅ។ អ៊ីចឹងខ្ញុំសូមសួរជាយោបល់របស់លោកវិញ ថាតើលោកយល់យ៉ាងម៉េចដែរ ចំពោះអ្វីដែលមានភាពមិនៗស្របគ្នា មួយផ្សារថ្មី និងផ្សារច្បារអំពៅបែបនេះ? សូមលោកជួយពន្យល់ជូនអង្គជំនុំជម្រះ។

2-TCCP-1063៖

**ឆ៖** បាទ អរគុណ។ បានៗក្នុងពេលនោះ ខ្ញុំបានឆ្លើយអ៊ីចឹងមែន តែពេលនោះខ្ញុំមិនដែលស្គាល់ភ្នំពេញទេទ។ ដល់ហើយ ខ្ញុំអត់ស្គាល់ទីតាំង។ ម្ល៉ោះហើយពេលដែលគេសួរខ្ញុំ ៗឆ្លើយថាផ្សារថ្មី តែតាមពិតដល់ពេលខ្ញុំស្គាល់មិនមែនផ្សារថ្មីទេ គឺថាផ្សារច្បារអំពៅ។ ពីព្រោះបានខ្ញុំថាផ្សារច្បារអំពៅ ពីព្រោះផ្សារហ្នឹងនៅជិតស្ពាន នៅជិតស្ពាន ហើយមានទន្លេនៅជិត។ បានខ្ញុំថា ខ្ញុំមិនដែលស្គាល់ទេទីក្រុងភ្នំពេញ។ អ៊ីចឹងបានថាខ្ញុំ ខ្ញុំនិយាយទៅវាអត់បានពិតមែន។

**ស៖** សូមអរគុណ។ អ៊ីចឹងឥឡូវលោកជ្រើសរើសយកទីតាំងមួយណា ជាផ្សារថ្មី ឬក៏ផ្សារច្បារអំពៅ?

**ឆ៖** បាទ ឥឡូវនេះខ្ញុំជ្រើសរើសយកផ្សារច្បារអំពៅ ហ្នឹងពិតប្រាកដតែម្តង។

[១៥:០៥:៥២]

**ស៖** សូមអរគុណ។ អ៊ីចឹងដើម្បីឲ្យកាន់តែច្បាស់ទៀត ខ្ញុំសូមតាំងសំណួរមួយចំនួន ដើម្បីពាក់ព័ន្ធនឹងកន្លែងហ្នឹង ថាតើវាជាផ្សារច្បារអំពៅ ឬក៏ផ្សារថ្មី។ អ៊ីចឹងខ្ញុំសូមធ្វើការបញ្ជាក់លោកបន្តិចថា បើតាមអ្វីដែលលោកចាំ ពេលដែលលោកទៅដល់ទីនោះ ខ្ញុំចង់ឲ្យលោករកនឹកឡើងវិញមើល ថាទៅដល់ទីនោះហ្នឹង ផ្សារហ្នឹងមានដំបូលអត់?

**ឆ៖** បាទ ពេលនោះខ្ញុំទៅផ្សារហ្នឹងគឺថាមានដំបូង តែអត់មានជញ្ជាំងទេ មានតែដំបូល អត់មានជញ្ជាំងទេ។ ម្ល៉ោះហើយជញ្ជាំងហ្នឹងគឺថាចំហ បានដល់ហើយបងប្អូនយើង ដែលប្រជាជនមកហ្នឹងសម្រាន្ត ជ្រកនៅក្នុងផ្សារនេះតែម្តង។ អត់មានជញ្ជាំងថ្មទេ មានតែចាក់សាបក្រោម បាទប៉ុណ្ណឹង។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់លោកម្តងទៀតថា លោកថាមានដំបូល តើដំបូលហ្នឹងពណ៌អីដែរ? ហើយដំបូលហ្នឹងធ្វើពីអ្វីដែរ?

**ឆ៖** បាទ ដំបូលហ្នឹងដំបូលប្រក់ពីស័ង្កសី ស័ង្កសីពណ៌ស។

**ស៖** លោកអាចចាំបានឬទេ តើទំហំនៃផ្សារហ្នឹងវាមានទំហំប៉ុន្មានដែរ? ហើយបើតាមការប៉ាន់ប្រមាណមើល ខ្ញុំចង់ឲ្យលោករកនឹកមើលៗ ថាមានតូបច្រើនទេនៅក្នុងផ្សារហ្នឹង?

**ឆ៖** បាទ ក្នុងផ្សារនេះតាមពេលនោះគឺថា តូបមានតែខាងៗតិចៗ ហើយកណ្តាលហ្នឹងគឺថាមានបរិវេណទីធ្លាទូលាយ អត់មានតូបអីនៅកំប៉ិកកំប៉ុកទេ គឺថាទីធ្លាទូលាយតែម្តង បានគេឲ្យប្រជាជនមកសម្រាកនៅកន្លែងហ្នឹង វាស្រឡះ អត់មានតូបណាបាំងបន្ទប់បាំងអី អត់មានទេ ក្នុងពេលនុ៎ង។

[១៥:០៨:២២]

**ស៖** តើផ្សារហ្នឹងវាមានចម្ងាយប៉ុន្មានពីទន្លេ?

**ឆ៖** បាទ ផ្សារហ្នឹង បើតាមខ្ញុំនេះកាលនុ៎ង វាមិនជាឆ្ងាយប៉ុន្មានទេ ប្រហែលជាត្រឹម១០០ ឬ ៥០ម៉ែត្រចេញពីទន្លេ ចម្ងាយប្រហែលប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរលោកមួយទៀត តើលោកស្គាល់អ្នកលឿងទេ?

**ឆ៖** បាទ បើចំណែកកន្លែងអ្នកលឿង ខ្ញុំបាទស្គាល់ៗ ព្រោះខ្ញុំមក ខ្ញុំឈប់នៅត្រើយខាងកើត។

**ស៖** អ៊ីចឹងលោកប្រាកដហើយ ថាទីតាំងដែលផ្សារហ្នឹងមិនមែនជាទីតាំងដែលផ្សារនៅៗស្រុកអ្នកលឿង?

**ឆ៖** បាទ ទីតាំងនេះគឺថាមិនមែនទីតាំងនៅផ្សារអ្នកលឿងទេ គឺថាអ្នកលឿងខ្ញុំនៅតាមផ្ទះ តាមថ្នល់ នៅជ្រកនៅតាមថ្នល់ មានផ្ទះថ្មគេតាមថ្នល់ តាមខាងជើងថ្នល់ជាតិលេខ១ ហ្នឹងខ្ញុំសម្រាក។

**ស៖** សូមអរគុណ។ អ៊ីចឹងទីតាំងផ្សារហ្នឹងមានចម្ងាយប៉ុន្មានពីស្ពានដែរលោក?

**ឆ៖** បាទ ខ្ញុំសូមសួរលោកប្រធានបន្តិច។ ទីតាំងផ្សារណាដែលថានៅឆ្ងាយពីស្ពាន? ខ្ញុំស្តាប់ច្រឡំត្រង់ហ្នឹង។

**ស៖** ចាស អរគុណ។ ខ្ញុំចង់សំដៅទៅលើផ្សារច្បារអំពៅ តើផ្សារច្បារអំពៅដែលលោកបានលើកឡើងហ្នឹង មានចម្ងាយប៉ុន្មានពីស្ពាន? ពីព្រោះពីដើមលោកបានលើកឡើងថា ផ្សារហ្នឹងនៅជាប់ទន្លេ -- នៅក្បែរទន្លេ និងក្បែរស្ពាន។ អ៊ីចឹងលោកបានលើកឡើងថា ចម្ងាយប្រហែល៥០ម៉ែត្រជាងពីទន្លេ។ ឥឡូវខ្ញុំចង់សួរថា តើផ្សារហ្នឹងដដែល ច្បារអំពៅហ្នឹងដដែល មានទីតាំងផ្សារហ្នឹងមានចម្ងាយប៉ុន្មានពីស្ពានដែរ?

[១៥:១០:៤៨]

**ឆ៖** បាទ ផ្សារហ្នឹង កាលនោះគឺថា មានទីតាំងប្រហែលជាពី១០០ចុះ មិនដល់លើសពី១០០

ម៉ែត្រទេ ហ្នឹងដល់ស្ពាន ដល់មាត់ទន្លេ។

**ស៖** ខ្ញុំសូមបញ្ជាក់លោកបន្តិច ថាតើទីតាំងស្ពានកាលពីជំនាន់ហ្នឹង មានដាច់ៗស្ពានដែរឬទេ ឬក៏ស្ពានហ្នឹង នៅប្រើប្រាស់បាន?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ពេលនោះស្ពាននៅប្រើប្រាស់បាន ព្រោះពេលនោះមានកងទ័ពវៀតណាម -- កងទ័ពខ្មែរក្រហម គេនៅយាមលើនុ៎ង អត់ទាន់មានខូចទេ។

**ស៖** សូមអរគុណ។ ចុះហេតុអីបានជាលោកហៅឈ្មោះផ្សារហ្នឹងថា "ច្បារអំពៅ"? លោកបានឈ្មោះហ្នឹងមកពីណា? បើ--

**ឆ៖** បាទ ពេលនោះបានខ្ញុំហៅ "ច្បារអំពៅ" ពីព្រោះខ្ញុំហៅតាមតែអ្នកគេស្គាល់ៗមុនខ្ញុំ ព្រោះខ្ញុំមិនដែលបានមកភ្នំពេញ ខ្ញុំអត់ស្គាល់។ ដល់ឮគេហៅថា "ច្បារអំពៅ" ចេះតែច្បារអំពៅ តាមគេទៅ។ អាហ្នឹងពេលនោះ ខ្ញុំអត់បានស្គាល់ទេ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមបន្តទៅប្រធានបទយើងវិញ ពាក់ព័ន្ធជាមួយនឹងវត្តមានរបស់លោក ខៀវ សំផន នៅផ្សារនុ៎ង។ លោកចាំបានទេ ថ្ងៃដែលលោក ខៀវ សំផន ទៅផ្សារហ្នឹង តើគាត់ទៅនៅម៉ោងប៉ុន្មានដែរ? ហើយគាត់ទៅតែម្នាក់ឯង ឬក៏មានអ្នកអមទៅជាមួយ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ថ្ងៃនោះគឺថា មានលោក ខៀវ សំផន គាត់អញ្ជើញមកអញ្ជើញមកហ្នឹង នៅប្រហែលជាម៉ោងប្រាំបីព្រឹក ម៉ោងប្រហែលជាប្រាំបីព្រឹក។ គាត់អញ្ជើញមក មានសហការីគាត់ ប្រហែលជា១០នាក់ជាង ព្រោះខ្ញុំក៏មិនបានរាប់ដែរ ព្រោះថាខ្ញុំស្មាន ប៉ាន់ស្មានមើលទៅប្រហែលប៉ុណ្ណឹង។ ហ្នឹងក្រុមការងាររបស់គាត់ជូនដំណើរគាត់មក ដើម្បីមកសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅពេលនុ៎ង។

[១៥:១៣:២៦]

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លោកមួយសាទៀត លោកហាក់បីដូចជាលើកឡើងថាច្បាស់បំផុតថាគាត់ពិតជា ខៀវ សំផន។ អ៊ីចឹងខ្ញុំចង់សួរលោកថា មូលហេតុអីបានជាលោកហ៊ានសន្និដ្ឋាន ឬក៏អះអាងថា បុគ្គលដែលចូលទៅផ្សារហ្នឹង ដែលទៅចែកអំណោយហ្នឹងគឺជា ខៀវ សំផន មូលហេតុអីទៅ?

**ឆ៖** បាទ បានជាខ្ញុំហ៊ានអះអាងថា គាត់ជាលោក ខៀវ សំផន ពីព្រោះខ្ញុំបានធ្លាប់មើលខ្សែភាពយន្ត កាលដែលគេមិនទាន់ជម្លៀសមក មានកងទ័ពយកទៅបញ្ចាំងតាមភូមិឲ្យមើល។ មានឃើញ

រូបគាត់ ហើយគេអ្នកស្គាល់ គេប្រាប់ថា ហ្នឹងហើយលោក ខៀវ សំផន។ ពេលនោះហើយបានខ្ញុំហ៊ាន កំណត់ថា ច្បាស់ជាគាត់មែន ពីព្រោះខ្ញុំបានធ្លាប់ឃើញគាត់នៅក្នុងខ្សែភាពយន្ត។

**ស៖** សូមអរគុណ។ មុននេះបន្តិចលោកថា លោក ខៀវ សំផន មកដល់នៅម៉ោងប្រាំបីព្រឹក ជាមួយនឹងសហការី ប្រហែលជាជាង១០នាក់។ អ៊ីចឹងខ្ញុំចង់ឲ្យលោកជួយរៀបរាប់អំពីទិដ្ឋភាពនៅពេល ដែលវត្តមានគាត់មកដល់ដំបូងហ្នឹង តើមានទិដ្ឋភាពយ៉ាងម៉េចដែរ? ដូចថាធម្មតា នៅពេលដែលគាត់ចុះ មក អ៊ីចឹងមានទិដ្ឋភាពយ៉ាងម៉េច? ឧបមាថា ស្ថានភាពពីធម្មតា អាចនៅមានស្ថានភាពអីផ្សេងទៀត ឬ ក៏យ៉ាងម៉េច សូមលោកជួយរៀបរាប់ឲ្យលម្អិតបន្តិចមក អំពីពេលដែលគាត់ចុះពីឡានមកដល់?

[១៥:១៥:១០]

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ ពេលដែលលោក ខៀវ សំផន គាត់អញ្ជើញមកដល់ ផ្សារនោះ គឺថាគេឲ្យយើង ឲ្យប្រជាពលរដ្ឋហ្នឹង ដើម្បីយើងតម្រៀបជួរ ដើម្បីរង់ចាំស្តាប់ប្រសាសន៍ របស់គាត់ ចាំទទួលអបអរគាត់ នៅក្នុងពេលនុ៎ង។ ដើម្បីឲ្យប្រជាពលរដ្ឋហ្នឹងតម្រង់ជួរ រៀបជាជួរ ដើម្បីធ្វើជាអង្គប្រជុំមួយ សម្រាប់ទទួលគាត់នៅក្នុងពេលនុ៎ង។ ហើយពេលគាត់មកដល់ហើយហ្នឹង គាត់ក៏មានប្រសាសន៍ឡើងថាដែរ គាត់មានប្រសាសន៍ឡើងដូចខ្ញុំរៀបរាប់អំមិញខ្លះដែរ។ ពេលនោះ គាត់ក៏បានមានប្រសាសន៍ថា យើងបង្កើត -- ធ្វើបដិវត្តនេះ ធ្វើដើម្បីលុបបំបាត់របបប៉ុលពត -- អ៎! របប លន់ នល់ (សូមទោស) របប លន់ នល់។ មួយទៀត គឺថាលុបបំបាត់របបនាយទុន សក្តិភូមិ បញ្ញវន្ត គាត់មិនឲ្យមានទេ។ ហ្នឹងគាត់ប្រសាសន៍ដែលគាត់លើកឡើង។ ពេលនោះគាត់និយាយច្រើន ប៉ុន្តែខ្ញុំ យូរឆ្នាំពេក ខ្ញុំវាភ្លេចអស់ដែរ ខ្ញុំមិនបានចាំអស់ទេ គ្រាន់តែខ្ញុំចាំកន្លែងសំខាន់ៗ។ បាទ ខ្ញុំចាំបានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកថា តើពេលដែលមុននឹងលោក ខៀវ សំផន មក មានថ្នាក់ ដឹកនាំផ្សេងគេមកមុន ដើម្បីរង់ចាំទទួលគាត់ ឬមួយក៏អត់ទេ លោក?

**ឆ៖** បាទ ពេលនោះខ្ញុំដូចជាមិនចាំ បានចាប់អារម្មណ៍ប៉ុន្មានដែរ ស្រាប់តែគាត់មកដល់តែម្តង។ ដូចជាអត់មានកម្មវិធីអី មកអឹកអធិកអីប៉ុន្មានទេកាលណោះ។ គឺថាគាត់អញ្ជើញមក គ្នាគាត់មួយក្រុម គាត់មកតែម្តង អត់មានអ៊ូអរឯណា ដូចយើងសម័យឥឡូវទេ។ ហ្នឹងអង្កាល់ណោះ។

**ស៖** សូមអរគុណ។ ពេលហ្នឹងលោក ខៀវ សំផន គាត់ស្លៀកសម្លៀកបំពាក់អីដែរ លោក?

[១៥:១៧:៥៦]

**ឆ៖** បាទ ពេលនោះក៏លោក ខៀវ សំផន គាត់ស្លៀកពាក់ខោអាវខ្មៅ ខោអាវខ្មៅ ហើយគាត់

បង់កក្រមាខៀវ។ ហើយមួយទៀត ទ្រនាប់ជើងគាត់ ទ្រនាប់ជើងកង់ឡាន តែកង់ឡានដូចថា ម៉ាករាង ល្អជាងគេ អាហ្នឹងតាមខ្ញុំមើលទៅ ព្រោះសម័យនោះ ច្រើនតែទ្រនាប់ជើងកង់ឡានទេ។ ហ្នឹងពេលគាត់មក ខោខ្មៅ អាវខ្មៅ។ រួមចំណែកទាំងអស់ ក្រុមការងារគាត់ទាំងអស់ សុទ្ធតែខោខ្មៅ អាវខ្មៅ។

**ស៖** សូមអរគុណ។ អ៊ីចឹងមុនហ្នឹង លោកលើកអំពីករណីដែលគេឱ្យលោកឈរតម្រង់ជួរ។ អ៊ីចឹងពេលនុ៎ង លោកមាននៅក្នុងជួរនឹងគេអត់? ហើយទីតាំងជួររបស់លោកហ្នឹងនៅកន្លែងណា? ហើយមានគម្លាតចម្ងាយពីលោក ខៀវ សំផន ប្រវែងប៉ុន្មានដែរ លោកនៅចាំបានទេ?

**ឆ៖** បាទ ពេលនោះគេឱ្យតម្រៀបជួរនៅក្នុងផ្សារ ក្នុងផ្សារហ្នឹងតែម្តង ក្នុងផ្សារ។ ហើយក្នុងផ្សារនេះ ថ្ងៃនុ៎ងវាជួរវាច្រើន ខ្ញុំមិនបានជាចាំជួរទេ គឺថាប្រជាជនច្រើន។ តែតាមពិតខ្ញុំមិនបាននៅជួរមុខទេ ខ្ញុំនៅជួរកណ្តាល។ នៅជួរកណ្តាល ព្រោះខ្ញុំឃ្លាតពីគាត់ហ្នឹងប្រហែលជា២០ម៉ែត្រ ប្រហែលជា២០ម៉ែត្រ ឬ១៥ម៉ែត្រ ដែលខ្ញុំឃ្លាតពីគាត់ ព្រោះខ្ញុំមិនបាននៅជួរមុខទេ។

**ស៖** សូមអរគុណ។ មុនហ្នឹងលោកលើកឡើងថា លោក ខៀវ សំផន បាននិយាយមកកាន់ប្រជាជននៅម្តុំនៅហ្នឹង នៅក្នុងផ្សារហ្នឹង។ អ៊ីចឹងក្រោយការដែលគាត់និយាយ -- ខ្ញុំចង់សូមបញ្ជាក់ថា មុននឹងគាត់និយាយ តើមានអ្នកណាគេឡើងថ្លែងសុន្ទរកថាប្រកាសបើក ឬមួយក៏គេឡើងប្រកាសថា មានគណៈអធិបតីមកអី ដើម្បីប្រកូកប្រកាសឱ្យប្រជាជនដឹងដែរឬទេ ពេលដែលគាត់មកដល់ហើយ? ឧបមាថា ជួនកាលមានអ្នកឧទ្ទេសនាមមួយ តើមានៗដែរឬទេ នៅពេលនុ៎ង?

[១៥:២០:២០]

**ឆ៖** បាទ ពេលនោះមានៗអ្នកប្រកាសកម្មវិធី។ មានអ្នកប្រកាសកម្មវិធីថា លោក ខៀវ សំផន គាត់អញ្ជើញមក តែដល់តួនាទី ខ្ញុំភ្លេច។ តួនាទីរបស់គាត់ ខ្ញុំភ្លេចដែរកាលនោះ យូរឆ្នាំពេក ខ្ញុំភ្លេចតួនាទីរបស់គាត់។

**ស៖** ខ្ញុំសូមសួរលោកថា អ្នកដែលប្រកាសថា លោក ខៀវ សំផន មកហ្នឹង គាត់និយាយផ្ទាល់មាត់ ឬក៏គាត់មានកាន់ឧបករណ៍អីប្រកូកប្រកាសដែរឬក៏អត់ទេ? និយាយសាមញ្ញគឺមីក្រូ មានប្រើប្រាស់មីក្រូ ដើម្បីប្រកូកប្រកាសអត់? ព្រោះអីខ្ញុំគិតថា នៅនុ៎ងវាដូចជា ហាក់បីដូចជាមានមនុស្សច្រើនដែរ។ តើគេមានកាន់ឧបករណ៍ ដើម្បីនិយាយទៅកាន់ប្រជាពលរដ្ឋនៅក្នុងផ្សារហ្នឹងដែរឬទេ?

**ឆ៖** បាទ កាលនោះដែលអ្នកប្រកាសហ្នឹងគឺថាមាន មានកាន់មីក្រូហ្វូនកាលនោះ មិនបានមីក្រូយើងនេះទេ មីក្រូហ្វូន។ មានកាន់មីក្រូ បើនិយាយតែមាត់ ឮមិនបានៗសព្វទេ ព្រោះប្រជាជនច្រើន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ចុះលោក ខៀវ សំផន វិញគាត់និយាយផ្ទាល់មាត់ទទេ ឬក៏គាត់ប្រើមីក្រូហ្វូនដើម្បីនិយាយ?

**ឆ៖** បាទ ពេលនោះលោក ខៀវ សំផន ក៏គាត់កាន់មីក្រូហ្វូនដែរ ដល់ហើយគាត់កាន់មីក្រូហ្វូន បើមិនកាន់មីក្រូហ្វូន ស្តាប់គ្នាអត់បាន ម្ល៉ោះហើយគាត់កាន់មីក្រូហ្វូន គាត់និយាយដែរ។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់សួរលោកវិញ ថាក្រោយដែលលោក ខៀវ សំផន និយាយហើយ រយៈពេល ៗណាដែលគេចាប់ផ្តើមចែកអំណោយ?

[១៥:២២:៣៥]

**ឆ៖** បាទ ក្រោយពីលោក ខៀវ សំផន គាត់មានប្រកាសចប់ហើយ ហ្នឹងគឺថាប្រហែលជា១០ នាទី គេចាប់ផ្តើមចែក។ ចែកហ្នឹងចែកជានិមិត្តរូប បានប្រហែលជាប្អូនដប់ម្ភៃគ្រូទេ។ ហើយក្រោយនៅសល់ប៉ុន្មាន គឺថាក្រុមការងាររបស់គាត់ គាត់ទៅប្រគល់ឲ្យតាមៗក្រុមតែម្តង។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ ហៅមីក្រូហ្វូនហ្នឹង ដូចជាមិនដែលឮទេ ពាក្យខ្មែរនេះ ឬក៏អ្នកផ្សេងឮ ខ្ញុំដូចមិនដែលយល់ទេ។ ម៉េចទៅ មីក្រូហ្វូនហ្នឹង? ដើមបណ្តឹងរដ្ឋប្បវេណីអាចពន្យល់បានទេ? ឧបករណ៍ហ្នឹងយ៉ាងម៉េចទៅ ដែលការដែលខ្មែរយើងហៅ ឧគ្ឃោសនាសព្ទ។ មីក្រូហ្នឹងក៏បានដែរ ប៉ុន្តែមីក្រូហ្វូននេះ យើងយល់ថាម៉េច ឧបករណ៍នោះដែលគេប្រើប្រាស់នុ៎ង នៅពេលនុ៎ង? ឬក៏មេធាវីយល់? យើងដូចមិនយល់សោះនេះ។ សាក្សី អាចឆ្លើយបញ្ជាក់បានទេ?

**2-TCCP-1063៖**

**ឆ៖** បាទ មីក្រូហ្វូនហ្នឹង គឺមីក្រូហ្នឹង គឺមីក្រូគេដាក់ថ្ម មីក្រូដាក់ថ្ម ដូចយើងសព្វថ្ងៃ ក៏មានដែរ។

**ប្រធានអង្គជំនុំ៖**

ហើយទំហំវាប៉ុនណាដែរ? លោកអាចធ្វើដៃបានទេ? ហើយទំហំប៉ុន្មានទៅ?

**2-TCCP-1063៖**

**ឆ៖** បាទ ទំហំឧបល័រ ប្រហែលជាប៉ុណ្ណឹង ប្រហែលជាមុខវា ប្រហែលជា២តឹក ឬ១តឹកកន្លះ ហ្នឹងទំហំឧបល័រ។ ហើយបណ្តោយប្រហែលជា៤តឹក ឬ៣តឹក។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញបន្តទៀតចុះ!

[១៥:២៤:២៧]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ទី ស្រ៊ុនណា៖**

**ស៖** ខ្ញុំសូមឱ្យលោកបញ្ជាក់ឡើងវិញ លោកបានលើកឡើងថា ការចែកអំណោយហ្នឹង មានអ្នកឡើងទៅទទួលជានិមិត្តរូប។ តើអ្នកឡើងទទួលជានិមិត្តរូបហ្នឹង លោកចង់មានន័យយ៉ាងម៉េចដែរ? ហើយមានចំនួនប៉ុន្មាននាក់?

**2-TCCP-1063៖**

**ឆ៖** បាទ ជានិមិត្តរូបហ្នឹងគឺថា គាត់ចែកជាតំណាង ម៉្លោះបើគាត់ចែកគ្រប់គ្នាទៅវាយូរ វាយូរពេក ព្រោះគេប្រញាប់ឡើងរថយន្ត។ ហ្នឹងក្នុងពេលហ្នឹងគឺថាគាត់ចែកប្អូនដប់ ម្ភៃនាក់សិន ហើយថាសល់ប៉ុន្មាន គេទុកក្រុមការងារ ប្រគល់ឱ្យផ្ទាល់ៗដៃតែម្ដង ក្នុងពេលនោះ។

**ស៖** សូមអរគុណ។ អ៊ីចឹងក្នុងចំណោម២០នាក់ហ្នឹង មានរូបលោកដែរឬទេ?

**ឆ៖** បាទ ក្នុងនោះមានរូបខ្ញុំផងដែរ។

**ស៖** អ៊ីចឹងមានន័យថា លោកជាអ្នកឡើង លោកគឺជាមនុស្សម្នាក់ក្នុងចំណោម២០នាក់ ជាអ្នកឡើងទៅយកអំណោយផ្ទាល់ពី លោក ខៀវ សំផន តើមានន័យអ៊ីចឹង ឬក៏មិនមែនលោក?

**ឆ៖** បាទ មានន័យអ៊ីចឹងមែន។

[១៥:២៦:០៤]

**ស៖** សូមអរគុណ។ តើអំណោយដែលគេចែកឱ្យក្នុងអំឡុងពេលហ្នឹងមានអីគេខ្លះដែរលោក?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ អំណោយដែលគាត់ចែកឱ្យពេលនោះ ទី១ មានបាយមួយកញ្ចប់ម្នាក់ បើគ្នាប្រាំនាក់ មួយគ្រួសារប្រាំនាក់ហ្នឹងគេឱ្យប្រាំកញ្ចប់។ ហើយបន្ទាប់មកទៀត ខោអាវ ខោអាវហ្នឹងក្នុងម្នាក់មួយកំប្លេ ម្នាក់មួយកំប្លេ អាវមួយខោមួយ។ បើស្រីៗហ្នឹងគឺថាសំពត់មួយ អាវមួយ ហើយក្រមាមួយក្នុងម្នាក់ ហ្នឹងគេចែកពេលនុ៎ង។ ហើយអាវៗខ្មៅ ឬអាវត្រុំ មិនច្បាស់ជាខ្មៅទាំងអស់ទេ គឺថាមានសាច់ត្រុំខ្លះ មានខ្មៅខ្លះនៅក្នុងពេលនោះ។ ហើយក្រមាៗខៀវ ក្រមាខៀវទាំងអស់គ្នា។ ហើយមួយទៀត មានប្រេងក្រឡា ប្រេងក្រឡាហើយនិងថ្នាំពេទ្យមួយកញ្ចប់ផង។ បាទ មានប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ក្រោយទទួលអំណោយហើយ តើគេចាត់ចែងក្រុមរបស់លោក ក៏ដូចជាប្រជាជននៅក្នុងផ្សារទាំងអស់ហ្នឹងទៅណាដែរ?

**ឆ៖** បាទ ក្រោយពីពេលចែកអំណោយរួច គេឲ្យប្រជាជនធ្វើដំណើរឡើងឡាន ឡើងរថយន្ត ដើម្បីទៅកន្លែងវ៉ារទេះភ្លើង ក្នុងពេលនុ៎ង។

**ស៖** សូមអរគុណ។ អ៊ីចឹងចម្ងាយពីផ្សារច្បារអំពៅទៅវ៉ារទេះភ្លើងហ្នឹង លោកជិះអីគេទៅ ហើយនិងពេលជិះទៅហ្នឹង វាមានចម្ងាយប៉ុន្មានដែរ?

**ឆ៖** បាទ ពីវ៉ារទេះ -- ពីកន្លែងឡើងរថយន្តទៅវ៉ារទេះភ្លើងហ្នឹង ខ្ញុំមិនបានស្មានដឹងទេចម្ងាយ តែជិះប្រហែលជាមួយម៉ោងជាងដែរបានដល់។

[១៥:២៨:៤០]

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរចុងក្រោយ ដោយសូមឲ្យលោកធ្វើការបញ្ជាក់អំពីសម្ដីរបស់ លោក ខៀវ សំផន នៅក្នុងអំឡុងពេលដែលគាត់និយាយនៅក្នុងផ្សារហ្នឹងឡើងវិញ។ តើលោកអាច រៀបរាប់លើកអំពីសម្ដីគាត់ឡើងវិញម្ដងទៀតបានដែរឬទេ? ពីព្រោះមុនហ្នឹង ហាក់បីដូចជាមិនសូវមាន ការច្បាស់លាស់ សូមលោកជួយរៀបរាប់បន្តិចមក។

**ឆ៖** បាទ ក្នុងពេលនោះដែលគាត់អញ្ជើញមកដល់ គាត់មានប្រសាសន៍ថា គាត់មានប្រសាសន៍ ប្រាប់ប្រជាពលរដ្ឋថា យើងធ្វើបដិវត្តន៍នេះធ្វើដើម្បី និងផ្ដួលរំលំរបបលន់ នល់ របបលន់ នល់ ពីព្រោះ លន់ នល់ ជាអ្នកប្រឆាំងបដិវត្ត។ មួយទៀត ធ្វើនេះដើម្បីប្រឆាំងនឹងរបបនាយទុន សក្ដិភូមិ បញ្ញវន្ត។ ហើយបន្ទាប់មកគាត់ថា ក្នុងបដិវត្តន៍នេះមិនឲ្យមានអ្នកមាន មានអ្នកក្រទេ គឺថាឲ្យប្រជាជនមានភាព ស្មើៗគ្នា មានភាពស្មើៗគ្នា។ ហើយបន្ទាប់មកទៀត ក៏គាត់បានផ្ដាំផ្ញើថា ដែលអង្គការជម្លៀសបងប្អូន មកនេះ គឺថាជម្លៀសដើម្បីឲ្យផុតពីពួកយួនឈ្លានពាន ខ្លាចយួនសម្លាប់ពុកម៉ែបងប្អូន បានជម្លៀសឲ្យ យើងទៅនៅខាងនិរតី ឲ្យផុតពីកងទ័ពវៀតណាមដែលវាប្រុងចូលមក ពីព្រោះកន្លងមកមានចូលមកខ្លះៗ ហើយកាលនោះ តាមព្រំដែន រហូតដល់គេជម្លៀសចេញមក។ ហ្នឹងក្នុងពេលហ្នឹង គាត់នេះអ៊ីចឹង។ ដល់ គាត់ផ្ដាំផ្ញើមួយទៀត គាត់ថា ពេលដែលបងប្អូនទៅដល់និរតី ដល់បាត់ដំបងនោះ គឺថា ធ្វើយ៉ាងណាឲ្យ ពុកម៉ែបងប្អូនទាំងអស់គោរពតាមគោលនយោបាយ មាគ៌ារបស់បក្សឲ្យបានម៉ឺងម៉ាត់។ ហ្នឹងគាត់មាន ប្រសាសន៍អ៊ីចឹង។ ធ្វើយ៉ាងណាកុំក្បត់នឹងបក្ស តែក្បត់នឹងបក្ស បើបក្សដឹង ត្រូវសម្លាប់ចោល។ ហ្នឹង គាត់បានមានប្រសាសន៍អ៊ីចឹង។ ហើយគាត់បន្ថែមចុងក្រោយទៀត គាត់ថា ទុកក៏មិនចំណេញ យក ចេញក៏មិនខាតដែរ អ្នកក្បត់នឹងបដិវត្តន៍។ ហើយតមកទៀត គាត់និយាយច្រើន ប៉ុន្តែខ្ញុំមិនបានចាំអស់ ក្នុងពេលនោះ ពីព្រោះវាយូរឆ្នាំហើយ។ សូមអស់យោបល់។

[១៥:៣១:២៨]

**ស៖** សូមអរគុណ។ នៅមានចំណុចតូចមួយទៀត ខ្ញុំសូមសួរលោកត្រឡប់ទៅខាងដើមបន្តិច។ ពីខាងដើម លោកបានលើកឡើងថា លោកបានជាប់គុកនៅខាងស្វាយរៀង។ អ៊ីចឹងខ្ញុំសូមសួរបន្តិចថា មូលហេតុអីបានជាលោកត្រូវជាប់គុកនៅទីនោះ? លោកមានដឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ បានខ្ញុំជាប់គុក គេចោទខ្ញុំថា ខ្ញុំជាទាហានលន់នល់។ ហ្នឹងតាមខ្ញុំដឹង។ ពេលនោះ ខ្ញុំមុនដំបូង ខ្ញុំធ្វើជាទាហានមែន។ ដល់ពេលខ្ញុំត្រូវរបួស ខ្ញុំក៏ឈប់ពីទាហាន ខ្ញុំមកធ្វើជាប្រជាពលរដ្ឋ។ តែពេលធ្វើប្រជាពលរដ្ឋនេះ គេកៀងកម្លាំង គេថា គេជំរុញឲ្យយើងធ្វើចូលជាកងស្វ័យត្រាណ ដូចឪពុកខ្ញុំដែរ។ ដល់ហើយគេថា យើងជាទាហានលន់នល់ បានគេយកយើងមកដាក់គុកក្នុងពេលនោះ។ ហើយពេលដែលខ្ញុំជាប់គុកនោះគឺថា វាហួសហេតុពេក បើដេកក៏ដេកមិនបានដែរ ក្នុងវត្តតាដៃនុ៎ង ក្នុងសាលាឆាន់នុ៎ង លើសាលាឆាន់នុ៎ង សុទ្ធតែសង្កើច។ សង្កើចមិនដឹងជាប៉ុន្មានលានសង្កើចទេ គិតទៅមនុស្សវាជាង៥០០នាក់ ម្នាក់ៗគ្មានដេកបានយប់ សង្កើចវាខាំ សង្កើចវាខាំម្យប់ៗ ហ្នឹងគ្មានបានដេកប៉ុន្មានទេ នៅក្នុងពេលនោះ ហើយធ្វើការក៏ហួសកម្លាំង ក្នុងពេលនោះ។ ហូបក៏ហូបមិនឆ្អែត វេទនាជាទីបំផុត ក្នុងពេលជាប់គុកនោះ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់លោកបន្តិច ថាតើគេមានធ្វើទារុណកម្មលើរូបលោកដែរឬទេ?

[១៥:៣៣:៣២]

**ឆ៖** បាទ ក្នុងពេលនោះគេមិនបានធ្វើទារុណកម្ម ដូចជាដាក់ខ្នោះ ចង ឬក៏វ៉ៃដំអីទេ គ្រាន់ថា គេប្រើជាកម្លាំងឲ្យយើងអូសរទេះ ឬជីកព្រែក ជីកប្រឡាយ ធ្វើការធ្ងន់ៗ ប៉ុណ្ណឹង តែមិនបានទៅដាក់ខ្នោះ ឬចងអី អត់មានទេ។ ពេលគេសួរចម្លើយ ក៏គេមិនបានចង មិនបាននេះដែរ ហ្នឹងតាមដែលជាក់ស្តែង។ គ្រាន់តែគេហៅយើងទៅសួរ សួរចម្លើយបងប្អូនធ្វើអី នៅខាងលន់នល់ហ្នឹង។ បើបងប្អូនធ្វើអី គេឲ្យយើងធ្វើហ្នឹងវិញ។ ហ្នឹងពេលហ្នឹង គេប្រាប់អ៊ីចឹង គេសួរអ៊ីចឹង។ ដល់ហើយខ្លះក៏ឆ្លើយត្រង់ ខ្លះក៏មិនប៉ានឆ្លើយ។ ដល់ថ្ងៃក្រោយក៏នៅតែក្នុងគេដឹង។ ក្នុងដឹង ដឹងពីប្រជាពលរដ្ឋដូចគ្នា។ ខ្លះក៏ប៉ានប្រាប់គេ ខ្លះក៏មិនប៉ាន។ ដល់ហើយគេអាចស្រាវជ្រាវដឹង ពីព្រោះកាលនោះ គេស្រាវជ្រាវច្បាស់លាស់ណាស់ ពីព្រោះកាលនោះគេស្រាវជ្រាវច្បាស់លាស់ណាស់។ ដល់ហើយខ្ញុំ គេដឹងថា ខ្ញុំធ្វើជាទាហាន បានគេយកមកដាក់គុកក្នុងពេលនុ៎ង។

**ស៖** សូមអរគុណ។ អ៊ីចឹងលោកចាំបានទេ មានទោសចំនួនប៉ុន្មាន -- មានអ្នកដែលត្រូវជាប់នៅក្នុងគុកជាមួយលោកហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ? ហើយអ្នកទាំងនោះ គឺគាត់សុទ្ធតែជាទាហានលន់ នល់ដែរ ឬមួយក៏គាត់មានយ៉ាងម៉េចដែរ លោក?

**ឆ៖** បាទ កាលនោះអ្នកដែលជាប់គុកជាង៥០០នាក់នោះ គឺថាមានជាទាហានហ្នឹង ប្រហែលជា៣០ភាគរយ -- អំ ប្រហែលជា១០ភាគរយទេ ទាហាន បាទ សូមទោស។ ហើយដល់ស្វ័យត្រាណ កងស្វ័យត្រាណ ប្រហែលជា៣០ភាគរយ។ ហើយមួយទៀត ខាងប្រជាជន ប្រជាជន ហើយនិងសិស្សសាលា ខាងនិស្សិត និស្សិតហ្នឹងក៏មានគេយកទៅដាក់នៅនុំងដែរ ប្រហែលជាបួនដប់ភាគរយដែរហ្នឹង នៅក្នុងពេលនោះ។

[១៥:៣៥:៥០]

**ស៖** សូមអរគុណលោក។ ចុះពេលដែលលោកជាប់នៅទីនោះ មានការចាប់ចង ឬក៏មានការបាត់ខ្លួនអីដែរឬទេ អំឡុងពេលដែលលោកនៅក្នុងគុកនោះ?

**ឆ៖** បាទ ក្នុងពេលដែលខ្ញុំជាប់គុកនោះ គឺថាមានថ្ងៃមួយ ថ្ងៃមួយមិនដឹងគេយកអ្នកនុំងមកពីណា ស្រាប់តែយប់នុំង ឮសូរបាញ់ ប្រហែលជាម៉ោងប្រាំបីយប់ ឮសូរបាញ់។ ឮសូរបាញ់ យើងអ្នកដែលជាប់ហ្នឹង យើងក៏អត់ប៊ានចេញទេ អត់ប៊ានចុះពីសាលាឆាន់ទេ នៅដេកលើសាលាឆាន់ទាំងអស់។ ស្រាប់ដល់ព្រឹកឡើង ព្រឹកឡើង គេឲ្យយើងទៅមើល។ បាញ់ហ្នឹង បាញ់នៅខាងកើតវត្ត ជាយវត្តហ្នឹងតែម្តង តាមថ្នល់ នៅតាមថ្នល់ ថ្នល់នៅខាងត្បូងវត្ត។ ដល់ពេលហើយ ព្រឹកឡើង គេឲ្យយើងអ្នកជាប់ៗហ្នឹងទៅមើល។ ពេលនេះហើយ ដែលគេបំភិតបំភ័យយើង គេសម្លុតយើង ធ្វើឲ្យយើងតក់ស្លុតស្មារតី។ គេមិនឲ្យយើងប៊ានរត់។ គេឲ្យយើងទៅមើល ទៅមើលទៅ ខ្មោចហ្នឹង មិនដឹងគេដាក់ មិនដឹង ក៏ដួលទៅ ឃើញអ៊ីចឹងមិនដឹង ឃើញនៅចំតិតគូថ។ ដួលនៅចំតិតគូថនៅហ្នឹង។ ហើយគេឲ្យយើងទៅមើល ហើយបានគេឲ្យចូលមកវិញ។ ហើយគេប្រាប់ថា បងប្អូនកុំរត់ តែរត់ គេបាញ់ចោលអ៊ីចឹង។ ហ្នឹងពេលនោះ។

[១៥:៣៧:១១]

ហើយមានថ្ងៃខ្លះទៀត ក្នុងមួយយប់អ៊ីចឹង គេយកចេញ ចេញក្បែរៗក្រុម ក្បែរគ្នាហ្នឹង មួយយប់ពីរនាក់ បីនាក់ យកចេញ។ យកចេញហ្នឹង យកចេញទៅសម្លាប់នៅទួលខាងកើត ទៅសម្លាប់នៅទួលខាងកើត។ ទួលនោះគេហៅថា “ទួលស្លូត”។ ទួលស្លូត នៅឃ្លាតពីកន្លែងឃុំឃាំងទៅប្រហែលជា១គីឡូ

នៅខាងជើងផ្ទះខ្ញុំ ប្រហែលជាប្រាំពីរ ប្រាំបីរយម៉ែត្រហ្នឹង ហ្នឹងកន្លែងនុ៎ង។ តែកាលនោះខ្ញុំអត់បាននៅហ្នឹងទេ គេជម្លៀសខ្ញុំឱ្យចេញមកនៅចុងភូមិខាងជើងនេះ នៅអង្គាល់នុ៎ង។ ហើយដល់ពេលហើយ ព្រឹកឡើង ស្រាប់តែបាត់ បាត់គ្នាយើង យើងអត់ហ៊ានទេ អត់ហ៊ានសួរទេ អត់ហ៊ានសួរគ្នាទេ។ បាត់ៗទៅ បាត់ៗទៅ ហ្នឹងពេលនុ៎ង។ ស្រាប់តែដល់ក្រោយមក បានយើងដឹងទៅថា គេយកទៅសម្លាប់នោះ ពីព្រោះយើងដើរទៅធ្វើការ ខ្លះទៅដាំត្រសក់ ដាំននោងតាមៗទួលទៅ ឃើញអន្លង់គេជីកកប់ហ្នឹងទៅ បានដឹងថា អ៎! ប្រហែលជាគេយកមកសម្លាប់នៅកន្លែងហ្នឹង។ ហ្នឹងបានដឹងប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់សួរលោកថា ក្រៅពីរូបលោកជាទាហាន លន់ នល់ តើមានសមាជិកក្រុមគ្រួសាររបស់លោក -- តើលោកមានសមាជិកក្រុមគ្រួសារដែលធ្វើទាហាន លន់ នល់ ដែរឬក៏អត់ទេ លោក?

**ឆ៖** បាទ ក្នុងក្រុមគ្រួសារខ្ញុំមានបងថ្លៃខ្ញុំមួយឈ្មោះ បងសុខ ពិល ហ្នឹងគាត់ធ្វើជាទាហាន ហើយខ្ញុំហ្នឹងធ្វើទាហានបាន៣ខែដែរ តែខ្ញុំត្រូវរបួស ខ្ញុំឈប់។ ហ្នឹងមានប៉ុណ្ណឹង។ ឪពុកខ្ញុំ គាត់ជាប្រជាពលរដ្ឋទេ។

**ស៖** សូមអរគុណ។ តើបងប្រុសរបស់លោកឈ្មោះ សុខ ពិល ដែលជាទាហាន លន់ នល់ ហ្នឹង តើមានអីកើតឡើងចំពោះរូបគាត់ដែរឬក៏អត់? ហើយចំពោះក្រុមគ្រួសារគាត់ហ្នឹង មានអីកើតឡើងដែរឬក៏អត់?

[១៥:៣៩:២១]

**ឆ៖** បាទ ចំណែកបងខ្ញុំឈ្មោះ សុខ ពិល នេះ ចំណែកមានបញ្ហាលើគ្រួសារគាត់ គេយកគាត់មករៀន យកមករៀននៅវត្តគ្រួសហ្នឹង បាត់ខ្លួនទាល់អំមិញទៅ។ ហើយនៅសល់ប្រពន្ធគាត់ គេបញ្ជូនមកជាមួយឪពុកខ្ញុំ គេជម្លៀសមកជាមួយឪពុកខ្ញុំមកព្រៃវែង។ មកដល់ព្រៃវែងហ្នឹង បានរយៈកាលប្រហែលជា២ខែ ហ្នឹងបើតាមដំណឹងម្ដាយក្មេកខ្ញុំ គាត់អញ្ជើញមកជាមួយ គេជម្លៀសមកជាមួយដែរ គាត់នៅរស់សព្វថ្ងៃ គាត់ថា មកដល់ព្រៃវែងហ្នឹង មកដល់ពាមជរហ្នឹង ប្រហែលជា២ខែ គេដឹង គេស្រាវជ្រាវម៉េចទេ គេដឹងថា បងខ្ញុំហ្នឹងត្រូវជាប្ដី ប្ដីត្រូវជាទាហានលន់ នល់ ធ្វើទាហាន លន់ នល់។ គេក៏យកគាត់ទៅសម្លាប់នៅព្រែក នៅកោះដាច់។ ហើយពេលសម្លាប់ហ្នឹង បើតាមព័ត៌មានដែលម្ដាយក្មេកគាត់ប្រាប់ខ្ញុំហ្នឹង គេវាំងជាសំណាញ់ វាំងជាព្រួល ព្រោះខែនុ៎ង ខែទឹកឡើង។ គេវាំងជាព្រួលកណ្ដាលទន្លេ គេជីកកាណូតយកទៅដល់ គេពន្លិចនៅកណ្ដាលទន្លេហ្នឹង ៗបើតាមនុ៎ង។ ហើយខ្ញុំគ្រាន់តែឮអ៊ីចឹង

ខ្ញុំតក់ស្លុតអស់ ពីព្រោះបាត់បង់បងប្អូន ឪពុកម្ដាយអស់។ ហើយនៅចំណែកឪពុកខ្ញុំ ដល់ពេលគេបញ្ជូនខ្ញុំមកក្រោយ គេបញ្ជូនគាត់ពីព្រៃវែង ពីពាមជរ ទៅដល់បាក់ចិញ្ចៀនដែរ ហ្នឹងពេលនុ៎ង។ ហើយគាត់ក៏ស្លាប់នៅបាក់ចិញ្ចៀនបាត់អស់ទៅ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបញ្ជាក់ឡើងវិញ លោកថា បងថ្លៃឈ្មោះ សុខ ពិល ហ្នឹងត្រូវគេបញ្ជូនទៅរៀន។ មូលហេតុអីបានជាគេបញ្ជូនគាត់ទៅរៀន លោក?

**ឆ៖** បាទ មូលហេតុ គាត់ធ្វើទាហាន ធ្វើទាហាន លន់ នល់។

[១៥:៤១:១០]

**លោកស្រី ទី ស្រ៊ុនណា៖**

សូមអរគុណ។ ខ្ញុំអស់សំណួរហើយ។ សូមអរគុណចំពោះការឆ្លើយដ៏ក្បោះក្បាយរបស់លោក និងសូមអរគុណលោកប្រធាន និងសូមផ្ទេរវេទិកាជូនទៅខាងសហព្រះរាជអាជ្ញា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញា!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្ដឹង។ ខ្ញុំមានសំណួរបន្តិចបន្តួចប៉ុណ្ណោះ។ សំណួរទី១ ខ្ញុំចង់សួរថា តើលោករៀបការនៅសម័យខ្មែរក្រហមមែនទេ?

**2-TCCP-1063៖**

**ឆ៖** បាទ កាលនោះ ខ្ញុំរៀបការតាំងពីសម័យ លន់ នល់។

**ស៖** អ៊ីចឹងលោកមិនបានរៀបការដោយការរៀបចំនៅក្នុងរបបខ្មែរក្រហមទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់បានរៀបក្នុងសម័យខ្មែរក្រហមទេ។

**ស៖** សូមអរគុណលោក។ ខ្ញុំមានសំណួរពីរបីបន្តទៀត ទាក់ទងទៅនឹងអ្វីដែលលោកបានប្រាប់យើង ទាក់ទងទៅនឹងសុន្ទរកថារបស់ ខៀវ សំផន។ នៅពេលដែលលោកមកភ្នំពេញហ្នឹង តើលោកធ្វើដំណើរចេញពីណា មកភ្នំពេញហ្នឹង?

**ឆ៖** បាទ ខ្ញុំបាន--

[១៥:៤២:៤០]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំទាលទាន់ឆ្លើយ!

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន មើលសំណួររបស់សហព្រះរាជអាជ្ញានេះ ខ្ញុំសូមជំទាស់ដូចព្រឹកមិញដែរហ្នឹង គឺថាយើងមានដើមបណ្ដឹងរដ្ឋប្បវេណី មកនិយាយអំពីការឈឺចាប់របស់គាត់ទាំងអស់ ក៏ប៉ុន្តែខ្ញុំឃើញថាសហព្រះរាជអាជ្ញា កំពុងតែនិយាយអំពីការផ្លាស់ទីរបស់ប្រជាជន ការជម្លៀសនៅឆ្នាំ១៩៧៧ ក្រៅពីក្របខ័ណ្ឌវិសាលភាពនៃសំណុំរឿង០២/២។ អ៊ីចឹងខ្ញុំសូមជំទាស់នឹងសំណួរនេះទៀត។ ហើយខ្ញុំសូមរំឭកផងដែរថា ដើម្បីឲ្យច្បាស់លាស់ទាំងអស់គ្នានេះ ថានៅសវនាការថ្ងៃទី០៨ កញ្ញា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញារង លោក វាំងសង់ ដឺវីល បានបញ្ជាក់នៅម៉ោង១១:០៥:០៩វិនាទីថា មូលហេតុនៃការមកផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺដើម្បីមកនិយាយអំពីសុន្ទរកថារបស់លោក ខៀវ សំផន។ ខ្ញុំសូមដកស្រង់៖ "ដោយហេតុថាជាសក្ខីកម្មខ្លី ពីព្រោះអ្វីដែលយើងចាប់អារម្មណ៍ គឺផ្នែកហ្នឹងហើយ គឺផ្នែកមួយនៃសុន្ទរកថារបស់ ខៀវ សំផន។" អ៊ីចឹងយើងឃើញថាសួរ គឺថាតើដើមបណ្ដឹងរដ្ឋប្បវេណីមកពីណា ពីណើនោះ អ៊ីចឹងខ្ញុំគិតថា បើយើងគិតថាកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីមក ដើម្បីឲ្យគាត់និយាយអំពីអ្វីដែល ខៀវ សំផន បានលើកឡើងអីនោះ ឃើញមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនេះគាត់ចោទសំណួរពីមុនមកនោះ ឃើញថា វាខុសហើយ ខុសពីវិសាលភាពហើយ។

[១៥:៤៤:៥៣]

**លោក នីកូឡាស គូមជែន៖**

គឺថាខ្ញុំសូមឆ្លើយតប ដោយសារតែយើងទទួលបានពីរវគ្គ ហើយឥឡូវនេះមានការរំខាន ដូច្នេះខ្ញុំ<ក្រែងតែមិនចប់តាមពេលវេលាដែលបែងចែកឲ្យនោះទេ>។ ចំណុចទី២ទាក់ទងទៅនឹការផ្លាស់ទីលំនៅគឺថាកថាខណ្ឌ<៣៧> នៅក្នុងឯកសារ <E3 101/9/1>ហ្នឹង គឺបានបញ្ជាក់ថា ដំណាក់កាលទី៣ នឹងត្រូវបានលើកយកមកដោះស្រាយនៅក្នុងករណីមួយចំនួននៅក្នុងសំណុំរឿង០០២/០២ ជាពិសេសទាក់-ទងទៅនឹងស-២១ និងការបោសសម្អាតផ្ទៃក្នុង ក៏ដូចជាការជម្លៀសប្រជាជនដែរ។ ហើយបន្ថែមពីលើនេះទៀត សំណួរដែលខ្ញុំសួរសាក្សីនេះ គឺនិយាយអំពីសុន្ទរកថារបស់ ខៀវ សំផន ទេ។ ដើម្បីឲ្យដឹងហើយនិងឲ្យយល់ពីបរិបទអំពីការងាររបស់ ខៀវ សំផន យើងចាំបាច់ត្រូវដឹង ថាតើគាត់និយាយជាមួយ

ក្រុមណាមួយ។ ហើយវាជាការសំខាន់ដើម្បីឲ្យ<យល់>អំពីខ្លឹមសាររបស់ក្រុមដែលយើងគិតថាជាក្រុមជនសង្ស័យ ព្រោះពួកគាត់ជាខាងបូព៌ា ដែលគេជម្លៀសពីខាងបូព៌ាទៅខាងភូមិភាគដទៃទៀត។ ដូច្នេះយើងមិនអាចយល់អំពីការងាររបស់ ខៀវ សំផន បានទេ ប្រសិនបើយើងមិនដឹងថាតើ ខៀវ សំផន គាត់ថ្លែងទៅកាន់ក្រុមណា ហើយហេតុអ្វីដែលពួកគាត់និយាយ ហើយហេតុអ្វីបានគាត់និយាយអំពីបញ្ហាខ្មាំងក៏ដូចជាអ្នកដែលក្បត់នឹងបក្សដូចគ្នានេះដែរ។

[១៥:៤៦:១៣]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកសហព្រះរាជអាជ្ញា កំពុងតែឆ្លើយតបទៅនឹងការជំទាស់របស់គាត់នោះ គឺថា គាត់លើកពីកថាខណ្ឌមួយ ព្រោះថាគោលបំណងនិយាយពីការជម្លៀសលើកទី៣ ដំណាក់កាលទី៣ ហើយនិងការបោសសម្អាតនៅមន្ទីរស-២១។ ក៏ប៉ុន្តែនេះ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គាត់និយាយអំពីការជម្លៀសផ្លាស់ទីរបស់គាត់មក។ អ៊ីចឹងខ្ញុំនៅតែរក្សាការជំទាស់របស់ខ្ញុំដដែល វាអត់ពាក់ព័ន្ធទេ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ ហើយសំណួរនេះអាចសួរបាន បរិបទនេះគ្រាន់តែអង្គជំនុំជម្រះមិនឲ្យសួរលម្អិត ពាក់ព័ន្ធជាមួយនឹងអង្គហេតុជម្លៀសប្រជាជនដំណាក់កាលទី៣ប៉ុណ្ណោះ។ បរិបទដែលឲ្យដាច់គ្នាជាកង់ៗហ្នឹង គឺនឹងមិនមានខ្លឹមសារទាំងការស្តាប់ ទាំងការសរសេរនិងការគិតមិនដឹងថាគិតយ៉ាងម៉េចទេ ដូច្នេះសំណួរនេះអាចសួរបាន។ ហើយសាក្សីឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានសួរចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកចាំ បើលោកមិនចាំទេ សូមឲ្យសហព្រះរាជអាជ្ញាអន្តរជាតិនេះសួរម្តងទៀត។

**2-TCCP-1063៖**

បាទ ក្នុងពេលនោះខ្ញុំអត់បានចាំផង ខ្ញុំអត់បានចាំ វាភ្លេចអស់ដែរ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារង -- សហព្រះរាជអាជ្ញាអន្តរជាតិ សួរសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត ប្រហែលជាសាក្សីរូបនេះភ្លេចសំណួររបស់លោកហើយ។

[១៥:៤៧:៤៣]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ លោកដើមបណ្តឹងលោកបាននិយាយអំពីការប្រមូលមុំនៅភ្នំពេញ ដូច្នេះតើលោកអាចប្រាប់បានទេ ថាហេតុអ្វីបានជាលោកធ្វើដំណើរមកភ្នំពេញ? តើលោកចេញដំណើរពីទីណាមកដល់ទីណាខ្លះ? សូមលោកជួយរៀបរាប់។

**2-TCCP-1063៖**

**ឆ៖** បាទ អរគុណ។ ខ្ញុំបានជាមូលហេតុបានខ្ញុំមកដល់ភ្នំពេញ គឺពួកខ្មែរក្រហមហ្នឹងបានជម្លៀសខ្ញុំចេញពីភូមិតាដៃ ឃុំកំពង់ចំលង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដើម្បីឲ្យទៅនៅខេត្តបាត់ដំបង។ តែមុននោះ មុននឹងដល់ខេត្តបាត់ដំបងនោះ គឺថាខ្ញុំបានចេញដំណើរពី១ស្វាយរៀង ពីស្វាយរៀងមកដល់ភ្នំពេញនេះ គឺថាវាច្រើនយប់ណាស់។ យប់ទី១ ថ្ងៃទី១ ខ្ញុំចេញពីភូមិតាដៃ មកដល់ក្រោលគោ។ ដល់ក្រោលគោហ្នឹង សម្រាកហ្នឹងមួយថ្ងៃ មួយយប់ សម្រាកមួយយប់។ មួយយប់ហ្នឹង ក្នុងយប់នោះមានភ្លៀងធំទៀត ព្រោះខែនោះខែភ្លៀង។ មានភ្លៀងធំ អត់មានកន្លែងជ្រកទេ គឺថាខ្ញុំជ្រកនៅតាមរោងម៉ាស៊ីនសំយ៉ាបរោងម៉ាស៊ីន--

**ប្រធានអង្គជំនុំ៖**

លោកសង្ខេបទៅបានហើយ សំណួរមិនសួរលម្អិតអ៊ីចឹងទេ។ មូលហេតុអីដែលគេជម្លៀសពីនុ៎ងមក? ហើយជម្លៀសពីណាមក១បានមកដល់ផ្សារ លោកអះអាងថាផ្សារច្បារអំពៅអំមិញនេះ? យល់ទេសំណួរនេះគឺខ្លីទេ?

[១៥:៤៩:២៧]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ ខ្ញុំគិតថាខ្ញុំយល់អ្វីដែលដើមបណ្តឹងគាត់បាននិយាយ គឺគាត់ធ្វើដំណើរពី ១ <ស្វាយរៀង>ទៅបាត់ដំបង។ ដូច្នេះខ្ញុំចង់សួរថា អ្នកដែលចូលរួមស្តាប់សុន្ទរកថារបស់ ខៀវ សំផន ហ្នឹងគឺជាអ្នកមកពីបូព៌ាទាំងអស់មែនទេ?

**2-TCCP-1063៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកប្រធាន។ អ្នកដែលចូលរួមស្តាប់នេះ គឺថាសុទ្ធតែអ្នកជម្លៀសមកពីបូព៌ា បាទ ទាំងអស់។

**ស៖** លោកនិយាយថា មានអ្នកចូលរួមច្រើន ប៉ុន្តែតើលោកអាចប៉ាន់ប្រមាណមើល ថាតើមានមនុស្សប៉ុន្មាននាក់ដែរ ប្រហែលជាប៉ុន្មាននាក់ដែរ ដែលចូលរួមនោះ?

**ឆ៖** បាទ មនុស្សនោះ បើតាមខ្ញុំស្មានមើលទៅប្រហែលជារាប់ពាន់នាក់ ប្រហែលជារាប់ពាន់នាក់ណោះ ព្រោះច្រើនណាស់ ច្រើនណាស់។

**ស៖** តើអ្នកចូលរួមនោះ មានគ្រប់វ័យ មានទាំងស្រី មានទាំងប្រុស អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ្នកចូលរួមនោះគឺថា អ្នកជម្លៀសមកហ្នឹងគឺថា មានប្រុស មានស្រី មានកុមារ ចូលរួមទាំងអស់ មកតាមឪពុកម្ដាយ។ មានកូនតូចៗហ្នឹងមកតាមទាំងអស់។

**ស៖** តើមានក្រុមប្រដាប់អាវុធមកការពារអ្នកដែលចូលរួមហ្នឹងដែរឬទេ?

[១៥:៥១:១៤]

**ឆ៖** បាទ ពេលនោះមាន មានអ្នកមកការពារនៅក្រៅផ្សារហ្នឹង គេការពារជុំវិញ។ គេខ្លាចយើងរត់ត្រឡប់ទៅវិញយ៉ាងមើលទៅ។

**ស៖** ប្រសិនបើលោកឃើញថា ខៀវ សំផន ធ្វើដំណើរមកហ្នឹង ចង់ដឹងថាតើគាត់ធ្វើដំណើរតាមរថយន្តអ្វីដែរ? ហើយតើមានរថយន្តប៉ុន្មានគ្រឿងដែរ ដែលមកជាមួយគាត់នោះ?

**ឆ៖** បាទ គាត់ធ្វើដំណើរមកនេះ ថ្ងៃនោះមានរថយន្តពីរគ្រឿង មានរថយន្តតែពីរគ្រឿងទេ។

**ស៖** តើនៅពេលនោះ លោកឃើញថាគាត់មានកងការពារមកជាមួយដែរឬទេ?

**ឆ៖** បាទ ពេលនោះមានគ្នាគាត់មកទាំងអស់ មិនដឹងពីណាការពារពីណា គ្រាន់ថា ពេលនោះមានគាត់ គ្នាគាត់ប្រហែលជា១០នាក់ជាង។

**ស៖** តើ<>សម្ភារៈដែលគេ<ចែកឲ្យនោះ គេដឹកមកជាមួយគាត់> ឬក៏មក<នៅពេលផ្សេង> គ្នា? ហើយថាតើគេបញ្ជូនមក<ឡាន ឬ>តាមកប៉ាល់ ឬក៏តាមអីដែរ?

**ឆ៖** បាទ សម្ភារៈនេះគឺថា គេដាក់ឡានមក ដាក់ឡានមក ដាក់រថយន្តមក មកទុកនៅកន្លែងហ្នឹងតែម្ដង។ គេមកដល់ គេបែងចែកនៅកន្លែងហ្នឹង។

**ស៖** <តើលោកឃើញ>រថយន្តហ្នឹង<ទេ?> តើជារថយន្តដឹកអីវ៉ាន់ធំៗ ឬក៏ជារថយន្តប្រភេទអ្វីដែរ?

**ឆ៖** រថយន្តហ្នឹង រថយន្តពណ៌កងទ័ព ពណ៌កងទ័ព រថយន្តហ្នឹង។

**ស៖** សូមអរគុណ។ តើ ខៀវ សំផន គាត់ថ្លែងសុន្ទរកថាហ្នឹងអស់រយៈពេលប្រហែលជាប៉ុន្មាននាទីដែរ?

[១៥:៥៣:៥៨]

**ឆ៖** បាទ លោក ខៀវ សំផន គាត់ឡើងថ្លែងសុន្ទរកថា ហ្នឹងចំនួនប្រហែលជា ជាងកន្លះម៉ោង ប្រហែលជាជាងកន្លះម៉ោង បានគាត់ចប់ ព្រោះគាត់ ឮថាគាត់ប្រញាប់ដែរ ឬក៏ប្រញាប់ឲ្យប្រជាពលរដ្ឋឡើងរថយន្តនៅក្នុងពេលនុ៎ង។

**ស៖** តើក្រោយពេល ខៀវ សំផន ចាកចេញទៅ តើមនុស្សនៅក្នុងក្រុមជាមួយលោកហ្នឹង គេបានជជែកពិភាក្សាគ្នាអំពីសុន្ទរកថារបស់ ខៀវ សំផន ហ្នឹងដែរទេ?

**ឆ៖** បាទ កាលនោះ ដូចជាមិនសូវបានចាប់អារម្មណ៍ពីរឿងសុន្ទរកថាប៉ុន្មានទេ ពីព្រោះយើងកំពុងតែពិបាក កំពុងតែរញ៉េរញ៉ៃ អារឿងកូនចៅ អារឿងធ្វើដំណើរបន្តទៅទៀត យើងអត់ទាន់បានមានចាប់អារម្មណ៍នៅក្នុង លើសុន្ទរកថារបស់គាត់ទេ។

**ស៖** លោកបាននិយាយថា ចំណុចមួយដែល ខៀវ សំផន បានលើកឡើង គឺថាខ្ញុំអត់មានពាក្យលោកដោយផ្ទាល់ទេ ប៉ុន្តែខ្ញុំនឹងសង្ខេប គឺថារំលោភ ឬក៏ក្បត់បក្ស។ អ្នកដែលក្បត់បក្សនឹងត្រូវបានគេសម្លាប់ ពីព្រោះពួកគេទុកក៏មិនចំណេញដែរ។ ដូច្នេះខ្ញុំចង់សួរថា តើនៅពេលដែលលោកឮគេនិយាយបែបហ្នឹង តើលោកមានអារម្មណ៍យ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ អរគុណ។ នៅក្នុងពេលនោះខ្ញុំ ដល់ឮគេនិយាយអ៊ីចឹង ខ្ញុំមានការភ័យខ្លាចតក់ស្លុត ខ្លាចក្រែងលោយើងខុសដោយប្រការណាមួយ យើងអត់ដឹង ពីព្រោះតាមតែធ្លាប់ឃើញ គឺថាអ្នកខ្លះអត់មានកំហុសអី ស្រាប់តែយកទៅបាត់ៗ អស់អ៊ីចឹង។ នុ៎ងដែលហើយដែលយើងតក់ស្លុត យើងភ័យ ភ័យតែមែនទែន។ ម៉្លោះហើយម្នាក់ៗគិតតែក្នុងខ្លួនថា មិនដឹងយើងគេយកទៅថ្ងៃណាទេ។ ចេះតែភិតភ័យជាប្រចាំ។

[១៥:៥៦:២១]

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសូមបញ្ចប់នៅប្រហែលជា៥នាទីទៀតប៉ុណ្ណោះ។ ឥឡូវនេះខ្ញុំចង់និយាយអំពីអ្វីដែលលោកបាននិយាយអំពីការឃុំខ្លួនជាមួយនឹងអ្នកដទៃទៀតនៅតាមវត្ត ហើយនិងជាមួយទាហានមួយនឹងចំនួនទៀតនោះ។ នៅក្នុងពេលនោះ ក្រោយពេលខ្មែរក្រហមទទួលបានជ័យជម្នះឆ្នាំ៧៥ គឺថាពេលហ្នឹង គេកំពុងគេតាមស្វែងរកប្រវត្តិរូប ហើយនិងតួនាទីរបស់ប្រជាជនកន្លងមក។ ដូច្នេះតើលោកឃើញថា តើមានការប្រព្រឹត្តខុសគ្នាដែរឬទេ រវាង<ពលទាហាន> ជាមួយនឹងអតីត<នាយ>ទាហាន<>?

**ឆ៖** បាទ ក្នុងពេលនោះ ខ្ញុំមានអារម្មណ៍មួយភិតភ័យមែនទែន ព្រោះពេលមុនដំបូង យើងថា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងអត់ធ្វើអីទេ យើងប្រាប់គេថា ខ្ញុំអត់បានធ្វើអីទេ ខ្ញុំជាប្រជាពលរដ្ឋ។ ដល់ពេលក្រោយមក ខ្ញុំនឹកឃើញថា ខ្ញុំភូតគេ។ ភូតគេ ដល់ហើយខ្ញុំមានការភិតភ័យតែម្ដងទៅ។ ភិតភ័យខ្លាចគេដឹង ថាខ្ញុំធ្វើជាទាហាន។ ដល់ថ្ងៃក្រោយមក នៅតែក្នុងគេដឹងមែន ក្នុងគេដឹងមែន គេក៏បានយកខ្ញុំ ត្រឹមឲ្យទៅរៀនសូត្រហ្នឹង។ ចៃដន្យវាអត់បានស្លាប់។ នៅក្នុងពេលនោះ គឺថាបានត្រឹមតែមួយជាប់គុក។ មានការភិតភ័យជាងអ្នកដែលគេមិនមានធ្វើការអីសោះ។

**ស៖** នៅពេលដែលខ្មែរក្រហមសួរអតីត<ទាហាន> តើគេមានសួរអំពីឋានន្តរសក្តិ ថាតើជា<ពលទាហាន ឬជាអនុសេនីយ៍ ឬជាវរសេនីយ៍>អីដែរទេ?

[១៥:៥៨:១៣]

**ឆ៖** បាទ ពេលនោះគេសួរទាំងអស់ គេសួរទាំងអស់។ លោកឯងធ្វើទាហានហ្នឹង ស័ក្តិប៉ុន្មាន? គេសួរអីចឹង។ ស័ក្តិប៉ុន្មាន ប្រាប់គេឲ្យត្រង់មក គេឲ្យធ្វើវិញ ហើយគេឲ្យធ្វើការងារហ្នឹងវិញ ស័ក្តិប៉ុន្មានគេឲ្យពាក់ស័ក្តិប៉ុណ្ណឹងវិញ។ តែដូចខ្ញុំៗជាកូនទាហានទេកាលនុ៎ង ខ្ញុំមិនទាន់មានបុណ្យស័ក្តិអីទេ។ ហើយអ្នកដែលមានបុណ្យស័ក្តិហ្នឹង អ្នកណាដែលស័ក្តិធំទៅ គេយកទៅរៀនឆ្ងាយ យកទៅរៀនឆ្ងាយ។ អ្នកដែលស័ក្តិ -- អ្នកដែលអត់មានបុណ្យស័ក្តិនៅរៀនជាមួយខ្ញុំនេះ ជាប់គុកជាមួយខ្ញុំ។ ហ្នឹងអ្នកទាហានៗហ្នឹង។ អ្នកណាមានស័ក្តិធំៗ សក្តិ១ សក្តិ២ហ្នឹង គេយកទៅរៀនឆ្ងាយ បាត់ខ្លួនទាល់អំមិញអស់ហ្នឹង។ បាទ ដឹងប៉ុណ្ណឹង។

**ស៖** តើលោកបានឃើញ ឬក៏បានស្គាល់អ្នកណាម្នាក់ដែលប្រាប់គេថា មានឋានន្តរសក្តិខ្ពស់ ហើយត្រូវបានគេយកទៅ<រៀនសូត្រ>កន្លែងណាផ្សេងទេ? ហើយប្រសិនបើលោកបានស្គាល់ តើពួកគាត់ហ្នឹងត្រឡប់មកវិញ ឬក៏លោកបានឃើញពួកគាត់នៅពេលក្រោយមកទៀតទេ?

**ឆ៖** បាទ ពីព្រោះពេលនោះ ខ្ញុំអត់បានដឹងទេ គ្រាន់ថាគេអ្នកដឹង យើងៗអត់ដឹងថា អ្នកណាប្រាប់ អ្នកណាមិនប្រាប់ យើងអត់បានដឹងទេ។ ទោះបីអ្នកហ្នឹងប្រាប់ ក៏យើងមិនដឹង ព្រោះគេលាក់ការណ៍គេមិនឲ្យយើងដឹងទេ ក្នុងពេលនោះ។

**ស៖** ចុះ<មេបញ្ជាការ>របស់លោក<កាលលោកនៅជាទាហាន និងជាកងស្វ័យត្រាណវិញនោះ> តើលោកដឹងទេថា មានអ្នកណាខ្លះនៅរស់រានមានជីវិតក្រោយរបបកម្ពុជាប្រជាធិបតេយ្យទេ?

[១៦:០០:២០]

**ឆ៖** បាទ អ្នកដែលរងគ្រោះជាមួយខ្ញុំហ្នឹងគឺថាមាន មានអ្នកនៅរស់ច្រើនដែរ។ ខ្លះក៏ស្គាល់ ខ្លះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏មិនស្គាល់។ តែជាក់ស្តែង តែអ្នកដែលជម្លៀសចេញពីបូព៌ាទៅដល់បាត់ដំបងនេះគឺថា នៅរស់មកវិញនៅសល់ប្រហែលជា២០គ្រួដែរ។ ទៅហ្នឹងវា៧០គ្រួ ដល់ឥឡូវនៅសល់ប្រហែលជា២០គ្រួទេ។ ២០គ្រួនោះគឺថា នៅក្នុងភូមិខ្ញុំបាទហ្នឹង មានៗឈ្មោះច្រើនដែរ ប៉ុន្តែខ្ញុំសូមលាក់ឈ្មោះបានទេ ក៏ម៉េច?

**លោក នីកូឡាស គូមជែន៖**

លោកដើមបណ្តឹងរដ្ឋប្បវេណី សូមអរគុណច្រើន។ ហើយខ្ញុំក៏សូមអរគុណចំពោះលោកប្រធានដែរ ដោយសារខ្ញុំដល់ពេលវេលា ខ្ញុំសូមបញ្ចប់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០១ ខែធ្នូ ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1063 បញ្ចប់ និងផ្តើមស្តាប់សក្ខីកម្មសាក្សី 2-TCW-1069 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ និងឱ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែក ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ។

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*